ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ការសន្សំ និង ការចំណាយ



**បំណិនជីវិតសម្រាប់មធ្យមសិក្សាបឋមភូមិ**
**គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា**

USAID ជំនួយពីពលរដ្ឋអាមេរិក
អង្គការអប់រំពិភពលោក WORLD EDUCATION
AFLATOUN Child Social & Financial Education

ឧបត្ថម្ភដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិ
រៀបចំដោយ អង្គការអប់រំពិភពលោក សហការជាមួយអង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ : ៩៤៥ អយក.ប្រក

# ប្រកាស
## ស្តីពី
## ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយ
## សៀវភៅ " ការសន្សំ និងការចំណាយ "

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
-បានឃើញអនុក្រឹត្យលេខ ៨៨អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
-យោងសេចក្តីណែនាំលេខ ០៣ អយក.សណន.ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៣ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីប្រព័ន្ធអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស
-យោងសំណើរបស់អង្គការអប់រំពិភពលោក ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១២
-យោងកំណត់ហេតុប្រជុំរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអនុម័តសៀវភៅ និងសម្ភារឧបទេសនាថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៤
-តាមសំណើរបស់ប្រធានក្រុមប្រឹក្សាអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស

## សម្រេច

ប្រការ ១ - អនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅ " ការសន្សំ និងការចំណាយ " ដែលជាស្នាដៃនិពន្ធ និងរៀបរៀងរបស់អង្គការអប់រំពិភពលោក សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីប្រើប្រាស់ជាឯកសារជំនួយក្នុងការបង្រៀននិងរៀនកម្មវិធីបំណិនជីវិត នៅតាមសាលារៀនមធ្យមសិក្សាបឋមភូមិ ។

ប្រការ ២ - អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ និងអង្គការអប់រំពិភពលោក មានភារកិច្ចអនុវត្តប្រកាសនេះ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤

បណ្ឌិត ហង់ ជួន ណារ៉ុន

កន្លែងទទួល:
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីជូនជ្រាបជាព័ត៌មាន "
- ដូចប្រការ២
- កាលប្បវត្តិ
- ឯកសារនា. អកស.

# គណៈកម្មការអភិវឌ្ឍសៀវភៅ
# "ការសន្សំ និង ការចំណាយ"


**គណៈកម្មការនិពន្ធ និងរៀបរៀង**

១. លោក អេង  សុខ
២. លោក វីលៀម វ៉ាន់ឌឺវ៉ាល់

**គណៈកម្មការកែសម្រួល**

១. លោក ឈុំ វណ្ណធន
២. លោក ប៊ុត សុភាន់
៣. លោក ផុក ចាន់ថុល



ឧបត្ថម្ភថវិកាដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិ(USAID)

សហការរៀបចំដោយ
អង្គការអប់រំពិភពលោក និង ក្រសួងអប់រំ យុវជន និងកីឡា

# មាតិកា


អារម្ភកថា........................................ ក

វត្ថុបំណងរួម........................................ ខ

ការត្រៀមលក្ខណៈមុនពេលបង្រៀន........................................ ខ

ខ្លឹមសារសង្ខេប........................................ គ

មេរៀនទី ១៖ តម្រូវការ និងចំណង់........................................ ១

មេរៀនទី ២៖ ការសន្សំប្រាក់........................................ ៩

មេរៀនទី ៣៖ សុវត្ថិភាព........................................ ១៤

មេរៀនទី ៤៖ ការរៀបចំ........................................ ១៨

មេរៀនទី ៥៖ ការទៅធនាគារ........................................ ២៣

មេរៀនទី ៦៖ ធនាគារ........................................ ២៨

មេរៀនទី ៧៖ អសុវត្ថិភាព........................................ ៣១

មេរៀនទី ៨៖ សង្កេត........................................ ៣៥

មេរៀនទី ៩៖ បទបង្ហាញ........................................ ៣៩

មេរៀនទី ១០៖ ការសន្សំ........................................ ៤៦

# អារម្ភកថា

វិស័យអប់រំជាវិស័យគន្លឹះមួយ រួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច ពិសេសការអភិវឌ្ឍធនធានមនុស្ស។ ដោយសង្គមជាតិយើងមានការអភិវឌ្ឍលើគ្រប់វិស័យ ការអប់រំក៏ត្រូវបានយកចិត្តទុកដាក់យ៉ាងខ្លាំង ដើម្បីបណ្តុះបណ្តាលធនធានមនុស្ស ប្រកបដោយគុណភាពនិងមានជំនាញខ្ពស់ ដើម្បីបំពេញលើគ្រប់លក្ខខណ្ឌការងារ។

ដើម្បីឆ្លើយតបនឹងតម្រូវការរីកចម្រើននៃទីផ្សារសេរីរបស់សង្គមជាតិ ក្រសួងអប់រំ យុវជននិងកីឡា បានបង្កើតគោលនយោបាយសម្រាប់អភិវឌ្ឍន៍កម្មវិធីសិក្សាចំណេះទូទៅ និងគោលនយោបាយអប់រំបំណិនជីវិត សម្រាប់អនុវត្តន៍នៅតាមសាលារៀនចំណេះទូទៅ។

កម្មវិធីបំណិនជីវិតនៅតាមមូលដ្ឋាន គឺជាស្នូលនៃការបង្កើនគុណភាព និងប្រសិទ្ធភាពក្នុងវិស័យអប់រំ ដែលនឹងផ្តល់ឱ្យសិស្សនូវចំណេះដឹងមូលដ្ឋានយ៉ាងជ្រៅជ្រះ និងពង្រឹងជំនាញផ្សេងៗ ដែលមានសារៈសំខាន់សម្រាប់ការស្រូបយកបទពិសោធន៍ល្អៗក្នុងការពង្រឹងចំណេះដឹង និងបំណិន ចាំបាច់សម្រាប់បម្រើជីវភាពរស់នៅប្រចាំថ្ងៃ។

នៅក្នុងប្រទេសកម្ពុជា មានវប្បធម៌ក្នុងការសន្សំលុយ និងវត្ថុមានតម្លៃផ្សេងៗតាមមធ្យាបាយជាច្រើន។ នៅក្នុងម៉ូឌុលនេះ យើងចង់បង្រៀនសិស្សអំពីគុណវិបត្តិ និង គុណប្រយោជន៍ នៃវិធីផ្សេងៗដូចជា ការទិញគោ ការទិញដីការទិញមាស ឬជួលរបស់របរមានតម្លៃ។

ក្រៅពីនេះ យើងចង់ឱ្យសិស្សសិក្សាអំពីការសន្សំវត្ថុដែលមិនមែនជាលុយគឺមានសារប្រយោជន៍សម្រាប់ ខ្លួនពួកគេ និងបរិស្ថានរស់នៅ។

ប្រព័ន្ធធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកំពុងមានការកើនឡើងខ្លាំង។ ដូច្នេះ វាមានការចាំបាច់ដែលសិស្សត្រូវរៀន ថាតើស្ថាប័នទាំងនោះធ្វើការរបៀបណា និងពួកគេអាចប្រើវាយ៉ាងដូចម្តេច។ ម៉ូឌុលនេះនឹងមិនផ្តោតទៅលើរបៀបចាត់ចែងថវិកា និងការគ្រប់គ្រងប្រាក់ឡើយ។ ដូច្នេះ យើងបានសរសេរម៉ូឌុលបំណិនជីវិតផ្សេងទៀតដែលមានឈ្មោះថា "ការគ្រប់គ្រងប្រាក់"។

ជាមួយបំណិន និងចំណេះដឹងដែលសិស្សបានរៀនពីម៉ូឌុលនេះ ពួកគេនឹងអនុវត្ត ហើយអាចចាត់ចែងការសន្សំ ប្រាក់ និងវត្ថុដែលមិនមែនជាប្រាក់ប្រកបដោយប្រសិទ្ធភាព ព្រមទាំងធ្វើការសម្រេចចិត្ត ប្រកបដោយភាពឈ្លាសវៃ ហើយប្រកបដោយការទទួលខុសត្រូវចំពោះការចំណាយប្រាក់របស់ពួកគេ។

## ១. វត្ថុបំណងរួម

បំណិនជីវិត គឺជាបំណិនបញ្ញា បុគ្គលិកលក្ខណៈ អន្តរបុគ្គល និងវិជ្ជាជីវៈដែលអាចជួយក្នុងការធ្វើសេចក្តីសម្រេចចិត្ត ការធ្វើទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព អាចដោះស្រាយបាន និងគ្រប់គ្រងខ្លួនឯងបាន។ គឺជាបំណិនដែលរួមចំណែក ក្នុងការលើកស្ទួយសុខុមាលភាព និងជីវភាពប្រកបដោយផលិតភាព។ *(គោលនយោបាយបំណិនជីវិត ២០០៦)* ក្រោយពេលរៀនចប់សិស្សទាំងអស់មានសមត្ថភាព៖

សិស្សនឹងទទួលបានបំណិន និងចំណេះដឹងអំពីការសន្សំ និងការចំណាយដោយ ៖

- ការប្រើប្រាស់យុទ្ធសាស្ត្រសន្សំសំចៃ និងកត់ត្រាការសន្សំ និងការចំណាយក្នុងសៀវភៅសន្សំ
- ធ្វើការអង្កេតប្រព័ន្ធធនាគារតាមរយៈកម្មសិក្សា និងការត្រិះរិះយ៉ាងស៊ីជម្រៅអំពីគុណវិបត្តិនិងគុណប្រយោជន៍
- បង្កើតការសាកសួរអំពីទម្លាប់សន្សំ និងចំណាយ ក្រោមការតាមដានរបស់សិស្ស ព្រមទាំងធ្វើការវិភាគលទ្ធផល
- ប្រាប់សិស្សដទៃទៀតអំពីមធ្យោបាយខុសៗគ្នាក្នុងការសន្សំលុយ និងវត្ថុមានតម្លៃដែលមិនមែនជាលុយ
- អនុវត្តន៍តាមរយៈការសម្តែង និងករណីសិក្សា

## ២. ការត្រៀមលក្ខណៈមុនពេលបង្រៀន

ម៉ូឌុលនេះចែកចេញជាច្រើនផ្នែកផ្សេងៗគ្នា ហើយមានគោលបំណងខុសៗគ្នា។ ការត្រៀមលក្ខណៈមុនពេលបង្រៀនសិស្ស ជាដំណាក់កាលត្រៀមរបស់គ្រូ។ ព័ត៌មានទាក់ទងនឹងការបង្រៀន និងរៀន ពិសេសមេរៀន ត្រូវបានគ្រូត្រៀមទុកជាមុន។

### ● សម្ភារឧបទេស

ផ្នែកនេះផ្តល់នូវសេចក្តីសង្ខេបពីសម្ភារឧបទេស។ ភាគច្រើនជាសម្ភារៈមូលដ្ឋាន ដូចជា ប៊ិច ឬក្រដាស។ សម្ភារៈផ្សេងទៀតនៅក្នុងមេរៀននេះនឹងត្រូវផ្តល់ឱ្យសិស្សសម្រាប់អនុវត្ត តាមរយៈឯកសារសម្រាប់សិស្ស ដែលបានភ្ជាប់នៅក្នុងម៉ូឌុលនេះ។ ពេលខ្លះវាមានការជាន់គ្នាផងដែរ។

### ● លទ្ធផលរំពឹងទុក

ផ្តល់នូវឃ្លាបញ្ជាក់ពីអ្វីនឹងត្រូវសម្រេចបាន និងវាយតម្លៃនៅខាងចុងមេរៀន។ ឃ្លាទាំងនេះទាក់ទង នឹង គោលដៅរួមរបស់បំណិនជីវិត ដែលបានកំណត់នៅក្នុងគោលការណ៍ណែនាំបំណិនជីវិតនៅមធ្យមសិក្សាបឋមភូមិ ។

### ● សញ្ញាសម្គាល់សម្រាប់សកម្មភាពនីមួយ។

ខាងក្រោមនេះ ជាសញ្ញាសម្គាល់សកម្មភាពងាយៗដើម្បីឱ្យគ្រូអនុវត្តបានជោគជ័យក្នុងការបង្រៀន និងរៀន។

ធ្វើសកម្មភាព ៖ គ្រូចាំបាច់ត្រូវធ្វើសកម្មភាពផ្ទាល់ខ្លួន

សរសេរ ៖ ពេលខ្លះត្រូវការឱ្យសរសេរនៅលើក្តារខៀន

សួរ ៖ មានសំណួរដែលត្រូវសួរទៅកាន់សិស្ស

ពន្យល់ ៖ ពន្យល់ចំណុចសំខាន់ៗ ឬប្រាប់សិស្សនៅក្នុងថ្នាក់

● **លំនាំបង្រៀន**

មេរៀននីមួយៗចែកជា ៣ផ្នែក។ ផ្នែកទី១ គឺជាសេចក្ដីផ្ដើមដែលយើងព្យាយាមផ្សារភ្ជាប់ទៅនឹងចំណេះដឹងដែលសិស្សមានស្រាប់ ឬរំលឹកមេរៀនចាស់។ ផ្នែកទី២ យើងនឹងបង្រៀនសកម្មភាពសំខាន់ៗ ដោយផ្អែកលើវិធីសាស្ត្របង្រៀនបែបការងារគម្រោង(ចុះស្រាវជ្រាវ ប្រមូលព័ត៌មានសម្ភាស ចងក្រងឯកសារ និងបទបង្ហាញ...) និងយុទ្ធវិធីបង្រៀនផ្សេងៗទៀត។ នៅផ្នែកទី៣ ដែលជាផ្នែកបញ្ចប់ យើងអាចធានាបានថា រាល់លទ្ធផលនៃការសិក្សារបស់យើង គឺបានឆ្លងកាត់នូវយុទ្ធវិធីខុសៗគ្នាជាច្រើន។

## ៣. ខ្លឹមសារសង្ខេប

មេរៀនសង្ខេបត្រូវបានផ្ដល់ជូនឱ្យគ្រូក្នុងផ្នែកនេះ ដើម្បីជាទុនខ្លះក្នុងការបង្រៀន ហើយក៏ជាសញ្ញាណមួយជាក់លាក់បញ្ជាក់ពីទំនាក់ទំនង និងសារៈសំខាន់រវាងមេរៀននីមួយៗ ។

ខាងក្រោមនេះ គឺជាសេចក្ដីសង្ខេបរួមទាំង ១០ មេរៀន ៖

| ចំណងជើងមេរៀន | រយៈពេល | វត្ថុបំណង | ទំព័រ |
|---|---|---|---|
| ១. តម្រូវការ និងចំណង់ | ១ ម៉ោង ៣០នាទី | នៅក្នុងមេរៀននេះ សិស្សរៀនអំពីភាពខុសប្លែកគ្នារវាង "តម្រូវការ" និង "ចំណង់"។ សិស្សស្គាល់ និងផ្ដល់អាទិភាព ដល់តម្រូវការនិងចំណង់របស់ពួកគេ ព្រមទាំងបញ្ហាប្រឈម ផ្សេងៗដើម្បីទទួលបាន របស់ទាំងនោះ។ | ១ |
| ២. ការសន្សំប្រាក់ | ១ ម៉ោង ៣០នាទី | យើងនឹងពិចារណាអំពីវត្ថុខុសៗគ្នាដែលយើងអាចសន្សំ និងផ្ដោតលើការសន្សំវត្ថុដែលមិនមែនជាលុយ។ បន្ទាប់ ពីនេះមក យើងនឹងសិក្សាអំពីមធ្យោបាយខុសៗគ្នាក្នុងការសន្សំ និងធ្វើការកំណត់នូវសារៈសំខាន់ៗមួយចំនួន ស្ដីអំពីការសន្សំ។ | ៩ |
| ៣. សុវត្ថិភាព | ១ ម៉ោង ៣០នាទី | បញ្ហាចម្បងគឺសារៈសំខាន់នៃការសន្សំ។ ហេតុអ្វីយើងត្រូវ សន្សំ? ស្ថានភាពណាមួយអាចកើតឡើងដែលទាមទារ ឱ្យមានការសន្សំ? សិស្សនឹងបង្កើតប្រព័ន្ធសន្សំ សម្រាប់អ្វីដែលពួកគេចង់សន្សំ។ | ១៤ |
| ៤. ការរៀបចំ | ១ ម៉ោង ៣០នាទី | ក្នុងសប្ដាហ៍នេះ យើងនឹងរៀនអំពីសៀវភៅសន្សំសម្រាប់ កត់ត្រាការសន្សំ និងការចំណាយរបស់ខ្លួន។ សិស្សនឹង បង្កើតនូវកំណែថ្មីសាមញ្ញមួយ ហើយនឹងរៀនពីរបៀបប្រើប្រាស់វា។ សិស្សក៏នឹងធ្វើទស្សនកិច្ចសិក្សាទៅកាន់ធនាគារ។ | ១៨ |
| ៥. ការទៅធនាគារ | ១ ម៉ោង ៣០នាទី | តាមរយៈការធ្វើទស្សនកិច្ចសិក្សាទៅកាន់ធនាគារ យើងនឹង រៀនពីរបៀប ធ្វើការរបស់ធនាគារ។ យើងនឹងកត់សម្គាល់ កិច្ចការនិងទម្លាប់ខុសៗគ្នា ហើយនិងអង្កេតអំពីផលប្រយោជន៍នៃការសន្សំលុយ នៅក្នុងធនាគារ។ | ២៣ |
| ៦. ធនាគារ | ១ ម៉ោង ៣០នាទី | យើងនឹងរំលឹកពីចំណេះដឹងដែលទទួលបានពីការធ្វើ ទស្សនកិច្ចសិក្សាទៅកាន់ធនាគារ ហើយនិងប្រើប្រាស់វា ដើម្បីបង្កើតជាជំនួញមួយ អំពីផលប្រយោជន៍របស់ធនាគារ។ សិស្សនឹងធ្វើបទបង្ហាញអំពីជំនួញរបស់ពួកគេ។ | ២៨ |

| | | | |
|---|---|---|---|
| ៧. អសុវត្ថិភាព | ១ ម៉ោង ៣០នាទី | សិស្សនឹងសិក្សាពីភាពខុសប្លែកគ្នារបស់រូបិយវត្ថុ ភាពខុសគ្នារវាង ដុល្លារ និងលុយរៀលដែលនឹងត្រូវបានពន្យល់។ សេចក្តីសង្ខេបជារួមអំពីភាពខុសប្លែកគ្នារបស់ប្រព័ន្ធសន្សំនៅក្នុងប្រទេសកម្ពុជា។ យើងនឹងកត់ត្រានូវគុណវិបត្តិ និងគុណសម្បត្តិរបស់វា។ | ៣១ |
| ៨. សង្កេត | ១ ម៉ោង ៣០នាទី | យើងនឹងបង្កើតជាកម្រងសំណួរដែលអាចប្រើប្រាស់សើុបសួរពីទម្លាប់ក្នុងការសន្សំនិងការចំណាយ។ កម្រងសំណួរ នេះជាប្រភេទសំណួរបិទ និង សំណួរបើក។ សិស្ស នឹង សើុបសួរពីទម្លាប់ក្នុងការសន្សំ និងការចំណាយ របស់មិត្ត ភ័ក្តិក្នុងថ្នាក់ខុសគ្នាតែមានវ័យប្រហែលគ្នា។ | ៣៥ |
| ៩. បទបង្ហាញ | ១ ម៉ោង ៣០នាទី | ក្រុមទាំងអស់នឹងធ្វើបទបង្ហាញពីលទ្ធផលរបស់ពួកគេ ចំពោះថ្នាក់ខុសគ្នា។ ពួកគេនឹងបង្ហាញសេចក្តីសង្ខេប លទ្ធផល ហើយនិងការវិភាគរបស់ពួកគេ។ ចុងបញ្ចប់ ពួកគេនឹងផ្តល់ដំបូន្មានចំពោះទម្លាប់នៃការសន្សំ និងការ ចំណាយ ទៅកាន់មិត្តរួមថ្នាក់។ | ៣៩ |
| ១០. ការសន្សំ | ១ ម៉ោង ៣០នាទី | យើងនឹងរំលឹកការសន្សំដែលត្រូវបានចាប់ផ្តើមនៅក្នុង សប្តាហ៍ទី២ ព្រមទាំងធ្វើការវាយតម្លៃកិច្ចខំប្រឹងប្រែងរបស់យើង។ សិស្សនឹងចែករំលែក បទពិសោធន៍ ការពេញចិត្ត និងមតិយោបល់ចំពោះការខំប្រឹងប្រែងរបស់ពួកគេផ្ទាល់។ នេះនឹងមានការវាយតម្លៃ ហើយចុងបញ្ចប់ គឺជារង្វាន់ សម្រាប់ការខិតខំរបស់ពួកគេ។ | ៤៦ |

## ៤. ការវាយតម្លៃ

ការវាយតម្លៃមាន២ផ្នែកសំខាន់ៗ។ មួយផ្នែកជាការវាយតម្លៃនៅចុងបញ្ចប់នៃម៉ូឌុលនីមួយៗ និងជាវិញ្ញាសាសរសេរ ដែលយើងត្រូវបញ្ចូលនៅផ្នែកខាងចុងម៉ូឌុល ។ ផ្នែកមួយទៀត ជាការវាយតម្លៃទៅលើឥរិយាបថសិស្ស ដោយគ្រូជាអ្នកសង្កេតផ្ទាល់រៀងរាល់ថ្ងៃ ហើយដាក់ពិន្ទុ។ វិធីវាយតម្លៃទាំងពីរចំណុចនេះមានសារៈសំខាន់ក្នុងការវាស់ចំណេះដឹង និងឥរិយាបថរបស់សិស្សម្នាក់ៗ ។ ចំពោះការវាយតម្លៃសិស្សនេះ យើងគិតពិន្ទុ ៥០ ស្មើទៅនឹងមុខវិជ្ជាមួយចំនួន ផងដែរ គឺយើងឱ្យពិន្ទុ ៣៥ ទៅលើឥរិយាបថ និងពិន្ទុ ១៥ ទៅលើវិញ្ញាសាសរសេរ។

នៅតាមមេរៀននីមួយៗ គ្រូទុកពេលឱ្យសិស្សពិភាក្សាក្រុមតូចឱ្យបានច្រើន នៃចំណុចសំខាន់ៗនៅពាក់កណ្តាលមេរៀននីមួយៗ។ កំឡុងពេលសិស្សពិភាក្សាក្រុមតូច ជាពេលវេលាដែលគ្រូអាចសង្កេតឥរិយាបថសិស្សក្នុងការដាក់ពិន្ទុ។

ជាការល្អគ្រូគួរដាក់ពិន្ទុឥរិយាបងសិស្សចាប់ពីមេរៀនទី ៦ តទៅ។

## ៥. ឯកសារបន្ថែម

ផ្នែកនេះផ្តល់នូវព័ត៌មានរួមសម្រាប់គ្រូប្រើប្រាស់ រួមទាំងផ្ទាំងរូបភាពសម្រាប់គ្រូប្រើប្រាស់នៅក្នុងមេរៀននេះ។

# មេរៀនទី ១: តម្រូវការ និងចំណង់

🕑 រយៈពេលបង្រៀនៈ ១ ម៉ោង ៣០ នាទី

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និង សំណួរ សម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរសិក្សាលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ។
- រៀបចំបន្ទប់រៀន (តុ កៅអី ក្តារខៀន...)

📖 សម្ភារឧបទេស/ធនធានដែលត្រូវការ

- បាល់មួយ
- ហ្វឺត ឬ ដីស
- ខ្មៅដៃ ក្រដាសស

☼ វត្ថុបំណងៈ

នៅពេលរៀនមេរៀននេះចប់សិស្សទាំងអស់អាច ៖

- យល់ច្បាស់ពីភាពខុសគ្នារវាងតម្រូវការ និងចំណង់
- ផ្តល់អាទិភាពដល់តម្រូវការ និងចំណង់របស់ពួកគេ

**ចំណងជើងមេរៀនទី ១: តម្រូវការ និង ចំណង់** 🕑 ៣០ នាទី

**សេចក្តីផ្តើម**

ឱ្យសិស្សទាំងអស់ឈរជារង្វង់នៅក្នុងថ្នាក់ អ្នកត្រូវបោះបាល់ទៅអ្នកផ្សេងទៀត។ នៅពេលដែលគេចាប់បាល់បាន អ្នកត្រូវនិយាយពាក្យមួយចេញពីចិត្តរបស់អ្នក។

ធ្វើរបៀបនេះចំនួនពីរ ឬ បីនាទី។ នៅពេលចាប់ផ្តើមបង្រៀន ត្រូវឱ្យពាក្យដែលទាក់ទងនឹង តម្រូវការ។

ឧទាហរណ៍ ៖ សំលៀកបំពាក់ អាហារ ផ្ទះ

✎ សរសេរពាក្យដែលសិស្សបាននិយាយ *ឬក៏ឱ្យសិស្សសរសេរនៅលើក្តារខៀន*

ឧទាហរណ៍ ៖



អ្វីដែលអ្នកបាននិយាយ គេហៅថា *តម្រូវការ*។ ពួកវាមានភាពចាំបាច់សម្រាប់ការរស់នៅ ការអភិវឌ្ឍ និងការការពារខ្លួនយើង។ សម្ភារៈផ្សេងៗទៀតដែលមិនមែនជាតម្រូវការ ប៉ុន្តែពួកវាល្អ ហើយយើងចង់បានដែរនោះ គេហៅថា *ចំណង់*។

ឱ្យប័ណ្ណមួយពីឯកសារសម្រាប់សិស្ស ១ក ទៅសិស្សទាំងអស់ ហើយសរសេរពាក្យ *តម្រូវការ ចំណង់* និង *មិនបានសម្រេចចិត្ត* នៅលើក្រដាសមួយ។

សិស្សម្នាក់លើកក្រដាសជាមួយពាក្យ "តម្រូវការ" ម្នាក់ទៀតលើកពាក្យ "ចំណង់" ហើយសិស្ស ទី៣លើកពាក្យ "មិនបានសម្រេចចិត្ត"។ បែងចែករូបភាពដែលអ្នកមាន និង ឈរពីមុខមនុស្ស ដែលត្រឹមត្រូវ។

បន្ទាប់ពីគ្រប់គ្នាបានជ្រើសរើសផ្នែកសម្រាប់រូបភាពរបស់ពួកគេ សួរពួកគេមួយចំនួន ៖
*ហេតុអ្វីបានជាអ្នកជ្រើសរើសផ្នែកនេះ?*
សិស្សសរសេរចម្លើយដែលមានប្រយោជន៍នៅលើក្ដារខៀន។
បន្ទាប់ពីនេះធ្វើការពន្យល់ម្ដងទៀត៖ *ចំណង់* គឺជាអ្វីដែលអ្នកចូលចិត្ត ឬចង់បាន ប៉ុន្តែវាមិនមានភាពចាំបាច់សម្រាប់ការរស់នៅ ការអភិវឌ្ឍ ការចូលរួម និងការការពារឡើយ។

*តម្រូវការ* គឺជាអ្វីដែលចាំបាច់ សម្រាប់យើងរស់នៅក្នុងភាពថ្លៃថ្នូរ។ វាជាសិទ្ធិរបស់យើងដែល ត្រូវមានវាទោះបីជាគ្មានអ្វីធានាអះអាងថា យើងនឹងជួបវាបានគ្រប់ពេលវេលាក៏ដោយ។
តើអ្នករាល់គ្នាគិតថារូបភាពរបស់គាត់ត្រូវធ្វើការផ្លាស់ប្តូរទៅកាន់ផ្នែកផ្សេងទៀត ឬទេ?
ប្រសិនបើគ្មាននោះទេ សិស្សទាំងអស់អាចត្រឡប់ទៅកាន់កន្លែងអង្គុយវិញ។

## សកម្មភាពសំខាន់

៤០ នាទី

ពិភាក្សា ៖ តើអ្វីជាឧបសគ្គរារាំងក្នុងការបំពេញតម្រូវការរបស់អ្នក?
តើអ្នកអាចធ្វើអ្វីដើម្បីធានាថាអ្នកនឹងបំពេញបានតម្រូវការរបស់អ្នក?
តើអ្នកអាចចូលរួមក្នុងការបំពេញតម្រូវការរបស់អ្នកផ្ទាល់ដោយរបៀបណា?

នេះទាក់ទងនឹងសិទ្ធិកុមារ មិនមែនសិទ្ធិទាំងអស់ត្រូវបានបំពេញនោះទេ ផ្នែកខ្លះនៅតែស្ថិតក្នុងដំណើរការ។ កុមារត្រូវតែធ្វើការជាមួយមនុស្សពេញវ័យ ដើម្បីធានាថា ពួកគេនឹងរីករាយជាមួយសិទ្ធិរបស់ពួកគេ។ តម្រូវការភាគច្រើនគួរតែត្រូវបានផ្តល់ដោយរដ្ឋាភិបាល ដូចជាការអប់រំ ការថែទាំសុខភាព ការពារពីការជួញដូរ។

គ្រូឱ្យប័ណ្ណមួយសន្លឹក អំពីឯកសារ ១ខ ទៅសិស្សទាំងអស់។  ប័ណ្ណនីមួយៗដែលអ្នកមាន អ្នកអាចពិភាក្សានៅក្នុងក្រុមរបស់អ្នកថា តើអ្វីនឹងកើតឡើងប្រសិនបើកុមារក្នុងករណី សិក្សាជ្រើសរើសផ្តល់អាទិភាពដល់ចំណង់របស់គេ?
ចូរពិចារណាពីផល វិបាករបស់វា?

ក្រោយពីការពិភាក្សា អ្នកអាចឱ្យសិស្សប្រាប់ពីករណីសិក្សា និងផលវិបាករបស់ពួកគេដែលបានពិចារណា។ បង្រៀនសិស្សថា ប្រសិនអ្នកផ្តល់អាទិភាពចំណង់ឱ្យខ្ពស់ជាងតម្រូវការ វាអាចមានផលវិបាកអវិជ្ជមានចំពោះអ្នក និងគ្រួសាររបស់អ្នក។ ពេលខ្លះ វាល្អដែលយើងបំពេញចិត្តរបស់យើង ប៉ុន្តែលុះត្រាតែអ្នកមានប្រាក់បន្ថែមសម្រាប់ការចំណាយនេះ។ ប្រសិនបើគ្មាន យើងគួរតែរង់ចាំ និងសន្សំប្រាក់សម្រាប់តម្រូវការចាំបាច់ នាពេលអនាគតវិញប្រសើរជាង។

**បញ្ចប់មេរៀន** ⌚ ២០ នាទី

សិស្សទាំងអស់គូររូបខ្លួនឯង នៅចំកណ្តាលក្រដាស ដែលខ្ញុំបានឱ្យ។ ហើយខ្ញុំចង់ឱ្យអ្នកគិតពីតម្រូវការ និង ចំណង់របស់អ្នក។ នៅផ្នែកម្ខាងនៃក្រដាសគូរពីតម្រូវការ ហើយនៅម្ខាងទៀតគូរពីចំណង់។ ប៉ុន្តែអ្នក ត្រូវគិតពីអាទិភាព។ អ្វីដែលអ្នកចង់បាន និងត្រូវការខ្លាំងបំផុតដែលនៅជិតអ្នក និងអ្វីដែលអ្នកមិនសូវចង់បាន ឬមិនសូវមានតម្រូវការដែលឆ្ងាយបន្តិចពីខ្លួនរបស់អ្នក។

ខណៈពេលដែលអ្នកកំពុងដើរមើល អ្នកអាចសួរសិស្សអំពីការជ្រើសរើសរបស់ពួកគេ ឬទុកឱ្យពួកគេពន្យល់ទៅកាន់មិត្តរួមថ្នាក់ ប្រសិនជាគេចង់។ ត្រូវធានាថា ពួកគេយល់ពីភាព ខុសគ្នារវាង *តម្រូវការ* និង *ចំណង់* ហើយអាទិភាពទាំងនោះអាចខុសគ្នាទៅតាមបំណងរបស់ មនុស្សម្នាក់ៗ។ អាទិភាពទាំងនោះ គឺមិនចាំបាច់ដូចគ្នានោះទេ។

បិទគំនូររបស់សិស្សនៅលើជញ្ជាំងនៃថ្នាក់រៀន។

## សេចក្តីណែនាំគ្រូ

- ប្រសិនបើអ្នកមានផ្ទាំងរូបភាព ដែលស្តីអំពីសិទ្ធិកុមារនៅក្នុងសាលារបស់អ្នក អ្នកអាចប្រើវាបានក្នុងការពិភាក្សា។ វាក៏ជាឱកាសដ៏ល្អមួយដើម្បីពិនិត្យថា កុមារ នៅតែដឹងពីសិទ្ធិផ្សេងៗទៀតរបស់ពួកគេដែរ។
- ការពិភាក្សាជាឧបករណ៍សិក្សាដ៏មានថាមពលមួយ។ វាជាការចាំបាច់ដែលសិស្សទាំងអស់ត្រូវចូលរួម។ នេះអាចមានការពិបាក។ អ្នកអាចបំផុសសំណួរដោយ សួរថា "តើអ្នកគិតយ៉ាងដូម្តេចអំពីកិច្ចការនេះ ?" ឬ "តើអ្នកគិតថាវាដូចគ្នាទៅ នឹងអ្វីដែលគេបាននិយាយឬទេ ?"



សាលារៀន



ការការពារពី
ការរំលោភបំពាន
ឬ ការប្រមាថ



ការថែរក្សាជំងឺពីគ្រូពេទ្យ



សិទ្ធិសម្រាប់ការពារពី
ការរើសអើង



អាហារូបត្ថម្ភ



ការបញ្ចេញមតិយោបល់



កន្លែងកំសាន្ត និងការកំសាន្តសប្បាយ



ទឹកស្អាត



វត្តអារាម



មិត្តភក្តិ



សេរីភាពដើម្បីប្រតិបត្តិវប្បធម៌របស់ខ្ញុំផ្ទាល់



ការងារ



កុំព្យូទ័រផ្ទាល់ខ្លួន



ទូរទស្សន៍



អាហារឆ្ងាញ់ៗ



បន្ទប់គេងផ្ទាល់ខ្លួន



លុយជាច្រើន



ទូរស័ព្ទថ្មី



ស្ករគ្រាប់ និង នំស្រួយ



សំលៀកបំពាក់
និង
ម៉ូដនិយមថ្មី



ឡានថ្មី



ម៉ូតូថ្មី



គ្រឿងអលង្ការ



សម្រាកពេញមួយថ្ងៃ

១. បូរីទទួលបានលុយពីរ ឬ បី រយរៀលពីម្តាយរបស់គាត់ នៅពេលគាត់ទៅសាលារៀន ។ លុយទាំងនោះគឺទុកសម្រាប់ទិញអាហារញុាំ ។ ផ្ទុយទៅវិញ បូរី "ចូលចិត្តផ្អែម" ដូច្នេះគាត់ចូលចិត្តទិញស្ករគ្រាប់ជំនួសអាហារថ្ងៃត្រង់



របស់គាត់ ។ អស់រយៈពេលជាច្រើនឆ្នាំមកហើយ គាត់តែងតែទិញចំណីកំប៉ិចកំប៉ុក ហើយរំលងអាហារថ្ងៃត្រង់ ពីព្រោះថា ចំណីកំប៉ិចកំប៉ុកមានតម្លៃថោក ។

២. សារុតបានយកលុយពីម្តាយរបស់នាងដើម្បីទៅទិញសៀវភៅ ។ នៅតាមផ្លូវទៅកាន់ហាងលក់សៀវភៅ នាងឃើញស្បែកជើងមួយគូដ៏ស្រស់ស្អាត ។ នាងប្រាប់ខ្លួនឯងថា: ខ្ញុំត្រូវការទិញស្បែកជើងនោះមុនពេលដែលអ្នកដទៃទិញវាមុនខ្ញុំ ។ ស្បែកជើងនោះមើលទៅស្រស់ស្អាតពេលខ្ញុំពាក់វា ។ ប្រសិនបើខ្វះលុយ ខ្ញុំក៏អាចខ្ចីលុយពីមិត្តភ័ក្តិរបស់ខ្ញុំ ។





៣. ចិន្តាបានទទួលលុយពីមីងរបស់គាត់នៅថ្ងៃខួបកំណើតរបស់គាត់ ។ លុយទាំងនោះគឺគ្រប់គ្រាន់ដើម្បីធ្វើកម្មវិធីជប់លៀងជាមួយមិត្តភ័ក្តិរបស់គាត់ ។ មិត្តភ័ក្តិរបស់គាត់បានសុំអោយគាត់ប៉ាវពួកគេទៅញុាំអាហារនៅថ្ងៃខួបកំណើតរបស់គាត់ ។ ទោះបីជាយ៉ាងណា ម្តាយរបស់គាត់ត្រូវការលុយមួយចំនួនសម្រាប់រកស៊ី ។ គាត់បានប្រាប់ចិន្តាថា គាត់ត្រូវការខ្ចី និងសងវិញ នៅពេលដែលគាត់បានចំណេញពីការរកស៊ី ។

៤. ទេព រកលុយបានគ្រប់គ្រាន់ដើម្បីទិញស្បែកជើងមួយគូសម្រាប់ខ្លួនឯង ។ បាតរបស់ស្បែកជើងនោះបានរបើក។ ទោះបីជាយ៉ាងណា មុនពេលគាត់អាចទិញស្បែកជើងនោះ គាត់ក៏មានជំងឺ។



ឪពុកម្តាយរបស់គាត់មិនមានលុយដើម្បីនាំគាត់ទៅកាន់មន្ទីរពេទ្យទេ។ ទេព គិតថា ប្រសិនបើគាត់សំរាកបានស្រួល គាត់នឹងជាសះស្បើយ។

គាត់និយាយទៀតថា គាត់មិនត្រូវការទៅជួបគ្រូពេទ្យទេ ។ ស្បែកជើង គឺមានសារៈសំខាន់ណាស់ចំពោះគាត់ ព្រោះស្បែកជើងគាត់ចាស់ហើយ ។

៥. ញែក រកលុយបានដោយសារការលក់នំបញ្ចុក ។ នាងតាំងចិត្តទិញសំលៀកបំពាក់ឯកសណ្ឋានសិស្សថ្មីមួយ



សម្រាប់និងសំលៀកបំពាក់ផ្សេងទៀត ។ នាងត្រូវការទិញសំលៀកបំពាក់ឯកសណ្ឋានសិស្សថ្មី ព្រោះថា ឯកសណ្ឋានចាស់ចង្អៀត ។ នាងបានសន្សំលុយគ្រប់គ្រាន់ទុកសម្រាប់ទិញសំលៀកបំពាក់ថ្មីពីរឈុត ប៉ុន្តែនាងចង់ទិញសំលៀកបំពាក់មួយទៀតទុកសម្រាប់ពាក់ពេលនាងទៅដើរលេងជាមួយមិត្តភ័ក្តិ ។

# មេរៀនទី ២: ការសន្សំប្រាក់

🕑 រយៈពេលបង្រៀន: ១ ម៉ោង ៣០ នាទី

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន
- សំណួរ សម្រាប់សកម្មភាពត្រូវ នឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរសិក្សាលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ។
- ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)

📖 សម្ភារឧបទេស/ធនធានដែលត្រូវការ

១. ដីស ក្ដារខៀន

២. ឯកសារសម្រាប់សិស្ស ២ក

៣. ក្រដាស

☼ វត្ថុបំណង:

នៅពេលរៀនមេរៀននេះចប់សិស្សទាំងអស់អាច ៖

- ចេះសន្សំសំចៃបង្ការទុកជាមុន
- ដឹងថាហេតុអ្វីការរំលឹកពីអនុស្សាវរីយ៍សប្បាយៗមានសារៈសំខាន់ក្នុងការអភិវឌ្ឍខ្លួន
- បែកចែកវត្ថុមិនមែនជាលុយដែលអាចសន្សំបាន និងដឹងពីសារៈសំខាន់របស់វា
- ចងចាំវិធី/ក្បួនដែលអាចធ្វើឱ្យការសន្សំទទួលបានជោគជ័យ

**ចំណងជើងមេរៀនទី ២: ការសន្សំប្រាក់** 🕑 ១០ នាទី

**សេចក្ដីផ្ដើម**

ឱ្យសិស្សទាំងអស់មកក្នុងបន្ទប់រៀន ហើយប្រាប់ពួកគេថា អ្នកចង់ឱ្យពួកគេគិតពីអនុស្សាវរីយ៍ របស់ពួកគេ។ យើងនឹងលេងល្បែងរូបចម្លាក់។ សិស្សដើរកាត់បន្ទប់ដោយស្ងាត់ស្ងៀម ហើយរំពេចនោះអ្នកនឹងស្រែកថា "សប្បាយ" "សោកសៅ" "ភ្ញាក់ផ្អើល" "ខឹង"។ សិស្សត្រូវធ្វើជារូបចម្លាក់មួយ ដោយពណ៌នាពីអារម្មណ៍ ដែលទាក់ទងទៅនឹងអ្វីដែលបានកើតឡើងក្នុងជីវិតរបស់ពួកគេ។

បង្ហាញឧទាហរណ៍៖ ស្រែក "សោកសៅ" ហើយធ្វើមុខក្រៀមក្រំ ខណៈពេលដែលកំពុងកាន់រូបកង់ប្រឌិតមួយ។ សួរសិស្សថា តើពួកគេគិតថាអ្វីបានកើតឡើង? (បែកកង់ពេលដែលអ្នកកំពុងប្រញាប់ទៅសាលារៀន)។

លេងល្បែងកំសាន្តនេះជាច្រើនដង និងសួរសិស្សមួយចំនួនថា តើពួកគេកំពុងបង្ហាញពីអ្វី?

តើអ្នកកំពុងបង្ហាញពីអ្វីដល់យើង? តើអ្វីបានកើតឡើង?

តើអ្នកខឹង/សប្បាយ? ហេតុអ្វី?

១០ នាទីបន្ទាប់ បញ្ឈប់ល្បែងកំសាន្ត ហើយសួរសិស្ស៖

តើអ្នកមានអារម្មណ៍បែបណា នៅពេលដែលអ្នកចងចាំ នូវអនុស្សាវរីយ៍សប្បាយរីករាយក្នុងជីវិតរបស់អ្នក?

តើអ្នកមានអារម្មណ៍បែបណានៅពេល ដែលអ្នកចងចាំនូវបទពិសោធសោកសៅ?

តើមួយណាដែលអ្នកគិតថា មានប្រយោជន៍សម្រាប់អ្នក ចងចាំនូវបទពិសោធសោកសៅ ឬបទពិសោធន៍រីករាយ?

តើការចងចាំអនុស្សាវរីយ៍សប្បាយរីករាយជួយអ្នកដោយរបៀបណា?

ប្រាប់សារៈសំខាន់ខាងក្រោមទៅកាន់សិស្ស ៖

- ការចងចាំអនុស្សាវរីយ៍សប្បាយរីករាយមានសារប្រយោជន៍ជាង ការចងចាំនូវបទពិសោធសោកសៅ។ អនុស្សាវរីយ៍សប្បាយរីករាយធ្វើឱ្យជីវិតរបស់យើងមានក្ដីសង្ឃឹម និងភាពអំណត់កាន់តែច្រើន។
- ការអាស្រ័យលើបទពិសោធអវិជ្ជមានរារាំងយើងមិនឱ្យឆ្ពោះទៅមុខ។ វាក៏អាចធ្វើឱ្យ អន្តរាយដល់ការតស៊ូរបស់យើង ឬក៏សមត្ថភាពរបស់យើង ដើម្បីជំនះបទពិសោធន៍ អវិជ្ជមាន និងដើម្បីសម្លឹងទៅរកអនាគតដ៏ភ្លឺស្វាង។
- ប៉ុន្តែ បទពិសោធអវិជ្ជមានមិនមែនសុទ្ធតែអាក្រក់ទាំងស្រុងនោះទេ។ ជួនកាល បទពិសោធអវិជ្ជមានផ្ដល់តម្លៃវិជ្ជមាន និងមេរៀនដ៏ល្អអាចធ្វើឱ្យយើងរឹងមាំផងដែរ។
- វាមានការពិបាក ពេលខ្លះមិនអាចបំភ្លេចបទពិសោធអវិជ្ជមានបាន។ មធ្យោបាយមួយ ដើម្បីចងចាំបទពិសោធវិជ្ជមានគឺត្រូវរក្សាទុកវត្ថុអនុស្សាវរីយ៍នៃព្រឹត្តិការណ៍រីករាយក្នុងជីវិតរបស់អ្នក។ ជាធម្មតាវត្ថុទាំងអស់នោះជួយយើងចងចាំនូវរឿងអតីតកាល។

⟐ តើអ្នកបានចងចាំ ពីព្រឹត្តិការណ៍រីករាយដែលបានកើតឡើងចំពោះអ្នកដែរឬទេ?

វាអាចជារូបភាព កាដូ គ្រឿងអលង្ការសម្លៀកបំពាក់ថ្មីៗ។ល។ គ្រូក៏អាចឱ្យឧទាហរណ៍ពីវត្ថុដែលរំលឹកសិស្សពីព្រឹត្តិការណ៍រីករាយផងដែរ។

**សកម្មភាពសំខាន់** ៦៥ នាទី

ឱ្យសិស្សឈរតម្រង់ជាជួរនៅមុខក្ដារខៀន។ សិស្សទាំងអស់ឈរពីក្រោយគ្នា។

សិស្សគ្រប់គ្នាត្រូវសរសេរពាក្យសម្គាល់របស់ទីមួយដែលលេចចេញនៅក្នុងចិត្ត នៅពេលឮពាក្យសន្សំ និងការសន្សំ។

អ្នកត្រូវតែរហ័ស ហើយពេលអ្នកបញ្ចប់ ឱ្យខ្មៅដៃពណ៌ទៅកាន់សិស្សដែលនៅពីក្រោយអ្នក។

⟐ ខណៈពេលដែលគេកំពុងសរសេរ ត្រូវផ្ដល់យោបល់ឱ្យពួកគេគិតឱ្យបានវែងឆ្ងាយ។

ឧទាហរណ៍ ៖ ហេតុអ្វីយើងត្រូវការសន្សំ? តើយើងអាចសន្សំអ្វីបានខ្លះ? តើយើងសន្សំ ដោយ របៀបណា?

✎ ចាត់ចម្លើយជាក្រុមទៅតាមនិយមន័យរបស់ការសន្សំ។ ឱ្យសិស្សជួយ។

នេះអាចមើលទៅស្រដៀងនឹងឧទាហរណ៍ខាងក្រោម ៖

| ផ្លូវការ | មិនផ្លូវការ | មធ្យោបាយសន្សំ | ផ្សេងៗ... |
|---|---|---|---|
| លុយ | អនុស្សាវរីយ៍ | ក្នុងធនាគារ | ប្រើម្តងទៀត |
| មាស | ទំនាក់ទំនង | ទុកនៅឪពុកម្តាយ | |
| | ថ្នាំដុសធ្មេញ | ជាមួយគ្នា | |
| | អាហារ | | |

បន្ទាប់ពីនេះសួរសិស្ស ៖ *តើអ្វីជាសារៈសំខាន់នៃការសន្សំ? តើការសន្សំលុយអាចជួយអ្នកបាន ដោយរបៀបណា? តើការសន្សំវត្ថុផ្សេងៗទៀត (អាហារ សាប៊ូ ...) ដែលប្រហាក់ ប្រហែលនឹងលុយ អាចជួយអ្នកបានដោយរបៀបណា? តើអ្នកនឹងទទួលបានអ្វីប្រសិនបើអ្នកទុករបស់មួយចំនួនដើម្បីប្រើប្រាស់វានៅពេលក្រោយ? តើវត្ថុសំខាន់អ្វីខ្លះដែលអ្នកបានសន្សំពេលកន្លងមក?*

ដូចអ្វីដែលយើងបានរៀន អ្នកអាចសន្សំបានអ្វីផ្សេងទៀតក្រៅពីលុយ។ ការសន្សំរបស់របរ ទាំងនោះមានដូចជា អាហារ សាប៊ូ ស្ករគ្រាប់ ឬសូម្បីតែការប្រព្រឹត្តល្អ ក៏មានតម្លៃដែរ។ ពួកវាអាចរំលឹកអ្នកពីពេលសប្បាយរីករាយ ផ្តល់ឱ្យអ្នកនូវអារម្មណ៍ល្អចំពោះខ្លួនអ្នក ហើយ អាចប្រើវាបាននូវពេលក្រោយ ដើម្បីបំពេញចិត្តខ្លួនឯងជាមួយអាហារបន្ថែម គេសជ្ជៈ ឬពេល សប្បាយរីករាយ។

ថ្ងៃនេះ យើងនឹងអនុវត្តជាមួយការសន្សំប្រាក់ ប៉ុន្តែយើងនឹងគិតអំពីការចំណាយវាទៅលើ តម្រូវការ ឬចំណង់។ តើនរណាដឹងពីភាពខុសគ្នារវាងតម្រូវការ និងចំណង់? រំលឹក *ឡើងវិញពីចំណេះដឹងមេរៀនទី១។*

បែងសម្រាប់សិស្សជាក្រុមដែលមានសមាជិក៦នាក់។ អនុញ្ញាតឱ្យពួកគេជ្រើសរើសករណី សិក្សា ១ ក្នុងចំណោម ៤ ដែលមាននៅក្នុងឯកសារសម្រាប់សិស្ស។ ពួកគេអាចជ្រើសរើសដោយ មិនចាំបាច់ពិចារណាអ្វីនោះទេ។

អ្នកអាចអាន និងពិភាក្សាអំពីករណីសិក្សា។ គោលបំណងដើម្បីសន្សំលុយឱ្យបានច្រើន តាម តែអ្នកអាចធ្វើបាន ឬ យ៉ាងហោចណាស់ក៏ដើម្បីចំណាយលុយប្រកបដោយភាពប្រុងប្រយ័ត្ន ប្រសិនបើការសន្សំមិន អាចទៅរួច។



ដើរជុំវិញដើម្បីពិនិត្យថា សិស្សគ្រប់គ្នាៗចូលរួម។ នេះអាចជាឱកាសល្អដើម្បីបំពេញក្នុងផ្នែកមួយ នៃ *ក្រដាសវាយតម្លៃការសិក្សា របស់សិស្ស។*

ឱ្យសិស្សចែករំលែកលទ្ធផលរបស់ពួកគេ ជាមួយក្រុមដទៃទៀត ហើយសួរពីមូលហេតុ។

*ហេតុអ្វីបានជាអ្នកសម្រេចចិត្តដូច្នេះ?*

*តើអាចមានលទ្ធភាពផ្សេងទៀតទេ?*

**បញ្ចប់មេរៀន** ១៥ នាទី

ប្រាប់សិស្សនូវចំណុចសំខាន់ៗ ខាងក្រោមអំពីការសន្សំ។

១. នៅពេលអ្នកចំណាយលុយ ត្រូវគិតពីតម្រូវការ ឬ ចំណង់របស់អ្នក។

២. រៀនផ្ដល់អាទិភាព។ តើតម្រូវការមួយណាដែលបន្ទាន់ជាង? តើអ្វីដែលមានការទាក់ទង នឹងការរស់នៅរបស់គ្រួសារខ្ញុំជាង? ឧទាហរណ៍៖ អាហារ គឺសំខាន់ជាងទូរស័ព្ទ។

៣. ប្រសិនបើមានជម្រើសដើម្បីទទួលបានរបស់ដោយឥតគិតថ្លៃ ឬមានតម្លៃថោក ជ្រើសរើសរបស់ដោយឥតគិតថ្លៃ ឬមានតម្លៃថោក ជាជាងទិញរបស់ថ្មី។ឧទាហរណ៍ ៖ ប្រសិនបើអ្នកអាចទទួលបានសំលៀកបំពាក់ពីបងបង្កើតរបស់អ្នករើសយករបស់ទាំងនោះជំនួសឱ្យការទិញថ្មី។

៤. ការសន្សំលុយមិនមានន័យថា អ្នកត្រូវតែសន្សំចំនួនច្រើនភ្លាមៗទេ។ អ្នកអាចចាប់ផ្ដើម ដោយការសន្សំពីចំនួនតូចៗដែលអ្នកទទួលបាន ឬ លុយដែលអ្នកចំណេញពី ការរកស៊ី។

៥. កុំប៉ះពាល់លុយសន្សំរបស់អ្នក ប្រសិនបើអ្នកមិនត្រូវការវាចាំបាច់នោះទេ។

៦. កុំបាក់ទឹកចិត្ត នៅពេលដែលអ្នកមិនអាចសន្សំមួយរយៈ។ វានឹងមានឱកាសណាមួយដែលអ្នកអាចសន្សំបាន

៧. ការសន្សំលុយនឹងអនុញ្ញាតឱ្យអ្នកចំណាយសម្រាប់ចំណង់របស់អ្នកក្នុងពេលអនាគត។

៨. មនុស្សគ្រប់គ្នាអាចសន្សំបាន!។

សរសេរសារទាំងនេះលើក្រដាស ហើយដាក់បង្ហាញវានៅលើជញ្ជាំង!

ប្រសិនជានៅសល់ម៉ោង អ្នកអាចលេងល្បែងកំសាន្តខ្លីមួយ សិស្សអាចនិយាយពីអ្វីមួយ ដែលពួកគេចង់សន្សំ។ អាចជារបស់ពិសេសអ្វីមួយ។ សិស្សដទៃទៀតត្រូវទាយថា គេមានអ្វីក្នុងចិត្ត។ ពួកគេអាចសួរសំណួរ ប៉ុន្តែអាចទាយចម្លើយបានតែម្ដងប៉ុណ្ណោះ ដូច្នេះពួកគេត្រូវតែប្រាកដជាមួយចម្លើយ។ សិស្សដែលមានអ្វីនៅក្នុងចិត្តអាចឆ្លើយបានតែ "ទេ" ឬ "បាទ/ចាស"។

ឧទាហរណ៍ ៖ តើអ្នកអាចញ៉ាំវាបានទេ? - ទេ។ តើវាធ្ងន់ទេ? - បាទ/ចាស។ល។

## សេចក្ដីណែនាំគ្រូ

ការពិភាក្សាអំពីករណីក្នុងឯកសារសម្រាប់សិស្ស ២ " ក " មិនគួរកាត់សេចក្ដីដោយចម្លើយខុស ឬត្រូវនោះទេ។ វាមានសារៈសំខាន់ជាង ដែលសិស្សពន្យល់ពីជម្រើសរបស់ពួកគេ និងវិភាគឱ្យ បានស៊ីជម្រៅពីជម្រើសរបស់អ្នកដទៃ។

**ករណីទី១**



គ្រួសារអ្នកបានទទួលលុយចំនួន១០ដុល្លារពីបងប្អូនម្នាក់។នេះជាលុយដែលអ្នកសម្រាប់ប្រើប្រាស់ក្នុងមួយសប្តាហ៍។ ក្នុងចំណោមលុយ១០ដុល្លារ ៣ដុល្លារនឹងត្រូវ ចំណាយបន្ទាន់លើម្ហូបអាហារក្នុងគ្រួសារ។ ប្អូនស្រីរបស់អ្នក ត្រូវការឯកសណ្ឋានសិស្សថ្មី ព្រោះអាវរបស់នាងរហែក ត្រង់ក។ អាវថ្មីមានតម្លៃ៥ដុល្លារ។ ប្អូនប្រុសរបស់អ្នកត្រូវកាត់សក់មានតម្លៃ ២ដុល្លារ ព្រោះសក់របស់គាត់វែងពេក។ អ្នកត្រូវការលុយ ២ដុល្លាសម្រាប់គម្រោងរបស់សាលាដែល ចាំបាច់ត្រូវធ្វើព្រោះអ្នកអាចធ្លាក់ ប្រសិនជាអ្នកមិនធ្វើវា ។ មួយវិញទៀត ឪពុករបស់អ្នកត្រូវការលុយ៣ដុល្លារដើម្បីជួសជុលកង់របស់គាត់ទុកសម្រាប់ជិះទៅធ្វើការ។

**ករណីទី២**



អ្នករកលុយបាន៣ដុល្លារពីការលក់កាសែត។ អ្នកពិតជាឃ្លាន និងស្រេកទឹកជាខ្លាំង។ អ្នកទៅហាងមួយ។ នៅក្នុងហាង អ្នកឃើញថាអាហារបន្លែជាមួយបាយ និងនំបុ័ងបារាំងតម្លៃ១.៧៥ដុល្លារ។ យ៉ាងណាក៏ដោយ អ្នកអាចទិញនំបុ័ងបារាំងបំពងដែលមានបរិមាណដូចគ្នានឹងអាហារបន្លែចំណាយតែ១ដុល្លារ។ អ្នកក៏អាចចំណាយតែ២៥សេនសម្រាប់ទិញស្ករគ្រាប់ដែលអ្នកចូលចិត្តដើម្បីបំពេញចិត្តខ្លួនឯង។ ទឹកសុទ្ធមានតម្លៃ៥០សេន រីឯទឹកសូដាដែលអ្នកចូលចិត្តថ្លៃ៧៥សេន។ មានប្រដាប់ក្មេងលេងមួយដែលអ្នកចង់បានជាយូរមកហើយនោះមានតម្លៃ ១ដុល្លារ។ ប្អូនប្រុសរបស់អ្នកត្រូវការទឹកដោះគោដែលអ្នកអាចទិញវាបានក្នុងតម្លៃ១.២៥ដុល្លារ។ ប៉ុន្តែអ្នកក៏ត្រូវការសន្សំលុយដើម្បីទិញស្បែកជើងថ្មីដែលមានតម្លៃ១៥ដុល្លារ។



**ករណីទី៣**

គ្រួសាររបស់អ្នកមានលុយ១២ដុល្លារ។ អ្នកត្រូវបង់ថ្លៃភ្លើងអស់៦ដុល្លារ។ ប្រសិនបើអ្នកមិនបង់ថ្លៃភ្លើង ក្រុមហ៊ុនអគ្គិសនីនឹងផ្តាច់ភ្លើង។ យ៉ាងណាក៏ដោយម្តាយរបស់អ្នកដែលជាអ្នករកស៊ីចិញ្ចឹមគ្រួសារតែម្នាក់គត់ ហើយគាត់មានជំងឺ។ ការព្យាបាលនៅមណ្ឌលសុខភាពឬមន្ទីរពេទ្យគឺមិនយកលុយទេ តែត្រូវចំណាយលុយទិញថ្នាំ។ អ្នកត្រូវការយ៉ាងតិចបំផុត៤ដុល្លារសម្រាប់ទិញថ្នាំពីឱសថស្ថានដែលមិនមានជំនួយពីរដ្ឋាភិបាល។ ប្អូនប្រុសរបស់អ្នកត្រូវការទឹកដោះគោដែលត្រូវចំណាយ១.២៥ដុល្លារ។ អាហារក្នុងគ្រួសារនឹងត្រូវចំណាយអស់៣ដុល្លារយ៉ាងតិច។ អ្នកត្រូវការលុយ៣ដុល្លារសម្រាប់ដំណើរចុះកម្មសិក្សារបស់សាលាអ្នក។

**ករណីទី៤**

ម្តាយរបស់អ្នកឱ្យលុយ៨ដុល្លារ។ អ្នកត្រូវចំណាយលើការចុះឈ្មោះចូលរៀននៅសាលាឯកជនមួយអស់៣ដុល្លារ។ ឯកសណ្ឋានសិស្សថ្មីថ្លៃ៦ដុល្លារ។ អ្នកត្រូវចំណាយ ៥ដុល្លារសម្រាប់ទិញសៀវភៅ។ មួយវិញទៀត



សម្ភារផ្សេងៗរបស់សាលាមានតម្លៃប្រហែលជា៤ដុល្លារ។ ក្នុងចំនួនលុយ ៨ដុល្លារ អ្នកក៏ត្រូវដឹងថានឹងត្រូវទិញម្ហូបអាហារសម្រាប់គ្រួសារ។ សាច់មានតម្លៃ ២.៥ដុល្លារ បន្លែមានតម្លៃ ២.២៥ដុល្លារ ត្រីមានតម្លៃ ២.២៥ដុល្លារផងដែរ ឯនំបុ័ងបារាំង ឬបាយមួយចង់នឹងត្រូវចំណាយ១.៧៥ដុល្លារ។

# មេរៀនទី ៣: សុវត្ថិភាព

🕑 រយៈពេលបង្រៀនៈ ១ ម៉ោង ៣០ នាទី

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន
- សំណួរ សម្រាប់សកម្មភាពគ្រូ នឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរសិក្សាលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ។
- ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ។
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)

📖 សម្ភារឧបទេស/ធនធានដែលត្រូវការ

- ប័ណ្ណតូចៗជាមួយវត្ថុដែលអ្នកអាចសន្សំបាន
- ឯកសារសម្រាប់សិស្សទី ៣ក ៖ រូបភាពសត្វស្រមោច
- កាសែតម៉ាញេ
- ប្រអប់សម្រាប់លេងល្បែងកំសាន្ត
- ប្រអប់សន្សំផ្ទាល់ខ្លួនសម្រាប់សិស្សម្នាក់ៗ
- ខ្មៅដៃ ជ័រកាវ និងទស្សនាវដ្ដីចាស់ៗ ក្រដាស ថ្នាំលាប

☼ វត្ថុបំណងៈ

នៅពេលរៀនមេរៀននេះចប់សិស្សទាំងអស់អាច ៖

- ដឹងថាវាមានសារៈសំខាន់ ក្នុងការសន្សំដើម្បីរៀបចំ និងប្រើប្រាស់ពេលវេលាដែលកាន់តែពិបាកៗជាច្រើន
- កំណត់វត្ថុមួយចំនួនដែលពួកគេអាចសន្សំបាន
- បង្កើតប្រអប់សន្សំផ្ទាល់ខ្លួនមួយ

## ចំណាងជើងមេរៀនទី ៣៖ សុវត្ថិភាព 🕑 ២៥ នាទី

### សេចក្ដីផ្ដើម

នាំសិស្សទៅកាន់សំបុក ឬដំបូកសត្វស្រមោច។ ប្រសិនជាមិនអាចទៅរួច បង្ហាញពួកគេពីរូបភាពសត្វស្រមោចពាំស្លឹកឈើ។ (ល្បែងកំសាន្តអាចត្រូវបានលេងនៅខាងក្រៅថ្នាក់លើទីធ្លា។)

អនុញ្ញាតឱ្យសិស្សសង្កេត និងសួរពួកគេ ៖ តើសត្វស្រមោចកំពុងធ្វើអ្វី?

ចម្លើយដែលអាចមានៈ ពាំចំណី ប្រមូលទុកចំណី ការពារសំបុក ។ល។

យើងអាចរៀនពីសត្វស្រមោច។ អ្វីដែលសំខាន់បំផុតនោះ គឺសន្សំសម្រាប់ថ្ងៃ ដែលមានភ្លៀងច្រើន។ ពន្យល់សិស្សពីពាក្យថា ថ្ងៃដែលមានភ្លៀងច្រើន គឺជាពាក្យប្រៀបធៀបទៅនឹងពេល វេលាដែលពិបាកមួយ ដែលយើងនឹងត្រូវការទាំងធនធានថវិកា ឬធនធានមិនមែនជាថវិកាដើម្បីរស់នៅ។

យើងនឹងលេងល្បែងកំសាន្តមួយ។ គោលបំណងគឺ ដើម្បីជៀសវាងទទឹកពេលភ្លៀងអ្នកទាំងឡាយណាដែលទទឹក ត្រូវឆ្លើយនឹងសំណួរខាងក្រោម ៖

១. តើសម្ភារៈអ្វីខ្លះដែលអ្នកត្រូវការពេលវេលាដែលពិបាក ឬបន្ទាន់?

២. តើអ្នកអាចប្រើប្រាស់ការសន្សំថវិកាសម្រាប់ធ្វើអ្វី?

៣. តើអ្នកអាចប្រើប្រាស់ការសន្សំរបស់មិនមែនជាលុយសម្រាប់ធ្វើអ្វី?

ចូរពន្យល់ថា អ្នកចូលរួមទាំងអស់ត្រូវការគិតចម្លើយ៣ចំពោះសំណួរនីមួយៗ។ យើងនឹងប្រើចម្លើយទាំងនោះក្នុងល្បែងកំសាន្ត។

លេងល្បែង ៖ ភ្លៀងធ្លាក់ហើយ

ប្រាប់ទៅកាន់ក្រុមក្នុងសម្លេងខ្លាំងៗ៖ ភ្លៀងធ្លាក់ហើយ ផ្តុំជាក្រុមដោយខ្លួនអ្នកក្រោមឆត្រ ដែលមានសមាជិកចំនួន (ហៅចំនួនដូចជា ៥ ឬ ៧ )។ ក្រុមដែលមិនអាចផ្តុំសមាជិកបានគ្រប់ចំនួន នឹងត្រូវជម្រុសចេញ ហើយសមាជិកក្រុមនីមួយៗនឹងត្រូវឆ្លើយសំណួរ ដែលអ្នកបានផ្តល់ឱ្យកាលពីពេលមុន។

ត្រឡប់ទៅកាន់បន្ទប់រៀនវិញ។

**សកម្មភាពសំខាន់** ⌚ **៥៥** នាទី

តើនរណាអាចប្រាប់ពីចម្លើយដែលឆ្លើយកាលពីពេលលេងល្បែងកំសាន្ត?

សរសេរចម្លើយដែលទាក់ទងនឹងសំណួរទាំងបីនោះនៅលើក្តារខៀន។

បញ្ជាក់នៅចុងបញ្ចប់ថា ការសន្សំនឹងជួយសិស្សឆ្លងកាត់ពេលវេលាពិបាកបាន។ ការសន្សំក៏ នឹងធ្វើឱ្យមនុស្សយើងក្រោកឈរដោយខ្លួនឯង ដោយមិនចាំបាច់ពឹងពាក់អ្នកដទៃទៀត។ ប៉ុន្តែការសន្សំទាក់ទងជាមួយអ្នកដទៃទៀត នឹងផ្តល់ឱ្យអ្នកនូវមនុស្សម្នាក់ ដើម្បីពឹងអាស្រ័យ នៅពេលដែលអ្នកត្រូវការជំនួយពីអ្នកណាម្នាក់។ ក្រឡេកមើលក្បួនក្នុងការសន្សំ (សារៈសំខាន់ ក្នុងមេរៀនទី១)

តើមួយណាសំខាន់បំផុតសម្រាប់អ្នក?

នៅក្នុងសប្តាហ៍ក្រោយ អ្នកគ្រប់គ្នានឹងបង្ហាញថា តើអ្នកទាំងអស់គ្នា អាចសន្សំរបស់មានតម្លៃទៅតាមក្បួនដែលយើងបានរៀនដែរឬទេ។ អ្នកអាចជ្រើសរើសដោយខ្លួនឯងថា តើនោះជាអ្វី។ យើងនឹងរក្សាវាទុកនៅកន្លែងមានសុវត្ថិភាពក្នុងសាលា។

*សម្គាល់ ៖ ពន្យល់ពីប្រអប់ដែលអាចមាន និងកន្លែងដែលត្រូវចាក់សោរនៅពេលដែលចេញពីរៀន*

ប្រាប់សិស្សឱ្យគិតរឿងៗខ្លួន ពីអ្វីដែលពួកគេអាចសន្សំបាន។ រំលឹកពួកគេពីលទ្ធផល ដែលកើតឡើងក្នុងអំឡុងពេលលេងល្បែងកំសាន្តខុសៗគ្នាក្នុងមេរៀនទី១ ទី២ និងទី៣។

ប្រសិនបើរបស់ដែលពួកគេចង់សន្សំ មានទំហំធំពេកសម្រាប់ដាក់ក្នុងប្រអប់ ឬពិបាកយកមក ពួកគេអាចសរសេរពីរបស់នោះនៅលើក្រដាស ហើយដាក់នៅក្នុងប្រអប់សន្សំ។

*ប្រសិនបើពួកគេមានការលំបាក អ្នកអាចនិយាយពីលទ្ធភាពដំបូង ហើយធ្វើជាបញ្ជីមួយ។ ជម្រើសមានដូចជា ឯកសារល្អៗ អនុស្សាវរីយ៍សប្បាយ អាហារ សំលៀកបំពាក់ ទំនាក់ទំនង សាប៊ូដុសខ្លួន សាប៊ូកក់សក់ ឬសូម្បីតែរបស់ដែលមនុស្សដទៃគិតថាជាសំរាម ប៉ុន្តែអាចត្រូវ បានផ្លាស់ប្តូរជាវត្ថុតុបតែងសៀវភៅ។ល។*

ក្រោយពេល១០នាទី អនុញ្ញាតឱ្យពួកគេសម្រេចចិត្តទៅលើអ្វីដែលពួកគេអាចសន្សំ នៅរយៈពេល ៦ សប្តាហ៍ខាងមុខ។

ចូរចាំថា ៖ នេះមិនមែននិយាយអំពីចំនួនប៉ុន្មានដែលយើងសន្សំបាន ឬនរណាមានចំនួន ច្រើនជាងគេនោះទេ។ វាគឺអំពីនរណាអាចបង្ហាញឥរិយាបទល្អ និងអាចរក្សាការសន្សំបន្តទៅទៀតបាន។

*សម្គាល់ ៖ ប្រសិនជាអ្នកមានបញ្ហាក្នុងការយកប្រអប់សន្សំសម្រាប់សិស្សម្នាក់ៗ។*

ព្យាយាមរួមបញ្ចូលការសន្សំជាមួយគ្នា។ (មើលសេចក្តីណែនាំគ្រូ) នឹងប្រហែលជាមានសិស្សជាច្រើនព្យាយាមសន្សំប្រាក់ អនុស្សាវរីយ៍ ឯកសារល្អៗ ជាដើម។ ពួកគេអាចប្រើប្រអប់សន្សំ តែមួយបាន ពីព្រោះពួកគេនឹងប្រើប្រាស់សៀវភៅកត់ត្រាលុយដើម្បីតាមដានមើលនូវរាល់ការសន្សំរបស់ពួកគេ ដូច្នេះនៅចុងបញ្ចប់ យើងដឹងពីចំនួនច្បាស់លាស់នៃរបស់ដែលសិស្សម្នាក់បានសន្សំ។

បង្ហាញប្រអប់សន្សំ

នេះនឹងក្លាយជាប្រអប់សន្សំផ្ទាល់ខ្លួនរបស់អ្នក ដូច្នេះអ្នកត្រូវការធ្វើវាដោយខ្លួនឯង។សរសេរឈ្មោះរបស់អ្នក និងតុបតែងតាមរបៀបដែលអ្នកចូលចិត្ត។ អ្នកអាចប្រើសម្ភារៈខុសៗគ្នាដូច ជាទស្សនាវដ្តីចាស់ៗ ជ័រការ ខ្មៅដៃ។

**បញ្ចប់មេរៀន** ១០ នាទី

ចែកប័ណ្ណតូចៗទៅកាន់សិស្សគ្រប់គ្នា។

សិស្សទាំងអស់សរសេរឈ្មោះសម្ភារៈមួយ ដែលគេអាចសន្សំនៅលើប័ណ្ណដែលគ្រូបានផ្តល់ឱ្យ។ បំផុសពួកគេឱ្យចេះគិតដោយខ្លួនឯងប្រកបដោយភាពច្នៃប្រឌិត។ នៅពេលពួកគេធ្វើរួចរាល់ ប័ណ្ណទាំងអស់នឹងត្រូវប្រមូលផ្តុំក្នុងប្រអប់។ ជ្រើសរើសយកប័ណ្ណ មួយ ហើយបិទវាលើខ្នងរបស់សិស្ស។ សិស្សនីមួយៗទទួលបាននូវប័ណ្ណមួយ។

គោលបំណង ៖ ស្វែងរកអ្វីដែលនៅលើខ្នងរបស់អ្នក។

លក្ខខណ្ឌមួយ ៖ អ្នកអាចសួរសំណួរដែលអាចឆ្លើយថា "ទេ" ឬ "បាទ/ចាស"។

សិស្សគ្រប់គ្នាដែលដឹងថាអ្វីនៅលើខ្នងរបស់គេ អាចឈរនៅមុខក្តារខៀន។

ក្រោយពេល៥នាទី បញ្ឈប់ល្បែងកំសាន្ត ហើយសួរពួកគេថា តើពួកគេគិតថាវាជាអ្វី។ បន្ទាប់ពីពួកគេឆ្លើយ អនុញ្ញាតឱ្យពួកគេពិនិត្យថា តើវាត្រឹមត្រូវឬទេ?។

## សេចក្តីណែនាំគ្រូ

● ទោះបីជាសិស្សមិនសន្សំលុយ ក៏វានៅតែសំខាន់ ក្នុងការបង្កើតប្រព័ន្ធសន្សំសុវត្ថិភាពមួយ។ឬស្សីមានតម្លៃថោក និងជាមធ្យោបាយសុវត្ថិភាពដើម្បីសន្សំលុយ ឬរបស់មានតម្លៃផ្សេងៗ។ ប្រអប់ដែលអាចចាក់សោបាន ឬក៏កំប៉ុងក៏អាចប្រើបានដែរ។

● បញ្ហាមួយទៀត គឺត្រូវគិតដោយប្រុងប្រយ័ត្ន អំពីការថែរក្សាវាឱ្យមានសុវត្ថិភាពពេលចេញពីរៀន។ ប្រហែលជាលោកនាយកមានកន្លែងសុវត្ថិភាពដើម្បីរក្សាប្រអប់ ឬ ប្រហែលជាមានអ្នកយាមអាចថែរក្សាវាបាន។

● មូលហេតុក្នុងការរួមបញ្ចូលការសន្សំខុសៗគ្នាទៅក្នុងប្រអប់តែមួយគឺ ដើម្បីមានភាពងាយស្រួល។ មធ្យោបាយនេះ អ្នកមិនចាំបាច់ធ្វើប្រអប់៣០ខុសៗគ្នានោះទេ។ ប៉ុន្តែជាការពិតណាស់ ការមានប្រអប់សន្សំមួយសម្រាប់សិស្សម្នាក់ៗ គឺមានលក្ខណៈប្រសើរជាង!



# មេរៀនទី ៤: ការរៀបចំ

⏲ រយៈពេលបង្រៀនៈ ១ ម៉ោង ៣០ នាទី

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន
- សំណួរ សម្រាប់សកម្មភាពគ្រូវ នឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរសិក្សាលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ។
- ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្តារខៀន...)

📖 សម្ភារឧបទេស/ធនធានដែលត្រូវការ

១. ថតចម្លងឯកសារសម្រាប់សិស្ស ៤ខ សម្រាប់ក្រុមនីមួយៗដែលមានសិស្ស៤នាក់

២. ក្រដាសស្អាតមួយសម្រាប់សិស្សម្នាក់

៣. សរសេរឯកសារសម្រាប់សិស្ស ៤ក នៅលើក្តារខៀន

☼ វត្ថុបំណង:

នៅពេលរៀនមេរៀននេះចប់សិស្សទាំងអស់អាច ៖

- បង្កើតសៀវភៅសន្សំសង្ខេបមួយ និងដឹងពីរបៀបប្រើប្រាស់វា
- សរសេរសំណួរផ្សេងៗដែលទាក់ទងជាមួយការសន្សំ និងប្រព័ន្ធធនាគារ
- សរសេរសំបុត្រជាផ្លូវការមួយទៅកាន់អ្នកគ្រប់គ្រងធនាគារ តាមអត្ថន័យ និងទម្រង់ដូចការបង្ហាញ។

**ចំណងជើងមេរៀនទី ៤: ការរៀបចំ** ⏲ ១៥ នាទី

**សេចក្តីផ្តើម**

សិស្សម្នាក់នឹងចាប់ផ្តើមនិយាយ ៖ ខ្ញុំទៅធនាគារដើម្បីសន្សំ...។ សិស្សត្រូវបញ្ជាក់អ្វីមួយ ដូចជា ផ្លែប៉ោម។ សិស្ស បន្ទាប់បន្តនិយាយ ៖ ខ្ញុំទៅធនាគារដើម្បីសន្សំផ្លែប៉ោម និង ...។ គាត់ត្រូវថែមអ្វីមួយ ដូចជា លុយ។ សិស្សទីបីក៏និយាយ ផងដែរថាៈ ខ្ញុំទៅធនាគារដើម្បីសន្សំផ្លែប៉ោម លុយ និង ...។

ល្បែងកំសាន្តឈប់នៅពេលដែលនរណាម្នាក់ មិនអាចចងចាំពាក្យ ដែលបាននិយាយពីមុន ហើយបន្ទាប់មក អ្នកអាចចាប់ផ្តើមសារជាថ្មីនៅកន្លែងដែលបានឈប់។

**សកម្មភាពសំខាន់** ⏲ ៤០ នាទី

ថ្ងៃនេះ យើងនឹងបង្កើតសៀវភៅសន្សំមួយដើម្បីកត់ត្រាពីការសន្សំ និងការចំណាយ របស់យើង។ វាជារបស់ដ៏មានប្រយោជន៍មួយដែលអ្នកក៏អាចប្រើវាបាននៅផ្ទះផងដែរ។

ចែកក្រដាសស ទៅសិស្សគ្រប់គ្នា។ ពួកគេអាចមើលនៅលើ ក្តារខៀន ទៅក្រុមដែល មានសមាជិក ៤នាក់។ ពួកគេអាចចែកគ្នា មើលឯកសារនេះ។ ផ្តល់ការណែនាំអំពីរបៀបក្នុងការប ត់សៀវភៅ ធម្មតាមួយ។



សរសេរតារាងពេលវេលាដែលមាននៅលើឯកសារសម្រាប់សិស្ស ៤ "ក"
សិស្សត្រូវការសរសេរឈ្មោះខុសៗគ្នានៅក្នុងជួរនីមួយៗ។

| កាលបរិច្ឆេទ | ការសន្សំចូល | ការសន្សំចេញ | សរុប |
|---|---|---|---|
| ឧ. ថ្ងៃអង្គារ ទី១៧ ខែមីនា | ទង្វើល្អ២ | មិនមាន | ទង្វើល្អ២ |
| ថ្ងៃព្រហស្បតិ៍ ទី១៩ ខែមីនា | ទង្វើល្អ១ | មិនមាន | ទង្វើល្អ៣ |

គ្រប់ពេលវេលាដែលអ្នកមកសាលារៀន និងដាក់អ្វីមួយទៅក្នុងប្រអប់សន្សំរបស់អ្នក ត្រូវកត់ត្រាក្នុងសៀវភៅសន្សំរបស់អ្នកឱ្យបានទៀងទាត់។

*ប្រសិនបើជាសិស្សខុសគ្នាប្រើប្រអប់តែមួយក្នុងពេលដូចគ្នា ពួកគេគួរតែពិគ្រោះជាមួយគ្រូជាមុនសិន (មើលសេចក្តីណែនាំគ្រូ)។*

**បញ្ចប់មេរៀន** ៣៥ នាទី

ក្នុងសប្តាហ៍ក្រោយ យើងនឹងធ្វើទស្សនកិច្ចសិក្សានៅធនាគារមួយដើម្បីមើលអ្វីខ្លះបានកើតឡើងជាមួយលុយដែលមនុស្សផ្ញើក្នុងធនាគារ។ ថ្ងៃនេះ យើងនឹងរៀបចំការធ្វើទស្សនកិច្ច សិក្សានេះ។ អ្នកអាចបង្កើតជាក្រុមដែលមានសមាជិក ៤នាក់ ហើយជ្រើសម្នាក់ដើម្បីសរសេរ គំនិត និងចម្លើយរួមរបស់អ្នកពីសមាជិកគ្រប់ៗគ្នា។

ចែកឯកសារសម្រាប់សិស្ស ៤ខ ទៅកាន់សិស្សគ្រប់គ្នានេះ គឺអាចរៀបចំពួកគេសម្រាប់ដំណើរទស្សនកិច្ចសិក្សាទៅធនាគារ។ ប្រហែលជាសិស្សអាចរៀបចំលិខិតរបស់ពួកគេ សម្រាប់ផ្ញើទៅធនាគារនៅក្នុងបន្ទប់កុំព្យូទ័រ?

តមកទៀត អនុញ្ញាតឱ្យក្រុមមួយចំនួនអានខ្លាំងៗនូវគំនិត និងសំណួរដែលអាចមាន។ នៅសប្តាហ៍ក្រោយ ពួកគេនឹងធ្វើការស្រាវជ្រាវចំពោះវា ក្នុងអំឡុងពេលទស្សនកិច្ចសិក្សា។

## សេចក្តីណែនាំគ្រូ

- វានឹងអស្ចារ្យណាស់ប្រសិនបើធនាគារមូលដ្ឋានស្ម័គ្រចិត្តបង្ហាញសិស្សពីរបៀបធ្វើការងាររបស់ធនាគារ។ នេះនឹងមានផលប្រយោជន៍ដល់ធនាគារផងដែរ។ សិស្សដែលមានចំណាប់អារម្មណ៍ ចំពោះការងារក្នុងប្រព័ន្ធធនាគារ និងការលើកទឹកចិត្តឱ្យពួកគេផ្ញើលុយក្នុងធនាគារ គឺមាន សារៈសំខាន់សម្រាប់ធនាគារ។
- ប្រសិនបើមិនអាចធ្វើទស្សនកិច្ចសិក្សានៅធនាគារបាន អ្នកប្រហែលជាអាចរៀបចំដំណើរទស្សនកិច្ចទៅកាន់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយ។ វាមានសារៈសំខាន់ក្នុងការបញ្ជាក់ទៅកាន់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុថា យើងយកចិត្តទុកដាក់ចំពោះសេវាសន្សំ *មិនមែនសេវាកម្ចី ឬសេវាកម្មហិរញ្ញវត្ថុផ្សេងៗ ដែលមានផ្តល់ជូននោះទេ។*
- ជាពិសេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដូចជា វីសិនហ្វាន់ អេស៊ីលីដា អេអឹមខេ និងអម្រឹត គឺភាគច្រើនគួរឱ្យមានចំណាប់អារម្មណ៍។
- ចុងបញ្ចប់ នៅពេលដែលគ្មានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងធនាគារ យើងក៏អាចប្រើឯកសារចែកសិស្ស ៥ ដែលសិស្សអាចអានអំពីការធ្វើទស្សនកិច្ចធនាគារ ដែលសិស្សដទៃបានធ្វើ។

**ធនាគារ**

Form TRANSFER-07-A

## ពាក្យស្នើសុំផ្ទេរប្រាក់ក្នុងស្រុក
## LOCAL MONEY TRANSFER FORM

ការិយាល័យ (Office): ..................

**សម្រាប់អតិថិជន (FOR CUSTOMER)**

| | |
|---|---|
| ផ្ញើទៅ **Send to** | ឈ្មោះធនាគារទទួលផល (Name of beneficiary's bank): |
| | ឈ្មោះគណនី / ឈ្មោះអ្នកទទួលប្រាក់ (Account name / Receiver's name): |
| | លេខគណនី / អត្តសញ្ញាណ / លេខឥណទាន (Account N° / ID N° / Loan N°) |
| ចំនួនទឹកប្រាក់ផ្ញើ **Amount** | ជាលេខ (In figures): |
| | ជាអក្សរ (In words): |
| សំណួរសាកល្បង **Test question** | សំណួរ (Question): |
| | ចម្លើយ (Answer): |
| គោលបំណង **Purpose** | ☐ ផ្ញើឲ្យបងប្អូន (To a relative)<br>☐ ទូទាត់ឥណទាន (Loan repayment)<br>☐ ទូទាត់ថ្លៃទំនិញ/វិក្កយបត្រ (Pay for goods/invoice)<br>☐ ផ្សេងៗ (Others): |

| | |
|---|---|
| រូបិយប័ណ្ណ **Currency type** | ☐ ប្រាក់រៀល (KHR) ☐ ប្រាក់ដុល្លារ (USD)<br>☐ ប្រាក់បាត (THB) ☐ ផ្សេងៗ (Others): |
| ទូទាត់តាមរយៈ **Payment methods** | ☐ សាច់ប្រាក់ (Cash)<br>☐ គណនីលេខ (Account number):<br>☐ មូលប្បទានបត្រលេខ (Cheque number): |
| អ្នកផ្ញើប្រាក់ **Sender** | ឈ្មោះ (Name):<br>លេខទូរស័ព្ទ/អាសយដ្ឋាន (Phone/Add.): |
| ថ្លៃសេវាកម្មធនាគារ **Bank charges** | ☐ ទូទាត់ពីអ្នកផ្ញើ (From sender) ☐ ទូទាត់ពីអ្នកទទួល (From receiver)<br>☐ បង់ជាសាច់ប្រាក់ (Pay in cash) ☐ ផ្សេងៗ: (Others) |

ហត្ថលេខា ស្នាមមេដៃអ្នកផ្ញើប្រាក់
**(Signature / Thumbprint of Sender)**

កាលបរិច្ឆេទ (Date: DD / MM / YY)

ឯកភាពតាមលក្ខខណ្ឌប្រតិបត្តិការសេវាផ្ទេរប្រាក់នៅផ្នែកខាងក្រោយទម្រង់នេះ
(I agree with terms & conditions on the reverse of this form)

**សម្រាប់ធនាគារ (FOR BANK USE ONLY)**

| *Denomination* | | |
|---|---|---|
| | *Currency debit* | |
| | *Exchange rate* | |
| | *Transfer amount* | |
| | *Fee charge* | |
| | *Other* | |
| | *Total* | |

| *Authorized by* | *Certified by* | *Prepared by* |
|---|---|---|
| | | |

Marketing Division (17 December 2012)

Form TRANSFER-07-A

**ធនាគារ**

Form C-2

## ប័ណ្ណដាក់ប្រាក់បញ្ញើ
## DEPOSIT VOUCHER

| | |
|---|---|
| គណនីលេខ / ទូរស័ព្ទលេខ<br>Account / Mobile phone number | |
| ឈ្មោះគណនី<br>Account name | |

| លេខមូលប្បទានបត្រ<br>Check number | ឈ្មោះធនាគារ / សាខា<br>Bank / Branch name | ចំនួនទឹកប្រាក់<br>Amount |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |
| | កម្រៃសេវា / Fee charge | |
| | **សរុប / Total** | |

| | |
|---|---|
| សរុបចំនួនទឹកប្រាក់ជាអក្សរ<br>**Total amount in words** | |

ការណែនាំផ្សេងៗ :
Other instructions

ហត្ថលេខាអ្នកដាក់ប្រាក់បញ្ញើ / Depositor's signature

កាលបរិច្ឆេទ / Date: / /

☐ គណនីផ្ទាល់ Own account ☐ គណនីភាគីទីបី Third party account

☐ សាច់ប្រាក់ / Cash ☐ មូលប្បទានបត្រ / Check

**រូបិយប័ណ្ណ / Currency type**

☐ ប្រាក់រៀល / KHR ☐ ប្រាក់បាត / THB
☐ ប្រាក់ដុល្លារ / USD ☐ ផ្សេងៗ / Other:

**សម្រាប់ធនាគារ / FOR BANK USE ONLY**

ពិនិត្យ និងអនុម័ត
Checked and authorized

បេឡាធិការ
Teller

***Denomination***

| | | | |
|---|---|---|---|
| 500,000 x | = | 500 x | = |
| 200,000 x | = | 200 x | = |
| 100,000 x | = | 100 x | = |
| 50,000 x | = | 50 x | = |
| 20,000 x | = | 20 x | = |
| 10,000 x | = | 10 x | = |
| 5,000 x | = | 5 x | = |
| 2,000 x | = | 2 x | = |
| 1,000 x | = | 1 x | = |

*Total* -

MKD-22022013

*Bank's copy*

Form C-2



# គិតពីវា

នៅពេលដែលអ្នកមិនចាយលុយរបស់អ្នក មានន័យថាអ្នកសន្សំវា។ អ្នកមានជម្រើសជាច្រើនក្នុងការសន្សំលុយ។ ជម្រើសមួយ គឺទុកវាតាមធម្មតានៅក្នុងផ្ទះ ឬ ទុកក្នុងប្រអប់សន្សំដូចដែលបានធ្វើនៅសាលារៀន។ ជម្រើសមួយទៀត គឺដាក់វាក្នុងគណនីសន្សំរបស់ធនាគារ ។

ហេតុអ្វីអ្នកចង់ទុកលុយនៅក្នុងធនាគារ? តើធនាគារមានអ្វីដែលប្រអប់សន្សំរបស់អ្នកគ្មាន? សរសេរគំនិតរបស់អ្នកនៅខាងក្រោម:

______________________________

______________________________

______________________________

______________________________


World Education, Inc.
Cambodia Field Office
REGISTER (US$)

| Date | Voucher | Description | Received | Disburse | adv recon. | Balance |
|---|---|---|---|---|---|---|
| | | Opening Balance | | | | |

Details of US$ cash in cash box:

Total US$ in Cash Box =

Prepared by: Accountant Date: | Verified by: Finance Assistant Date: | Cash Checked/Counted by: Country Director Date:

យើងនឹងស្វែងយល់ពីរបៀបធ្វើការងាររបស់ធនាគារ ហើយនិងអ្វីដែលកើតមានចំពោះលុយរបស់យើងនៅពេលដែលយើងទុកវាក្នុងធនាគារ។

តើអ្នកចង់ដឹងចម្លើយរបស់សំណួរនោះគឺអ្វីដែរទេ?

ការធ្វើទស្សនកិច្ចទៅកាន់ធនាគារ នឹងក្លាយជាបទពិសោធន៍សិក្សាដ៏អស្ចារ្យមួយ។

នៅពេលបញ្ហាទាំងអស់នោះត្រូវបានសម្រេចចិត្ត អ្នកអាចសរសេរលិខិតផ្ញើទៅកាន់ធនាគារដែលអ្នកចង់ទៅទស្សនកិច្ច។ តើអ្នកស្គាល់ឈ្មោះរបស់អ្នកគ្រប់គ្រងធនាគារដែលអ្នកអាចសុំការអនុញ្ញាតបានដែរឬទេ? បន្ទាប់មក សរសេរលិខិត ស្នើសុំមួយ។

កាលបរិច្ឆេទ__________________

គោរពជូន លោក/លោកស្រី

យើងខ្ញុំជាសមាជិក ឬសិស្សថ្នាក់ទី ______ សិក្សានៅក្នុងសាលា __________________

ដែលមានអាសយដ្ឋាននៅ __________________________________________ ។

នៅក្នុងសាលារបស់យើង ពួកយើងកំពុងតែសិក្សាអំពី ____________________________

ហើយយើងចង់ដឹងបន្ថែមទៀតពីធនាគារធំៗដូចជា ___________________________ ។

យើងខ្ញុំចង់ ទៅធ្វើទស្សនកិច្ចសិក្សាធនាគាររបស់អ្នក នៅថ្ងៃទី_____ ខែ _________ ឆ្នាំ

_____ វេលាម៉ោង ___________ ។

យើងខ្ញុំមានសមាជិកចំនួន ___________ និងគ្រូរបស់យើង ___________ នឹងទៅជាមួយយើង ។

យើងខ្ញុំនឹងរង់ចាំការឆ្លើយតបពី ឬអនុញ្ញាតពីអ្នក។ សូមអរគុណ។

ដោយសេចក្ដីស្មោះត្រង់ពី

_________________

_________________

_________________

_________________

# មេរៀនទី ៥: ការទៅធនាគារ

🕑 រយៈពេលបង្រៀន: ១ ម៉ោង ៣០ នាទី

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន
- សំណួរ សម្រាប់សកម្មភាពគ្រូវ នឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរសិក្សាលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ។
- ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្តារខៀន...)
- រៀបចំបន្ទប់រៀន៖ តុ កៅអី ក្តារខៀន។ល។




📖 សម្ភារឧបទេស/ធនធានដែលត្រូវការ

ក្រដាសពណ៌សធំសម្រាប់ធ្វើការវាយតម្លៃ
នៃការធ្វើទស្សនកិច្ចសិក្សា

☼ វត្ថុបំណង:

នៅពេលរៀនមេរៀននេះចប់សិស្សទាំងអស់អាច ៖

- កំណត់ពីការងារខុសៗគ្នាក្នុងធនាគារ
- ប្រាប់ពីផលប្រយោជន៍ក្នុងការផ្ញើលុយក្នុងធនាគារ

## ចំណងជើងមេរៀនទី ៥: ការទៅធនាគារ

🕑 ១០ នាទី

### សេចក្តីផ្តើម

អាស្រ័យលើចម្ងាយ គ្រូអាចរំលឹកសិស្សពីមូលដ្ឋានច្បាប់សុវត្ថិភាពតាមដងផ្លូវខ្លះ។

- នៅពេលដើរ ឬជិះកង់ កុំទន្ទឹមគ្នាច្រើនជាងពីរនាក់
- នៅពេលបត់ឆ្វេង ឬស្តាំ ត្រូវប្រើដៃដើម្បីជាសញ្ញាបង្ហាញទិសដៅ

ជាមួយគ្នានេះ គ្រូវរំលឹកសិស្សថា យើងគឺជាភ្ញៀវក្នុងធនាគារ ដូច្នេះយើងមិនអាចប៉ះពាល់វត្ថុផ្សេងៗដោយគ្មានការសុំ ឬការអនុញ្ញាតនោះទេ។ ផ្តល់សំណួរ៣ទៅកាន់សិស្សឆ្លើយ ខណៈពេលកំពុងធ្វើទស្សនកិច្ចសិក្សានៅធនាគារ។

១. តើការងារផ្សេងៗក្នុងធនាគារមានអ្វីខ្លះ?
២. ហេតុអ្វីបានជាមនុស្សយកលុយរបស់ពួកគេមកធនាគារ?
៣. តើអ្នកបានរៀនរបស់ថ្មីអ្វីខ្លះ?

តើអ្នកទាំងអស់គ្នាបានត្រៀមសំណួរសម្រាប់សួរ អ្នកគ្រប់គ្រងធនាគារមកជាមួយដែរឬទេ? ប្រសិន បើមានយើងចាប់ផ្តើមចេញដំណើរ!

**សកម្មភាពសំខាន់** ⌚៦០ នាទី

នេះអាចជាតារាងពេលវេលានៃការធ្វើទស្សនកិច្ចសិក្សាដែលសិស្សយកមក

| រយៈពេល | សកម្មភាព | ប្រធានបទ |
|---|---|---|
| ១០នាទី | ស្វាគមន៍ | ណែនាំពីមនុស្សនៅក្នុងធនាគារ ណែនាំពីគ្រូ និងសិស្ស |
| ១៥នាទី | ធនាគារ | អ្នកគ្រប់គ្រងនិយាយពីប្រវត្តិរបស់ធនាគារ និងអាចផ្តល់ព័ត៌មានលម្អិតជាក់លាក់ពីវា។ |
| ១៥នាទី | ការងារ | អនុញ្ញាតឱ្យអ្នកគ្រប់គ្រងពន្យល់ពីការងារក្នុងធនាគារ និងកិច្ចការផ្សេងៗទៀត។<br>អ្នកគ្រប់គ្រងអាចប្រើបរិក្ខារពិតៗ<br>និងអាចបង្ហាញពីសៀវភៅគណនី សន្សំគំរូមួយ។ |
| ១៥នាទី | សំណួរ | សិស្សមានឱកាសសួរសំណួររបស់ពួកគេ។ |

គ្រូដើរជុំវិញ និងធ្វើឱ្យច្បាស់ថា អ្នកគ្រប់គ្រងយកចិត្តទុកដាក់លើផលប្រយោជន៍នៃធនាគារ និងរបៀបដំណើរការធនាគារ។ វាក៏ជាការល្អម៉្យាងដែរ ក្នុងការបង្កើតរូបភាពខ្លះៗ ដែលអាចប្រើដើម្បីបង្ហាញក្នុងថ្នាក់រៀន។ ក្រោយពេលមួយម៉ោងសិស្សត្រឡប់ទៅកាន់សាលាវិញ។



**បញ្ចប់មេរៀន** ⌚ ២០ នាទី

សិស្សធ្វើការជាដៃគូ ពួកគេប្រាប់គ្នាទៅវិញទៅមក ពីបទពិសោធន៍របស់ពួកគេក្នុងធនាគារ។ ពួកគេក៏ឆ្លើយសំណួរទី១ និងទី២ នៅក្នុងសេចក្ដីផ្ដើមផងដែរ។ សំណួរផ្សេងៗ ដែលពួកគេបានសួរ ក៏អាចឆ្លើយបានដែរ។

នៅលើក្រដាសធំមួយអ្នកសរសេរពាក្យ "ធនាគារ" សិស្សត្រូវសរសេរយ៉ាងហោចណាស់បញ្ហាមួយ ដែលពួកគេរៀនបានពីការធ្វើទស្សនកិច្ចសិក្សារបស់ពួកគេ។ ប្រសិនបើពួកគេ មិនមានអ្វីថ្មីទេ ពួកគេអាចសរសេរអ្វីដែលពួកគេ *ចូលចិត្ត*។

ព្យួរផ្ទាំងក្រដាសនៅលើជញ្ជាំង។ ប្រហែលជាអាចផ្ដិតរូបភាពខ្លះៗ ហើយបិទវានៅលើក្រដាស នោះ។

## សេចក្ដីណែនាំគ្រូ

គ្រូមានទំនាក់ទំនងច្បាស់លាស់ជាមួយការគ្រប់គ្រងរបស់ធនាគារ ធ្វើការចាត់ចែងអំពី ៖

- ពេលវេលាទៅដល់ និងពេលវេលាចាកចេញ
- តើនរណាអាចឆ្លើយនឹងសំណួររបស់សិស្ស?
- តើនរណាអាចពន្យល់ពីរបៀបធ្វើការងាររបស់ធនាគារ និងអាចនាំសិស្សដើរមើលបាន?

ប្រសិនបើមិនអាចទៅធ្វើទស្សនកិច្ចសិក្សានៅធនាគារ អ្នកអាចប្រើឯកសារសម្រាប់សិស្ស ៥ក និង ៥ខ ដើម្បីធ្វើឱ្យដូចការទៅទស្សនកិច្ច។ នេះជារឿងរ៉ាវអំពីកុមារមួយចំនួនដែលផ្ដល់ ព័ត៌មានអំពីការទស្សនារបស់ពួកគេ។

- សិស្សប្រហែលជាត្រូវការយកកង់របស់ពួកគេ ប្រសិនបើធនាគារនៅឆ្ងាយ។ ពេលវេលាធ្វើដំណើរមិនត្រូវបានបូកបញ្ចូលក្នុងតារាងសកម្មភាពការងារទេ។



ឯកសារចែកសិស្ស ៥គ - ការសន្សំ និងការចំណាយ

បន្តអានដើម្បីស្វែងយល់ពីដំណើរផ្សងព្រេងរបស់ពួកគេទៅកាន់ធនាគារ!

ធនាគារមាន *ទីតាំងនៅក្នុងអាគារមួយកណ្ដាលទីប្រជុំជនជិតបំផុតមួយ* ។
ពួកគេបានឃើញអាគារនេះជាច្រើនដងមកហើយ ប៉ុន្តែស្ទើរតែទាំងអស់គ្នាមិនដែលធ្លាប់ចូលទៅកាន់កន្លែងនោះឡើយ ។




មានមនុស្សជាច្រើនកំពុងអង្គុយនៅខាងក្រោយតុជាមួយឯកសារជាច្រើននិងមានកុំព្យូទ័រផងដែរ។ ពួកគេមើលទៅដូចជារវល់ណាស់។ មនុស្សជាច្រើនកំពុងបំពេញក្រដាសតូចមួយ ហើយអោយវាទៅអ្នក ដែលអង្គុយខាងក្រោយតុ។ មនុស្សជាច្រើនកំពុងរង់ចាំជាជួរនៅតុមួយដែលខ្ពស់ ហើយមានផ្លាំងសញ្ញាមួយសរសេរថា "លុយសុទ្ធ"។





អ្នកគ្រប់គ្រងបានស្វាគមន៍ពួកគេ ។ ពួកគេមានភាពតក់ស្លុតបន្តិច ។ តាមការពិត គាត់រំលឹក ពួកគេខ្លះៗអំពីវិន័យដំកឹងរឹង ។ ពួកគេបានទៅក្នុងការិយាល័យរបស់អ្នកគ្រប់គ្រង ។ គាត់បានអោយសិស្សអង្គុយចុះ ។ ពួកគេមានអារម្មណ៍ថា មានសារៈសំខាន់ និងទំនួលខុសត្រូវណាស់ដែលអង្គុយក្នុងការិយាល័យរបស់អ្នកគ្រប់គ្រងធនាគារ ។

គាត់បានប្រាប់ពួកគេថា គាត់ធ្វើការក្នុងធនាគារនេះជិត ១៥ឆ្នាំមកហើយ ។

ធនាគារមានឈ្មោះថា ______________________ ។ គាត់បានប្រាប់ពួកគេទៀតថា ធនាគារនេះមានទីស្នាក់ការធំនៅ

______________________ ហើយមានសាខាជិត១០០កន្លែងនៅទូទាំងប្រទេស។ គាត់បាននិយាយថា គាត់មានមោទនភាពណាស់ដែលមានចំណែកនៅក្នុងធនាគារធំបែបនេះ ដែលជួយមនុស្សទូទាំងប្រទេសអោយធ្វើការសន្សំ។

បន្ទាប់មក លក្ខណៈសំឡេងជាអ្នកជំនួញ គាត់ចាប់ផ្តើមពន្យល់ពួកគេពីរបៀបដំណើរការរបស់ធនាគារ។ នេះជារបស់មួយចំនួនដែល វិតា និង តូតូ ព្រមទាំងអ្នកដទៃនៅក្នុងក្លឹប អាហ្វ្លាតូន (Aflatoun) បានរៀន។

អ្នកគ្រប់គ្រងបានប្រាប់ពួកគេថា មនុស្សគ្រប់រូបសន្សំលុយរបស់ពួកគេនៅក្នុងគណនី ។ គាត់បន្តថា ធនាគារទាំងអស់មានប្រភេទគណនីខុសៗគ្នា។




មនុស្សម្នាក់ៗនៅក្នុងធនាគារមានគណនីមួយជាមួយលេខគណនីរៀងៗខ្លួន។ ព័ត៌មានលម្អិតអំពីគណនីរបស់មនុស្សម្នាក់ៗត្រូវបានរក្សាទុកក្នុងសៀវភៅសន្សំ។

**គណនីចរន្ត**

គណនីនេះជាធម្មតាគឺសម្រាប់អ្នកជំនួញដែលត្រូវការប្រើប្រាស់ធនាគារជាទៀតទាត់ និងរក្សាលុយរបស់ពួកគេក្នុងធនាគារដើម្បីធានាបានថាវាមានសុវត្ថិភាព។ ពួកគេដក និងដាក់លុយស្ទើរតែរាល់ថ្ងៃ។

**គណនីសន្សំ**

នេះជាអ្វីដែលមានសារៈសំខាន់សម្រាប់អ្នកត្រូវដឹង។ វាដូចគ្នាខ្លះៗទៅនឹងគណនីរបស់អ្នក។

នេះជាប្រភេទគណនីដែលមនុស្សភាគច្រើនចាប់ផ្តើមធ្វើការសន្សំ។

អ្នកអាចបន្ថែមលុយទៅក្នុងគណនីរបស់អ្នកពេលណាក៏បានតាមតែអ្នកចង់។ លុយដែលអ្នកបានបន្ថែមទៅក្នុងគណនីរបស់អ្នក គេហៅថា "លុយបញ្ញើ"។ ស្មៀននឹងបន្ថែមលុយបញ្ញើថ្មីទៅក្នុងលុយ ដែលអ្នកមានក្នុងគណនីរបស់អ្នក។ លុយសរុបរបស់អ្នក គេហៅថា "តុល្យភាព"។




លុយដែលអ្នកផ្ញើ គឺជាលុយរបស់អ្នក ទោះជាអ្នកទុកវានៅក្នុងធនាគារក៏ដោយ! ពេលខ្លះ បន្ទាប់ពីអ្នកបានសន្សំលុយរបស់អ្នក អ្នកចង់យកលុយមួយចំនួនមកវិញ ប្រហែលជាទៅទិញប្រដាប់ប្រដាលេងថ្មី ?

នៅពេលដែលអ្នកចង់យកលុយរបស់អ្នកមកវិញ អ្នកត្រូវធ្វើការដកលុយ ។ ការដកលុយ គឺជាការសុំពីធនាគារនូវលុយរបស់អ្នកមួយចំនួន ។

កាលណាអ្នកបានដកលុយមួយចំនួនដែលអ្នកចង់ វានឹងដកពីតុល្យភាពរបស់អ្នកពីមុន ។ វានឹងត្រូវបញ្ចូលក្នុងសៀវភៅសន្សំរបស់អ្នក ។

សមតុល្យថ្មីរបស់អ្នកនឹងជាលុយដែលអ្នកបានសន្សំ ដកនឹងលុយដែលអ្នកបានយកចេញ ។

# មេរៀនទី ៦: ធនាគារ

🕑 រយៈពេលបង្រៀនៈ ១ ម៉ោង ៣០ នាទី

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និង
- សំណួរ សម្រាប់សកម្មភាពគ្រូ នឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរសិក្សាលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ។
- ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)

📖 សម្ភារឧបទេស/ធនធានដែលត្រូវការ

១. ខ្មៅដៃពណ៌ ក្រដាសទំហំ A4 ដើម្បីផ្សាយពាណិជ្ជកម្មឱ្យធនាគារ

២. ម៉ាស៊ីនថតវីដេអូ ដើម្បីថតពាណិជ្ជកម្មតាមទូរទស្សន៍

☼ វត្ថុបំណងៈ

នៅពេលរៀនមេរៀននេះចប់សិស្សទាំងអស់អាច ៖

- យល់ពីគោលការណ៍អត្រាការប្រាក់
- ធ្វើឱ្យមានលក្ខណៈដូចជាប្រព័ន្ធធនាគារដោយការបង្កើតធនាគារផ្ទាល់ខ្លួនរបស់ពួកគេតាមរយៈការសម្ដែង
- យល់បានច្បាស់ និងពន្យល់ពីផលប្រយោជន៍របស់ធនាគារ

**ចំណងជើងមេរៀនទី ៦: ធនាគារ** 🕑 ១៥ នាទី

**សេចក្ដីផ្ដើម**

យើងនឹងរំលឹកការធ្វើទស្សនកិច្ចសិក្សារបស់យើងទៅកាន់ធនាគារ។ ឱ្យសិស្ស ៥នាក់ គូររូបភាពទាក់ទងនឹងអ្វី ដែលពួកគេបានរៀននៅលើក្ដារខៀន។ ពួកគេមានរយៈពេលតែ១០ នាទីដើម្បីគូរវា។

បន្ទាប់ពីនោះឱ្យសិស្សដទៃទាយថា តើពួកគេបានគូរអ្វី និងឱ្យពួកគ ពន្យល់ពីគំនូររបស់ពួកគេ នូវអ្វីដែលគេបានគូរ។ នេះអាចធ្វើជាមួយសិស្សខុសៗគ្នា។

លុក មានលុយ ៤០ ០០០រៀល ហើយចង់ទុកវានៅក្នុងធនាគារ។ ធនាគារឱ្យការប្រាក់ ៦%។
តើមួយឆ្នាំក្រោយមក លុកមានលុយចំនួនប៉ុន្មាន?
ហើយនៅពេលដែលអត្រាការប្រាក់ ៧% តើលុកមានលុយចំនួនប៉ុន្មាន?
ឬពេល លុកផ្ញើ ៨០ ០០០រៀល? តើលុកមានលុយចំនួនប៉ុន្មាន?

អត្រាការប្រាក់របស់ធនាគារ គឺថេរ មានន័យថា អ្នកនឹងទទួលបានលុយសម្រាប់ការសន្សំ! អ្នកសន្សំកាន់តែយូរ អ្នកទទួលបានលុយកាន់តែច្រើន។ ជាអកុសល នៅក្នុងប្រទេសកម្ពុជា កុមារមិនអាចបើកគណនីសន្សំដោយប្រើប្រាស់ឈ្មោះរបស់ពួកគេទេ រហូតដល់ពួកគេមាន អាយុ ១៨ឆ្នាំ។ តើអ្នកអាចធ្វើអ្វីបានចំពោះបញ្ហានេះ?
តើអ្វីជាគុណវិបត្តិ និងគុណសម្បត្តិក្នុងការទុកលុយរបស់អ្នកក្នុងធនាគារ?

**សកម្មភាពសំខាន់** 🕑 ៥០ នាទី

ថ្ងៃនេះយើង នឹងបង្កើតធនាគារផ្ទាល់ខ្លួនរបស់យើង។ ខ្ញុំនឹងចែកជាក្រុមតូចៗ ហើយអ្នកនឹងអនុវត្តការសម្តែងតួមួយ។ អ្នកអាចប្រើឯកសារសម្រាប់សិស្សទី ៦ជាជំនួយ។ លំហាត់មានបីផ្នែក៖

១. បង្កើតការផ្សាយពាណិជ្ជកម្មតាមទូរទស្សន៍មួយ ដែលមានថេរវេលា២នាទី និយាយអំពីមូលហេតុនិងសារៈសំខាន់ក្នុងការសន្សំលុយក្នុងធនាគារ

២. បង្កើតជាធនាគារផ្ទាល់ខ្លួនរួមទាំងកិច្ចការ សៀវភៅសន្សំ ក្រដាសដកប្រាក់ និងមូលប្បទានបត្រ។

ចែកឯកសារសម្រាប់សិស្សទី៦ ទៅក្រុមខុសៗគ្នាដើរជុំវិញ និងពិនិត្យមើលតើក្រុមទាំងអស់ធ្វើការ ជាមួយគ្នាដោយរបៀបណា។ អ្វីដែលមានសារៈសំខាន់បំផុតនោះ គឺពួកគេចែកការងារគ្នាធ្វើ និងអ្នកទាំងអស់គ្នាក៏ចូលរួមផងដែរ។ មើលពីដំណើរការរបស់វាពីរ ឬបីនាទី ហើយ*បើចាំបាច់*ផ្តល់ដំបូន្មានដល់ពួកគេ។

តើអ្នកណានឹងធ្វើអ្វី?
តើអ្នកត្រូវការអ្វី?
តើជំហានណាដែលអ្នកត្រូវអនុវត្ត?

នៅពេលដែលក្រុម បានបញ្ចប់ការបង្កើតការផ្សាយពាណិជ្ជកម្មតាមទូរទស្សន៍របស់ពួកគេ ពួកគេនឹងបង្កើតជា ធនាគារផ្ទាល់ខ្លួន។ អ្នកអាចលើកទឹកចិត្តពួកគេដោយ "ការទៅ" ធនាគាររបស់ពួកគេ ។ ដើរតួជាអតិថិជន ហើយទៅធនាគាររបស់ពួកគេដើម្បីដាក់លុយ ឬបើកគណនីមួយ។ ប្រសិនបើក្រុមជាច្រើនបានបញ្ចប់ អ្នកអាចអនុញ្ញាតឱ្យពួកគេអនុវត្តដោយការទៅកាន់ធនាគាររបស់ក្រុមដទៃ នេះអាចជាពេលដ៏សប្បាយមួយ។



**បញ្ចប់មេរៀន** ២៥ នាទី

ក្រុមទាំងអស់ បង្ហាញពីការផ្សាយពាណិជ្ជកម្មតាមទូរទស្សន៍របស់ពួកគេ។ ចាត់ឱ្យសិស្សខុសៗគ្នាថតពាណិជ្ជកម្មនោះទុក។ នៅពេលបន្ទាប់ពីការផ្សាយពាណិជ្ជកម្មបញ្ចប់ សិស្សដទៃទះដៃសរសើរចំពោះសិស្សដែលបានធ្វើការបង្ហាញ។

វាមិនអីទេ ប្រសិនបើអ្នកចង់ធ្វើវាម្តងទៀត ប៉ុន្តែមិនឱ្យលើសពី២ដងឡើយ។
នេះអាចជាឱកាសល្អដើម្បីបំពេញក្នុង*ក្រដាសវាយតម្លៃការសិក្សាសិស្ស*។

តើក្រុមណាមួយដែលបានបង្ហាញការផ្សាយពាណិជ្ជកម្មល្អជាងគេ និងហេតុអ្វី?
ព្យាយាមធ្វើឱ្យមានតុល្យភាពរវាង*ការពេញចិត្ត* (កំណត់សម្គាល់វិជ្ជមាន) និង*មតិយោបល់* (ដំបូន្មាន)

## សេចក្តីណែនាំគ្រូ

ប្រសិនបើអាចថតការផ្សាយពាណិជ្ជកម្មតាមទូរទស្សន៍ សិស្សអាចប្រើវាដើម្បីឆ្លុះបញ្ចាំងពី ពាណិជ្ជកម្មរបស់ពួកគេផ្ទាល់។ ការលើកទឹកចិត្តសិស្សឱ្យគិតពីស្នាដៃរបស់ពួកគេផ្ទាល់ និងពីរបៀបក្នុងការអភិវឌ្ឍ និងវាយតម្លៃ គឺជាឧបករណ៍សំខាន់សម្រាប់ការគិតស៊ីជម្រៅ និងបង្កើតសតិសម្បជញ្ញៈដោយខ្លួនឯង។

# មេរៀនទី ៧: អសុវត្ថិភាព

🕑 រយៈពេលបង្រៀនៈ ១ ម៉ោង ៣០ នាទី

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន
- សំណួរ សម្រាប់សកម្មភាពត្រូវ នឹងការបង្រៀនដែរឬទេ ?
- សរសេរសំណួរសិក្សាលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ។
- ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន ( តុ កៅអី ក្ដារខៀន...)

📖 សម្ភារឧបទេស/ធនធានដែលត្រូវការ

១. ខ្មៅដៃពណ៌

២. ក្រដាសស

៣. ឯកសារសម្រាប់សិស្សទី៧ - ករណីសិក្សា

☼ វត្ថុបំណងៈ

នៅពេលរៀនមេរៀននេះចប់សិស្សទាំងអស់អាចៈ

- យល់ភាពខុសគ្នារវាងលុយដុល្លារ និងលុយរៀល
- គណនាចំនួនលុយពីរៀលទៅដុល្លារ និងពីដុល្លារមកលុយរៀល
- ប្រើប្រាស់ចំណេះដឹងរបស់ពួកគេអំពីគុណវិបត្តិ និងគុណសម្បត្តិរបស់វិធីសាស្ត្រសន្សំផ្សេងៗ ក្នុងស្ថានភាពជាក់ស្ដែងខុសៗគ្នាតាមរយៈករណីសិក្សា

**ចំណាងជើងមេរៀនទី ៧: អសុវត្ថិភាព** 🕑 ១០ នាទី

**សេចក្ដីផ្ដើម**

សរសេរពីអត្រាប្ដូរប្រាក់រវាងដុល្លារ និងរៀល។ នៅថ្ងៃទី ២២ ខែមីនា ឆ្នាំ២០១១ គឺ១ដុល្លារ = ៤ ០០០រៀល។

ល្បែងកំសាន្តនេះ មានបំណងចង់ឱ្យអនុវត្តអត្រាប្ដូរប្រាក់រវាងដុល្លារ និងរៀល។ គ្រូនិយាយពីចំនួនប្រាក់រៀល ហើយសិស្សត្រូវប្ដូរទៅជាដុល្លារ។ នៅពេលដែលពួកគេដឹងថា វាមានចំនួនប៉ុន្មាន ពួកគេត្រូវបង្កើតជាក្រុមបង្ហាញនូវចំនួននោះ។

ឧទាហរណ៍ ៖ និយាយ ៖ ១២ ០០០រៀល នោះវាត្រូវជា ៣ដុល្លារ។ សិស្សត្រូវបង្កើតជាក្រុមដែល មានសមាជិកចំនួន ៣នាក់។៤០ ០០០រៀល គឺ ១០ដុល្លារ ហើយត្រូវនាំគ្នាបង្កើតជាក្រុមដូចមុន។ ប្រសិនបើអ្នកចង់ អ្នកធ្វើឱ្យពិបាកជាងនេះបន្តិច ដោយការបញ្ច្រាសមកវិញ និងឱ្យសិស្សចង្អុលបង្ហាញម្រាមដៃទៅលើ ដោយម្រាមមួយស្មើ ១០០០រៀល។

ឧទាហរណ៍ ៖ ២ដុល្លារ = ៨ម្រាម ដៃ ពីព្រោះ វាមានចំនួន ៨០០០ រៀល។ ៥ដុល្លារ = ២០ ម្រាមដៃ ដូច្នេះពួកគេត្រូវធ្វើការជាមួយគ្នា។




ពន្យល់ ៖ បន្ទាប់ពីរបបខ្មែរក្រហម ប្រព័ន្ធធនាគារត្រូវបានបំផ្លាញ ពីព្រោះខ្មែរក្រហមមិនចង់ឱ្យ មនុស្សមានឯកជនកម្មសិទ្ធិផ្ទាល់ខ្លួន។ ចំពោះជនបរទេសមួយចំនួនមកប្រទេសកម្ពុជាតាមរយៈអង្គការសហប្រជាជាតិ ពួកគេបានប្រើប្រាស់លុយដុល្លារជាច្រើន ហើយលុយដុល្លារត្រូវបានទទួលស្គាល់ផងដែរ។ នៅតំបន់ខ្លះជិតព្រំដែនប្រទេសថៃ អ្នកអាចប្រើលុយបាត។

និយាយជាមួយសិស្សអំពីការវិវឌ្ឍន៍នៃការសន្សំរបស់ពួកគេ។ តើនរណាសប្បាយចិត្តជាមួយការសន្សំនាពេលបច្ចុប្បន្ន? តើនរណាចង់សន្សំបន្ថែមទៀត? តើអ្នកអាចធ្វើវាបានដោយ របៀបណា?

**សកម្មភាពសំខាន់** ⏲ ៥០ នាទី

នៅក្នុងប្រទេសកម្ពុជាមានមធ្យោបាយខុសគ្នាៗជាច្រើនដើម្បីសន្សំ។ យើងនឹងក្រឡេកមើលជម្រើសទាំងអស់នោះ។ ដំបូង ខ្ញុំនឹងផ្តល់ករណីសិក្សាខ្លីមួយទៅកាន់ក្រុមនីមួយៗដែលមានសមាជិក៥នាក់ក្នុងមួយក្រុម។ អ្នកត្រូវអានករណីសិក្សា និងស្វែងរកគុណប្រយោជន៍ គុណ វិបត្តិ និងដំបូន្មានសម្រាប់មនុស្សក្នុងករណីសិក្សា។

ចែកឯកសារសម្រាប់សិស្សទី ៧ ទៅកាន់ក្រុមនីមួយៗដែលមានសមាជិក៥នាក់ក្នុងមួយក្រុម។ខណៈពេលដែលសិស្សកំពុងធ្វើការលើករណីសិក្សារបស់ពួកគេ អ្នកអាចសួរសិស្សខ្លះអំពី សៀវភៅសន្សំរបស់ពួកគេ។ តើពួកគេសន្សំបានប៉ុន្មានហើយ?

✎ តើពួកគេបានកត់វាទុកក្នុងសៀវភៅរបស់ពួកគេដែរឬទេ?
នៅលើក្តារខៀនអ្នករៀបចំតារាងដើម្បីប្រៀបធៀបករណីសិក្សាខុសៗគ្នា។ កុំទាន់បំពេញវាទុកឱ្យសិស្សផ្តល់ចម្លើយ ប៉ុន្តែប្រសិនបើចាំបាច់ បំពេញតារាងរបស់ពួកគេជាមួយឧទាហរណ៍ ខាងក្រោម។

| ឈ្មោះ | ណារិទ្ធ | ភិន | ស្រីយ៉ា | សុខា | ចិន្តា |
|---|---|---|---|---|---|
| គុណប្រយោជន៍ | ការសន្សំអាចមើលឃើញ<br>● ចិញ្ចឹមគោ | កន្លែងលាក់បាំង | មិនចាំបាច់ធ្វើវាដោយខ្លួនឯង | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានបទបញ្ជា | ប្រាក់ចំណេញខ្ពស់ |

| | | | | | |
|---|---|---|---|---|---|
| គុណវិបត្តិ | បើគោងាប់ ការសន្សំបាត់បង់។ គោអាចត្រូវគេលួច | ងាយស្រួលលួច គ្មានការប្រាក់ | ឪពុកម្តាយអាចត្រូវបានគេបន្លំ | អ្នកមិនអាចប្រៀបធៀបល័ក្ខខ័ណ្ឌផ្សេងៗទៀត | មេគុងទីនមិនអាចទុកចិត្តបានរហូតទេ |
| ដំបូន្មាន | លុះត្រាតែអ្នកចេះពីរបៀបថែរក្សាគោ | យកវាទៅធនាគារទីនោះវាមានសុវត្ថិភាព | ទៅជាមួយគ្នា ដូច្នេះអ្នកដឹងពីរបៀបធ្វើវានៅពេលក្រោយ | ទូរស័ព្ទ ឬទៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផ្សេងទៀត | ជ្រើសរើសអ្នកជិតស្និទ្ធណាម្នាក់មកយាមលុយ |

ដឹកនាំការពិភាក្សាមួយអំពីមធ្យោបាយសន្សំផ្សេងៗ។ វាគ្មានមធ្យោបាយណា "ល្អបំផុត" នោះទេ ប៉ុន្តែអ្នកចង់លើកទឹកចិត្តពួកគេ ឱ្យចេះគិត ឬរិះរករបៀបសន្សំលុយតាមរបៀបដែលខ្លួនគិតថាប្រសើរ។

ចុងបញ្ចប់ វាមានមធ្យោបាយ "មានសុវត្ថិភាពបំផុត" នោះគឺសន្សំក្នុងធនាគារ។ ដូច្នេះអ្នកត្រូវសួរធនាគារខុសៗគ្នាដើម្បីមើលថា តើធនាគារមួយណាមានអត្រាការប្រាក់ខ្ពស់ជាងគេបំផុត និងលក្ខខណ្ឌល្អជាងគេបំផុត។

**បញ្ចប់មេរៀន** ៣០ នាទី

កាលពីសប្តាហ៍មុន យើងបានអនុវត្តការបង្កើតជាធនាគារមួយ។ ថ្ងៃនេះ ធនាគាររបស់យើង ត្រូវបានបង្កើត ប៉ុន្តែយើងត្រូវការទាក់ទាញអតិថិជន។ អ្នកនឹងបង្កើតការផ្សាយពាណិជ្ជកម្មអំពីអត្ថប្រយោជន៍នៃការសន្សំ។ ប៉ុន្តែកុំផ្តោតតែលើការសន្សំលុយ គិតអំពីរបស់ផ្សេងៗដែលយើងបានសិក្សានៅមេរៀនមុនៗ រួចមកហើយ។ អនុស្សាវរីយ៍សកម្មភាពល្អៗ (ដូចជាការដុសធ្មេញ ការជួយមនុស្សចាស់) ការជួយថែរក្សាបរិស្ថាន ...។ល។) ការផ្សាយពាណិជ្ជកម្មនេះគឺសម្រាប់ធនាគាររបស់អ្នក។ ដូច្នេះ អ្នកត្រូវការផ្តល់ការគាំទ្រទៅលើសារៈសំខាន់ ក្នុងការសន្សំរបស់របរ និងប្រើប្រាស់ឱ្យចំទិសដៅ។

ពិចារណាអំពី ៖

- ឃ្លាលើទឹកចិត្តក្នុងការសន្សំដែលងាយស្រួលចាំ
- ឈ្មោះ និងទីតាំងល្អសម្រាប់ធនាគាររបស់អ្នក
- របៀបធ្វើឱ្យផ្ទាំងរូបភាពមានភាពទាក់ទាញ

អ្នកក៏អាចយកផ្ទាំងរូបភាពទៅផ្ទះដើម្បីបញ្ចប់វា។ នៅពេលក្រោយ យើងនឹងបង្ហាញផ្ទាំងរូបភាព ទាំងអស់។

## សេចក្តីណែនាំគ្រូ

នៅក្នុងវេបសាយ http://www.artofangkor.com/ccc/ មានរូបភាពជាច្រើនអំពីលុយរៀល បច្ចុប្បន្ន និងលុយពីជំនាន់មុន។

១. ណារិទ្ធ រស់នៅជាមួយគ្រួសារនៅខេត្តកំពង់ស្ពឺ។ ពួកគេមានដីស្រែបង្ករ។ ឆ្នាំនេះ ការប្រមូលផលបានល្អ ហើយវាច្រើនជាងអ្វីដែលយើងត្រូវការទុកអាហារសម្រាប់គ្រួសារទាំងមូល។ ដូច្នេះវាក៏នៅសល់ស្រូវខ្លះផងដែរ! ឪពុករបស់គាត់បានយកទៅលក់នៅផ្សារ ហើយលុយដែលគាត់ទទួលបាន គាត់យកទៅទិញគោមួយក្បាល។ ឪពុករបស់គាត់និយាយថា៖ "នេះជាមធ្យោបាយដ៏ល្អមួយដើម្បីសន្សំលុយ ពីព្រោះគោអាចផ្តល់អោយយើងនូវអាហារ" ។

តើអ្នកគិតយ៉ាងដូចម្តេចដែរ? តើជាមធ្យោបាយនេះល្អក្នុងការសន្សំលុយឬ?

---

២. គ្រួសាររបស់ ភិន រស់នៅខេត្តបាត់ដំបង។ វាគឺជាគ្រួសារដ៏ធំមួយ ពីព្រោះមីង និងពូរបស់នាងជាមួយកូនៗរបស់ពួកគាត់ក៏រស់នៅក្នុងផ្ទះនោះដែរ។ ម្តាយរបស់ ភិន រកលុយបានយ៉ាងច្រើនកាលពីខែមុន។ ការរកស៊ីបានទទួលផលល្អ ។ គាត់ចង់ទុកលុយខ្លះសម្រាប់ពេលមានឧបសគ្គ ហើយគាត់គិតពីមធ្យោបាយល្អក្នុងការសន្សំវាផងដែរ។ គាត់និយាយថា: "ខ្ញុំនឹងទុកវានៅក្រោមខ្នើយរបស់ខ្ញុំ" គ្មាននរណាម្នាក់ឃើញវាទេ! តើនេះជាជម្រើសដ៏ឈ្លាសវៃឬ? តើអ្នកនឹងធ្វើបែបណា?

---

៣. រស់នៅក្នុងទីក្រុងភ្នំពេញ ម្តុំបឹងត្របែក គ្រួសាររបស់ស្រីយ៉ា និងភាព មានគម្រោងធំៗជាច្រើន។ ពួកគេបានទទួលដំណឹងពីធនាគារ អេអិនហ្សិត (ANZ) ហើយចង់យកលុយទៅផ្ញើរធនាគារ។ ឪពុកម្តាយរបស់ពួកគេមានការបារម្ភក្រៃលែង ព្រោះពួកគេមិនដឹងពីរបៀបក្នុងការធ្វើវា។ សំណាងល្អ អ្នកជិតខាងដឹងអំពីបញ្ហានេះ ហើយស្ម័គ្រចិត្តយកលុយទៅធនាគារ ។ តើនេះជាជម្រើសល្អឬ? តើអ្នកនឹងប្រាប់អ្វីទៅកាន់ឪពុកម្តាយរបស់ស្រីយ៉ាង និងភាព?

---

៤. សុខា ធ្វើចំការជាមួយឪពុករបស់គាត់នៅបាវាយ។ ពួកគេបានលឺថា ចំការជិតគ្នានឹងដាក់លក់។ ដោយសារតែគ្រួសាររបស់សុខាមិនមានលុយគ្រប់គ្រាន់ ពួកគេចង់ខ្ចីលុយមួយចំនួន។ ឪពុករបស់គាត់បានសម្រេចចិត្តយកមាសសន្សំរបស់គាត់ទៅលក់នៅផ្សារ។ នេះជាកន្លែងតែមួយគត់ដែលមាននៅបាវាយ ដូច្នេះវាមិនមានជម្រើសច្រើននោះទេ ប៉ុន្តែឪពុករបស់គាត់ជឿថា វាជាកន្លែងដ៏ល្អមួយ ព្រោះគាត់ស្គាល់ម្ចាស់។ តើសំណួរអ្វីខ្លះដែលអ្នកចង់សួរទៅកាន់ឪពុករបស់សុខា ឬ កន្លែងទិញ-លក់មាស?

---

៥. ឪពុកម្តាយរបស់ចិន្តា បានលក់គោ។ ឪពុកគាត់និយាយថា គោមានជម្ងឺ ហើយវាអាចស្លាប់។ ឥឡូវនេះ ពួកគេត្រូវសម្រេចចិត្តប្រើលុយដែលបានពីការលក់គោនេះលេងតុងទីន។ មេតុងទីនជាអ្នករស់នៅភូមិជាដៃ។ តើដំបូន្មានអ្វីដែលអ្នកអាចអោយទៅឪពុកម្តាយរបស់ចិន្តា?

---

# មេរៀនទី ៨: សង្កេត

🕑 រយៈពេលបង្រៀនៈ ១ ម៉ោង ៣០ នាទី

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន
- សំណួរ សម្រាប់សកម្មភាពត្រូវ  នឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរសិក្សាលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ។
- ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)
- រៀបចំបន្ទប់រៀនៈ តុ កៅអី ក្ដារខៀន។ល។

📖 សម្ភារឧបទេស ធនធានដែលត្រូវការ

ឯកសារសម្រាប់សិស្សទី ៨

☼ វត្ថុបំណងៈ

នៅពេលរៀនមេរៀននេះចប់សិស្សទាំងអស់អាច ៖

- បង្កើតការស្ទង់មតិជាមួយសំណួរបិទ និងសំណួរបើក អំពីទម្លាប់ក្នុងការសន្សំ និងចំណាយ
- រៀបចំកម្រងសំណួរមួយដោយបង្កើតតំបន់ស្រាវជ្រាវ

**ចំណាងជើងមេរៀនទី ៨: សង្កេត** 🕑 ១០ នាទី

**សេចក្ដីផ្ដើម**

យើងនឹងលេងល្បែងកំសាន្តជាមួយលេខ។ ខ្ញុំបានសន្សំរបស់ជាច្រើន ហើយខ្ញុំនឹងហៅជា លេខ។ ពេលអ្នកឮពីចំនួនលេខនោះ អ្នកត្រូវបញ្ចូលគ្នាជាក្រុម និងបង្កើតជាលេខនោះដោយ កាន់ដៃគ្នា។ ឧទាហរណ៍ ៖ ខ្ញុំបានសន្សំអនុស្សាវរីយ៍ល្អចំនួន ៧។ សិស្សត្រូវបង្កើតជាលេខ ៧យ៉ាងធំមួយ។ បែងចែកសិស្សជាក្រុមដែល មានគ្នា១០នាក់ បើមិនដូច្នោះទេក្រុមនឹងមានទំហំធំពេក។

ខ្ញុំបានសន្សំគោ ៣ក្បាល - ខ្ញុំបានសន្សំសកម្មភាពល្អ៩ដង - ខ្ញុំបានសន្សំសម្លៀកបំពាក់ស្អាត ៤កំប្លេ - ខ្ញុំបានសន្សំកំប៉ុងចំនួន ៨ ទុកសម្រាប់រំលោយធ្វើម្ដងទៀត។

**សកម្មភាពសំខាន់** ⌚ ៦០ នាទី

នៅក្នុងសប្តាហ៍នេះ យើងនឹងធ្វើការអង្កេតមួយ។ សម្រាប់ម៉ូឌុលបំណិនជីវិតនេះ យើងចង់ដឹង ពីទម្លាប់ក្នុងការសន្សំ និងការចំណាយ និងចំណេះដឹងពីសិស្ស ហើយយើងត្រូវការអ្នកអង្កេតដ៏ល្អដូចជាពួកអ្នកទាំងអស់គ្នា ដើម្បីធ្វើការពិនិត្យពិច័យ។ នៅពេលដែលអ្នកចង់ប្រមូលព័ត៌មានពីក្រុមមួយ អ្នកត្រូវការសួរមនុស្សឱ្យបានច្រើននាក់ ឬពីរនាក់។ មានវិន័យមូលដ្ឋានខ្លះ។

សរសេរពីវិន័យមូលដ្ឋាន និងឧទាហរណ៍នៅលើក្តារខៀន

- ពន្យល់តើការស្ទង់មតិនិយាយអំពីអ្វី
- កុំធ្វើវាយូរពេក
- ប្រើប្រភេទសំណួរខុសៗគ្នា (សំណួរបិទ និងសំណួរបើក)

ឧទាហរណ៍ពីសំណួរបើក ៖

- តើអ្នកអាចប្រាប់ពីរបស់មួយចំនួនដែលអ្នកសន្សំ បានដែរឬទេ?
- ហេតុអ្វីអ្នកសន្សំវា?
- តើអ្នកណាខ្លះ ក្នុងគ្រួសាររបស់អ្នក ដែលធ្វើការសន្សំអ្វីមួយ?

ឧទាហរណ៍ពីសំណួរបិទ ៖

- តើអ្នកប្រើលុយទិញស្ករគ្រាប់ប៉ុន្មានដង?
  - ច្រើនជាង ៥ដងក្នុងមួយសប្តាហ៍
  - ចន្លោះ ២ និង ៥ដងក្នុងមួយសប្តាហ៍
  - តិចជាង ២ដងក្នុងមួយសប្តាហ៍
  - មិនដែលសោះ

បង្កើតសំណួរដែលចាប់ផ្តើមដោយពាក្យ *ពេលណា ហេតុអ្វី ឯណា អ្វីខ្លះ និង ដូចម្តេច*។ សរសេរ សំណួរមួយដែលចាប់ផ្តើមដោយពាក្យ *ពេលណា ហេតុអ្វី ឯណា អ្វីខ្លះ* ក្នុងសៀវភៅសរសេររបស់អ្នក។

តើនរណាអាចឱ្យឧទាហរណ៍សំណួរទាក់ទងនឹងប្រធានបទការសន្សំ និងការចំណាយដែល ចាប់ផ្តើមដោយពាក្យ *ពេលណា*? តើនរណាអាចឱ្យឧទាហរណ៍មួយ អំពីសំណួរបិទ?

អ្នកអាចបង្កើតជាក្រុមដែលមានសមាជិក៤នាក់ និងគិតអំពីសំណួរដែលចង់បង្កើត។ ប្រើឯកសារសម្រាប់សិស្សទី៨ជាការណែនាំ ហើយឆ្លើយនូវសំណួរទាំងអស់មុនពេលអ្នកបង្កើតកម្រងសំណួរ។ ប្រសិនជាអ្នកបានបញ្ចប់នូវសំណួរទាំងឡាយ អ្នកអាចសាកល្បងអនុវត្តជាមួយសិស្សក្នុងថ្នាក់នេះ។

*ប្រសិនបើអាច អ្នកអាចប្រាប់សិស្សឱ្យប្រើបន្ទប់កុំព្យូទ័រ ដើម្បីសរសេរនូវកម្រងសំណួររបស់ពួកគេ មួយច្បាប់ឱ្យបានត្រឹមត្រូវ។*

តើនរណាដែលដឹងរួចហើយថា ថ្នាក់មួយណាដែលខ្លួនត្រូវធ្វើការអង្កេត?

សរសេរនូវថ្នាក់ ដូច្នេះវានឹងមិនត្រួតគ្នា

ឱ្យឯកសារសម្រាប់សិស្សទី ៨ទៅកាន់សិស្ស ដើរជុំវិញដើម្បីឆ្លើយសំណួរ។

**បញ្ចប់មេរៀន** ២០ នាទី

ឱ្យសិស្សមួយចំនួនប្រាប់ពីសំណួររបស់ពួកគេទៅកាន់ក្រុមផ្សេងទៀត។ វាជាការប្រសើរបើហៅសិស្សដែលអ្នកបានសង្កេត និងអ្នកដែលបានបង្កើតនូវសំណួរល្អ ជាគំរូដល់ក្រុមដទៃ។ នៅសប្តាហ៍ក្រោយ អ្នកនឹងប្រតិបត្តិកម្រងសំណួររបស់អ្នក។ មនុស្សទាំងអស់ក្នុងក្រុម ត្រូវតែចូលរួម ប៉ុន្តែអ្នកអាចចែកកិច្ចការគ្នា។ អ្នកត្រូវការមនុស្សតែម្នាក់ ឬពីរនាក់ប៉ុណ្ណោះ សម្រាប់ការសម្ភាសន៍នីមួយៗ ដូច្នេះអ្នកអាចបែងចែកថ្នាក់ដែលអ្នកចង់អង្កេតជាពីរ ឬបីក្រុមតូចៗ។ មេរៀនបន្ទាប់ យើងនឹងពិនិត្យមើលថា តើដំណើរការនៃការស្ទង់មតិប្រព្រឹត្តទៅយ៉ាងដូចម្តេច និងអ្វីដែលយើងរៀនបានពីលទ្ធផលរបស់យើង។

ប្រសិនជាអ្នកនៅសល់ពេល អ្នកអាចលេងល្បែងកំសាន្ត "សន្សំអ្វី?" ពីមេរៀនទី៣។ អនុញ្ញាតឱ្យសិស្សប្រាប់អំពីអ្វីដែលពួកគេចង់សន្សំ។

ថាឡើងវិញ ពួកគេត្រូវតែបញ្ចប់ការស្ទង់មតិរបស់ពួកគេឱ្យបានមុនសប្តាហ៍ក្រោយ។ សប្តាហ៍ ក្រោយ យើងនឹងវិភាគអំពីលទ្ធផលរបស់យើង។

## សេចក្តីណែនាំគ្រូ

- ធ្វើការត្រួតពិនិត្យក្រុមខុសៗគ្នា។ សម្រាប់ការអង្កេតដែលល្អ វាមានសារៈសំខាន់ដែលពួកគេលាតត្រដាងពីការស្ទង់មើលមតិរបស់ពួកគេ។ ក្រុមនីមួយៗត្រូវសម្ភាសកម្រិតថ្នាក់ផ្សេងៗគ្នា។ ដូច្នេះ វាប្រហែលជាមានសារប្រយោជន៍ ដើម្បីសរសេរបញ្ជីមួយនៃក្រុមទាំងអស់និង តារាងពេលវេលានៃកំរិតថ្នាក់ណាមួយដែលពួកគេចង់សម្ភាស។

- អំឡុងពេលដែលមានការប្រជុំទូទៅជាមួយលោកនាយក និង/ឬជាមួយគ្រូ អ្នកប្រហែលជា ត្រូវការសួរពួកគេ ថាតើពួកគេយល់ស្របជាមួយការសម្ភាសដែរឬទេ។ បញ្ហានេះ គ្រូៗត្រូវតែដឹង។ នេះក៏ជាវេលាដ៏ល្អដើម្បីសួរពួកគេ ថាតើសិស្សអាចបង្ហាញពីសេចក្តីសន្និដ្ឋាន ចុងក្រោយរបស់ពួកគេទៅកាន់កម្រិតថ្នាក់នេះដែរឬទេ។ កាលវិភាគនៃការបង្ហាញនេះ នឹងត្រូវធ្វើនៅពេលក្រោយ។



# សង្កេត

ដូច្នេះអ្នកចង់ដឹងពីទម្លាប់សន្សំ និងចំណាយឬ? ប្រសិនបើអ្នកចង់ធ្វើការសង្កេតដ៏ល្អមួយ ដំបូងអ្នកត្រូវគិតអំពី *ក្រុមគោលដៅ*។ ក្នុងការសិក្សានេះ គឺត្រូវតែជានណារម្នាក់ដែលមកពីសាលារៀនរបស់យើង។
តើថ្នាក់មួយណាដែលអ្នកចង់ដឹងបន្ថែមទៀត?



________________________________________

ឥឡូវនេះ យើងបានកំណត់ក្រុមគោលដៅ យើងត្រូវគិតពីការពន្យល់សម្រាប់ពួកគេ។
តើអ្វីដែលយើងនឹងប្រាប់ពួកគេ?
ពិចារណាអំពីហេតុអ្វីអ្នកចង់ធ្វើការស្ទង់មតិនេះ និងតើអ្នកនឹងប្រើចម្លើយពួកគេនៅកន្លែងណា? តើវាមានលក្ខណៈ អនាមិក (មិនបញ្ចេញឈ្មោះ) និង តើពួកគេត្រូវការសរសេរ ឬនិយាយ?

សួស្តី យើងជា ________________________________________

យើងចង់សួរអ្នកនូវសំណួរខ្លះអំពី ____________________________________

______________________________________________________

នេះជាកិច្ចការសាលារបស់ពួកយើងអំពីការសន្សំ និងការចំណាយ។ យើងនឹងប្រើចម្លើយរបស់អ្នកដើម្បីបង្កើត

______________________________________________________

របស់ផ្សេងទៀតដែលយើងត្រូវការដឹងគឺ __________________________________

តើអ្នកមានសំណួរអ្វីបន្ថែមទៀតទេ? ____________________________________



# គិតពី

អញ្ចឹង អ្នកត្រៀមខ្លួនរួចហើយមែនទេ? ឥឡូវចូរគិតពី 'អ្វីដែលយើងត្រូវការដឹង?'
អ្នកចង់ដឹងពីទម្លាប់សន្សំ និងចំណាយ... ប៉ុន្តែ តើនេះមានន័យយ៉ាងដូចម្តេច?
តើអ្នកអាចសរសេរនូវអ្វីដែលអ្នកប្រុងនឹងអង្កេតចំៗដែរឬទេ?
យើងនឹងអង្កេតអំពី *អ្វីខ្លះ ដូចម្តេច ពេលណា ហេតុអ្វី ឯណា...*

*ឧទាហរណ៍: តើសិស្សទិញអ្វី ជាមួយលុយដែលពួកគេបានសន្សំ?*

______________________________________________________

______________________________________________________

______________________________________________________

______________________________________________________

______________________________________________________

# មេរៀនទ ៩: បទបង្ហាញ

🕑 រយៈពេលបង្រៀន: ១ ម៉ោង ៣០ នាទី

☑ ការត្រៀមលក្ខណៈ:

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន
- សំណួរ សម្រាប់សកម្មភាពគ្រូវ
  នឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរសិក្សាលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ។
- ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)

🕮 សម្ភារឧបទេស/ធនធានដែលត្រូវការ

១. ក្រដាសធំ ឬ តូចៗដែលបិទជាប់ជាមួយគ្នា។ សិស្សអាចប្រើវាសម្រាប់ធ្វើបទបង្ហាញ

២. ឯកសារសម្រាប់សិស្ស ៩ខ ជាមួយគម្រោងការងារសម្រាប់ការធ្វើបទបង្ហាញ

៣. ឯកសារសម្រាប់សិស្ស១០ សម្រាប់គ្រូបន្ទុកថ្នាក់ដែលសិស្សនឹងបង្ហាញពីលទ្ធផលរបស់ពួកគេ

☼ វត្ថុបំណង:

នៅពេលរៀនមេរៀននេះចប់សិស្សទាំងអស់អាច ៖

- បង្ហាញពីលទ្ធផលរបស់ពួកគេក្នុងលក្ខណៈដែលអាចមើលឃើញ តាមរយៈតារាង ឬក្រាប
- វិភាគលទ្ធផលរបស់ពួកគេទៅលើចក្ខុវិស័យរួម ភាពដូចគ្នា និងខុសគ្នា
- ធ្វើបទបង្ហាញលទ្ធផលចុងក្រោយទៅកាន់ថ្នាក់ដទៃ

**ចំណាងជើងមេរៀនទី ៩: បទបង្ហាញ** 🕑 ១០ នាទី

**សេចក្ដីផ្ដើម**

យើងបានសន្សំលុយ និងទៅផ្សារ។ យើងទិញអ្វីដែលយើងអាចប្រើ ឬលេងបាន។ ខ្ញុំនឹងបង្ហាញ អ្នកពីអ្វីដែលខ្ញុំចង់ទិញ ប៉ុន្តែខ្ញុំនឹងបង្ហាញវាក្នុងលក្ខណៈយឺតៗ។ ប្រសិនបើអ្នកដឹងថានោះជាអ្វី អ្នកអាចលើកដៃ ហើយឆ្លើយប្រាប់ខ្ញុំ។ ចូរប្រយ័ត្ន

អ្នកអាចទាយបានតែមួយដងប៉ុណ្ណោះ។

សម្ដែងជាលេងបាល់ទាត់។ អ្នកបានទិញស្បែកជើងសម្រាប់លេងបាល់ទាត់ថ្មីមួយគូ។ ធ្វើ ចលនាយឺតៗ។

ឥឡូវខ្ញុំនឹងជ្រើសរើសសិស្ស ៥នាក់ ដែលអាចបង្ហាញខ្ញុំនូវអ្វីមួយដែលគេបានទិញក្នុងចលនា យឺតៗ។ ប្រសិនបើអ្នកដឹងថាពួកគេទិញអ្វី លើកដៃហើយឆ្លើយ។ ប្រសិនបើអ្នកឆ្លើយត្រឹមត្រូវ អ្នកអាចប្ដូរជាមួយនឹងបុគ្គល ដែលអ្នកបានទាយ ហើយឡើងមកបង្ហាញយើងពីអ្វីដែលអ្នកបានទិញវិញម្ដង។

**សកម្មភាពសំខាន់** ⏲៦០ នាទី

ថ្ងៃនេះ យើងនឹងមើលការស្ទង់មតិរបស់យើង ព្រមទាំងស្វែងរករបៀបធ្វើបទបង្ហាញពីលទ្ធផល របស់ពួកយើង។ ប៉ុន្តែមុននឹងធ្វើការនេះ យើងត្រូវការវិភាគទិន្នន័យរបស់យើង។

តើអ្នកណាដឹងថា "ការធ្វើវិភាគ" ជាអ្វី?

ការវិភាគគឺជាការអាននូវព័ត៌មានទាំងអស់ និងពិនិត្យមើល ថាតើអ្នកអាចបង្កើតសេចក្ដីសន្និដ្ឋាន អ្វីខ្លះ។ មុនពេលយើងមើលចម្លើយរបស់យើង យើងត្រូវការប្រមូលព័ត៌មានទាំងអស់ចូលគ្នា ដូច្នេះវាមានភាពច្បាស់លាស់សម្រាប់អ្នកគ្រប់ៗគ្នា។ មានមធ្យោបាយខុសគ្នាក្នុងការធ្វើវា *(មើលសេចក្ដី ណែនាំគ្រូ)*។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកត្រូវធ្វើជា*សេចក្ដីសរុបច្បាស់លាស់*។

បង្ហាញឧទាហរណ៍ពីក្នុងឯកសារសម្រាប់សិស្ស ៩ក នៅលើក្ដារខៀន។

ពន្យល់ពីភាពខុសប្លែកគ្នា និងសួរសិស្ស អំពីក្រាប។

តើអ្នកឃើញថាមានកុមារីប៉ុន្មាននាក់ដែលបានសន្សំលុយក្នុងមួយខែ?

ភាគច្រើននៃកុមារា តើពួកគេទុកលុយនៅឯណា? (តារាង២)

តើសិស្សអាចសន្សំអ្វី បានច្រើនជាងគេ? និងអ្វីបានតិចជាងគេ? (តារាង៣)

តើមានមនុស្សប៉ុន្មាននាក់ ដែលគិតថាការសន្សំមិនមានសារសំខាន់? (តារាង៤)

វាមានភាពងាយស្រួលក្នុងការប្រើតារាង ឬក្រាប ជាមួយសំណួរដែលមានជម្រើសច្រើន។អ្នកអាចបែងចែកជាកុមារា និងកុមារី ឬតាមអាយុខុសៗគ្នា។

សំណួរបើកមានភាពពិបាកក្នុងការបង្ហាញ។ អ្នកអាចជ្រើសរើសសរសេរចម្លើយទាំងអស់ និង ពិនិត្យមើលថាចម្លើយមួយណាដែលដូចគ្នាតិច ឬច្រើន។

អ្នកអាចប្រើឯកសារសម្រាប់សិស្ស ៩ខ ជាមួយចម្លើយនេះ។ វាផ្ដល់នូវដំបូន្មានអំពីជំហានដែល អ្នកអាចធ្វើបាន។ នៅចុងបញ្ចប់ ពេលអ្នកចាប់ផ្ដើមអនុវត្តនូវការបង្ហាញរបស់អ្នក វាមានការ រៀបរាប់អំពីបញ្ហាសំខាន់មួយចំនួន។

- អ្នកគ្រប់គ្នាត្រូវតែចូលរួមក្នុងការធ្វើបទបង្ហាញ ដូច្នេះ តើនរណាដែលនឹងនិយាយពាក្យថាអំពី*អ្វី*?
- អ្នកត្រូវប្រើមធ្យោបាយខុសៗគ្នាដើម្បីបង្ហាញ និយាយ ប៉ុន្តែក៏អាចបង្ហាញរបស់អ្វីមួយ ឬសួរសំណួរមួយចំនួនផងដែរ។ ចូរចងចាំ ៖ អ្នកបង្រៀនយើង ដូច្នេះបង្ហាញថាអ្នក គឺជាគ្រូ។ ឈរត្រង់ និយាយខ្លាំងៗ ផ្លាស់ប្ដូរនិងប្រើភាសាកាយវិការ មើលមនុស្ស ឱ្យចំភ្នែក។



*អ្នកចូលរួម និយាយ បង្ហាញ សួរ ភាសាកាយវិការ*

ចែកឯកសារសម្រាប់សិស្ស ៩ខ ទៅឱ្យសិស្ស ពួកគេ នឹងចាប់ផ្ដើមធ្វើការសង្កេត។*នេះជាឱកាសល្អក្នុងការបំពេញតារាងវាយតម្លៃសិស្ស។*

យើងមានរយៈពេល៦០នាទី ដើម្បីរៀបចំបន្ទាប់ពីនេះ ខ្ញុំនឹងស្នើសុំមួយក្រុម ឬពីរក្រុមមកបង្ហាញនិងពន្យល់ពីបទបង្ហាញរបស់ពួកគេ។

**បញ្ចប់មេរៀន** ២០ នាទី

តើមានក្រុមណាមួយ ស្ម័គ្រចិត្តចាប់ផ្ដើមឡើងមកធ្វើការបង្ហាញទេ?

*ចំណាំ ៖ វាមិនចាំបាច់ដែលសិស្សត្រូវបង្ហាញឱ្យរួចរាល់ ប៉ុន្ដែវាអាចមានប្រយោជន៍សម្រាប់ ក្រុមដទៃដែលបានមើលឃើញឧទាហរណ៍នៃការធ្វើការបង្ហាញ។*

ក្នុងសប្ដាហ៍ក្រោយ ខ្ញុំនឹងសួរគ្រូដទៃទៀត ថាតើអ្នកអាចធ្វើបទបង្ហាញក្នុងថ្នាក់ដែលអ្នកបាន អង្កេត។ នេះមានន័យថា អ្នកទៅថ្នាក់ដទៃ ព្រមទាំងប្រាប់ពួកគេអំពីការស្រាវជ្រាវ។

វាមានសារៈសំខាន់ណាស់ដែលអ្នកចែករំលែកចំណេះដឹងរបស់អ្នកអំពីការសន្សំ និងការចំណាយជាមួយសិស្សដទៃទៀត ដូច្នេះយើងទាំងអស់គ្នាអាចទទួលបានផលប្រយោជន៍ និង ដឹងអំពីមូលហេតុដែលយើងត្រូវសន្សំ និងរបៀបសន្សំដែលមានប្រសិទ្ធភាព។

## សេចក្ដីណែនាំគ្រូ

វាអាចមានការពិបាកក្នុងការបង្ហាញលទ្ធផលក្នុងក្រាបដូចនេះ ៖






សិស្សដែលចេះកុំព្យូទ័រអាចធ្វើតារាងនេះនៅក្នុងបន្ទប់កុំព្យូទ័រ ប៉ុន្ដែប្រសិនបើអ្នក មិនច្បាស់អំពីវា អ្នកគួរតែជ្រើសរើសយករបៀបបកស្រាយជាការ "សរសេរ" ដូចតារាងខាងក្រោម ៖

| | កុមារី | កុមារី | .................. |
|---|---|---|---|
| សំណួរទី ១ | ១៣ | ១៤ | |
| សំណួរទី ២ | | | |

ដោយហេតុថាមានក្រុមជាច្រើន ក្រុមទាំងអស់មិនអាចបង្ហាញលទ្ធផលរបស់ពួកគេក្នុងថ្នាក់នេះ។ វានឹងល្អប្រសិនបើពួកគេអាចបង្ហាញវាទៅក្រុមដែលពួកគេបានអង្កេត។ និយាយជាមួយលោក នាយកសាលាអំពីបញ្ហានេះ។ ក្នុងអំឡុងពេលសប្តាហ៍ក្រោយ មុនពេលមេរៀនទី ១០ សិស្សទាំងអស់ត្រូវតែបង្ហាញពីលទ្ធផលរបស់ពួកគេទៅកាន់កម្រិតថ្នាក់ខុសៗគ្នា។ នេះនឹងចំណាយតែរយៈពេល១០នាទីសម្រាប់ការបង្ហាញនីមួយៗ ដូច្នេះវានឹងមិនពិបាកក្នុងការរៀបចម្លើយ។

ការបង្ហាញក្នុងក្រុមដទៃអាចដាក់ពិន្ទុដោយគ្រូ ដែលមានឯកសារសម្រាប់សិស្សទី១០ ។ នេះគឺជា ពាក្យគាត់ដែលទាក់ទងនឹងតារាងវាយតម្លៃការសិក្សារបស់សិស្ស។

- o និយាយច្បាស់លាស់ --- ទំនាក់ទំនង
- o មានភាសាកាយវិការវិជ្ជមាន --- ឥរិយាបថវិជ្ជមាន
- o បង្ហាញទំនុកចិត្ត --- ទុកចិត្តខ្លួនឯង / ជឿជាក់ខ្លួនឯង
- o បង្ហាញចំណេះដឹង --- ការដោះស្រាយបញ្ហា

**ឧទាហរណ៍ទី ១ ៖** លុយដុល្លារបានចាយ និងសន្សំក្នុងមួយខែ



**ឧទាហរណ៍ទី ២ ៖** តើអ្នកសន្សំលុយរបស់អ្នកនៅឯណា?



ឧទាហរណ៍ទី ៣ ៖ តើអ្នកសន្សំអ្វី?




ឧទាហរណ៍ទី ៤ ៖ ហេតុអ្វីបានជាអ្នកគិតថាវាមានសារៈសំខាន់ក្នុងការសន្សំ?

| ចម្លើយ | នាក់ |
|---|---|
| ដើម្បីទិញអ្វីដែលល្អនិងមានតម្លៃ | ៥ |
| ដើម្បីមានលុយនៅពេលមានអ្វីកើតឡើងជាយថាហេតុ | ៤ |
| ដើម្បីជួយគ្រួសាររបស់ខ្ញុំនៅពេលត្រូវការលុយ | ២ |
| ដើម្បីរៀនអំពីវា ដូច្នេះខ្ញុំអាចប្រើវានៅពេលក្រោយ | ១ |
| ខ្ញុំមិនដឹង | ៤ |
| វាមិនសូវមានសារៈសំខាន់ | ២ |
| ផ្សេងៗ | ៣ |



# ត្រៀមខ្លួនជាស្រេចដើម្បីធ្វើ

អ្នកទាំងអស់គ្នានឹងមានការបង្ហាញយ៉ាងរំភើបមួយអំពីការស្ទង់មតិរបស់អ្នក។ ដើម្បីធ្វើដូច្នេះ អ្នកនឹងត្រូវការធ្វើគម្រោងល្អមួយ។ មួយជំហានម្តង មួយជំហានម្តង យើងនឹងប្រាកដថាវានឹងទទួលបានជោគជ័យ។ សំណាងល្អ!

១. យកក្រដាសទាំងអស់ពីការអង្កេតរបស់អ្នក ហើយប្រាប់អ្នកដទៃអំពីដំណើរការនៃ **<u>ការអង្កេត</u>**របស់អ្នក ។ តើមនុស្សប៉ុន្មាននាក់ដែលអ្នកបានសួរ? តើមានចម្លើយជាច្រើនដូចគ្នាឬ តើមនុស្សទាំងអស់គ្នាឆ្លើយតបខុសៗគ្នាទេ?

២. បែងចែកចម្លើយជា *សំណួរមានជម្រើសច្រើន* និង *សំណួរបើក*។

ចម្លើយជម្រើសច្រើនអាចត្រូវបានបង្ហាញក្នុងលក្ខណៈជាក្រាប ។

តើអ្នកដឹងថាណាមួយណាទេ? ប្រហែលជាអ្នកអាចមើលឯកសារចែកសិស្ស ១៣ ជាគំរូ។

សំណួរបើកអាចត្រូវបានសរសេរក្នុងបញ្ជីមួយ

ចងចាំ: *ព្យាយាមបំព្រួញចម្លើយ និង បញ្ចូលចម្លើយដែលដូចគ្នាតិច ឬច្រើន*

ហេតុអ្វីបានជាអ្នកគិតថាវាមានសារៈសំខាន់ក្នុងការសន្សំ?

| ចម្លើយ | នាក់ |
|---|---|
| ដើម្បីទិញអ្វីដែលល្អនិងមានតម្លៃ | 5 |
| ដើម្បីមានលុយនៅពេលមានអ្វីកើតឡើងដោយមិនបានដឹងមុន | 4 |
| ដើម្បីជួយគ្រួសាររបស់ខ្ញុំនៅពេលត្រូវការលុយ | 2 |
| ដើម្បីរៀនសិក្សា ដូច្នេះខ្ញុំអាចប្រើវានៅពេលក្រោយ | 1 |
| ខ្ញុំមិនដឹង | 4 |
| វាមិនសូវមានសារៈសំខាន់ | 2 |
| ផ្សេងៗ | 3 |




៣. មនុស្សពីរនាក់មកពីក្រុមរបស់អ្នកអាចធ្វើ<u>ក្រាប</u> ហើយមនុស្សពីរនាក់ទៀតអាចសរសេរទៅ........

ប្រយ័ត្ន: *អ្នកត្រូវធ្វើវាអោយមានភាពទាក់ទាញ ជាមួយពណ៌ និងប្រហែលជាគំនូរខ្លះ* ។ *អ្នកដទៃនឹងមើលវា ដូច្នេះវាត្រូវតែល្អ។*

សម្រាប់បញ្ហានេះ អ្នកអាចប្រើ *ក្រដាសសបិទភ្ជាប់គ្នាដើម្បីធ្វើជាប័ណ្ណប្រកាសមួយ* ។

៤. រួចរាល់ហើយឬនៅ? ល្អ។ ឥឡូវនេះ អ្នកមានចម្លើយទាំងអស់ អ្នកអាចគិតអំពី**<u>សេចក្តីសន្និដ្ឋាន</u>** ។ តើអ្វីខ្លះជាការសន្និដ្ឋានទូទៅអំពីការសន្សំ និងការចំណាយក្នុងក្រុមនេះ។ សរសេរយ៉ាងតិច៣ នៅលើក្រដាសធំមួយ។ នេះជាអ្វីដែលអ្នកអាចបង្ហាញទៅកាន់ថ្នាក់ដែលអ្នកបានសម្ភាសន៍។



៥. ចុងក្រោយ អ្នកអាចគិតអំពី**ជំហ្វូន្នាន**។ សម្រាប់ការនេះ អ្នកនឹងត្រូវការរបស់ដែលអ្នកបាន រៀនក្នុងម៉ូឌុលបំណិនជីវិតនេះ។

ពន្យល់ទៅកាន់សិស្សដទៃ:

*ហេតុអ្វីវាមានសារសំខាន់ក្នុងការសន្សំ?*

*តើអ្វីជាភាពខុសគ្នារវាង ចំណង់ និងតម្រូវការ?*

*តើប្រព័ន្ធសន្សំណាមួយដែលមានក្នុងតំបន់របស់អ្នក?*

*តើអ្វីខ្លះជាមធ្យោបាយល្អក្នុងការសន្សំ? ហេតុអ្វី?*

កត់សម្គាល់: អ្នកប្រហែលជាអាចប្រើតារាងចំណង់ និងតម្រូវការ
របស់អ្នក ឬក៏សម្ភារៈផ្សេងៗដែលអ្នកបានធ្វើក្នុងម៉ូឌុលនេះ!

៦. ល្អ! អ្នកស្ទើតែបានបញ្ចប់ការរៀបចំរបស់អ្នក ។
របស់ចុងក្រោយ: តើនរណានឹងនិយាយអ្វី? បែងចែកកិច្ចការ
អ្នកនឹងត្រូវការមនុស្សម្នាក់សម្រាប់ផ្នែកនិមួយៗ ។

| | |
|---|---|
| **ផ្នែកទី ១**<br>**<u>ការអង្កេត</u>** | ពន្យល់អំពីមូលហេតុអ្នកធ្វើការអង្កេត ប្រាប់ពីចំនួនមនុស្សដែលអ្នកបានអង្កេត |
| **ផ្នែកទី២**<br>**<u>លទ្ធផល</u>** | បង្ហាញតារាង និងចម្លើយនៅលើប័ណ្ណប្រកាសធំមួយ ពន្យល់ពីផ្នែកខុសគ្នា |
| **ផ្នែកទី**<br>**៣ <u>សេចក្តីសន្និដ្ឋាន</u>** | ប្រាប់ពីសេចក្តីសន្និដ្ឋាននិងពន្យល់ថាតើអ្នកបានរបស់ទាំងនោះមកដោយរបៀបណា |
| **ផ្នែកទី ៤**<br>**<u>ដំបូន្មាន</u>** | ផ្តល់ដំបូន្មាន តាមសំណួរទី៥ នៅលើឯកសារចែកសិស្សនេះ សួរថា តើពួកគេមានសំណួរដែរឬទេ។ |



៧. ឥឡូវ ចូរអនុវត្ត!
សមាជិកទាំងអស់របស់ក្រុមត្រូវប្រាប់នូវអ្វីដែលពួកគេចង់និយាយ។
ធ្វើពុត ជាការធ្វើបទបង្ហាញដល់ថ្នាក់ទាំងមូល ។
អ្នកត្រូវជួយអ្នកដទៃដោយ ***ការសរសើរ*** និងផ្តល់ដំបូន្មាន ។
ចូរប្រាកដថា ប័ណ្ណប្រកាសរបស់អ្នក បញ្ចប់ក្នុងលក្ខណៈល្អមើល ។
ប្រសិនបើមិនដូច្នោះ យកវាទៅធ្វើនៅផ្ទះ ។

៨. តើអ្នកដឹងថាថ្ងៃណា និងបន្ទប់ណាដែលអ្នកត្រូវធ្វើបទបង្ហាញទេ ?
ខ្ញុំជឿជាក់ថា អ្នកនឹងធ្វើវាបានល្អ ពីព្រោះអ្នកបានរៀបចំយ៉ាងល្អ។
សំណាងល្អ!

# មេរៀនទី ១០: ការសន្សំ

🕑 រយៈពេលបង្រៀន៖ ១ ម៉ោង ៣០ នាទី

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន
- សំណួរ សម្រាប់សកម្មភាពត្រូវ នឹងការបង្រៀនដែរឬទេ ?
- សរសេរសំណួរសិក្សាលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ។
- ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្តារខៀន...)

📖 សម្ភារឧបទេស/ធនធានដែលត្រូវការ

១. ថតចម្លងវិញ្ញាបនប័ត្រការសន្សំសម្រាប់សិស្សគ្រប់គ្នា

☼ វត្ថុបំណង:

នៅពេលរៀនមេរៀននេះចប់សិស្សទាំងអស់អាច ៖

- វាយតម្លៃយុទ្ធវិធីសន្សំរបស់ពួកគេ ទៅលើចំណុចខ្លាំង និងខ្សោយ
- បង្ហាញចំណេះដឹង និងបំណិនរបស់ពួកគេដោយបំពេញតារាងវាយតម្លៃ
- មានទំនុកចិត្តដោយការសរសើរ និងវិញ្ញាបនប័ត្រចុងក្រោយដែលពួកគេបានទទួល

## ចំណាងជើងមេរៀនទី ១០ 🕑 ១០ នាទី

### សេចក្តីផ្តើម

ឱ្យសិស្សទាំងអស់នៅក្នុងរង្វង់មួយ និងប្រាប់ពួកគេឱ្យឈរជិតគ្នាបំផុត។ ជ្រើសរើសអ្នកស្ម័គ្រចិត្តម្នាក់ដែលនៅកណ្តាលរង្វង់។

យើងកំពុងលេងល្បែងកំសាន្តមួយ ដែលលុយត្រូវបានគេលួចបាត់។ ខ្ញុំឱ្យវាទៅនរណាម្នាក់ ក្នុងរង្វង់។ គេនឹងទុកវានៅខាងក្រោយខ្នង ហើងនឹងហុចវាទៅអ្នកដែលនៅជិតគ្នា ខាងឆ្វេង ឬខាងស្តាំ។ មនុស្សដែលនៅកណ្តាល គឺជាប៉ូលីស ហើយត្រូវសង្កេតឱ្យបានល្អ ដើម្បីដឹងថា លុយទៅកន្លែងណា។ មួយសន្ទុះក្រោយមក ខ្ញុំនឹងនិយាយថា "ឈប់" ហើយប៉ូលីសត្រូវស្វែង រកមនុស្សដែលមានលុយនោះ។ ពួកគេមានឱកាសតែម្តងគត់។

## សកម្មភាពសំខាន់ 🕑 ៦០ នាទី

ថ្ងៃនេះ យើងនឹងបញ្ចប់ម៉ូឌុលបំណិនជីវិតនេះ។ យើងបានរៀននូវអ្វីៗជាច្រើន ហើយខ្ញុំនឹងឱ្យអ្នកនូវលំហាត់តូចមួយដើម្បីបញ្ជាក់ចំពោះខ្លួនអ្នក។ ប៉ុន្តែដំបូង វាជាឱកាសដើម្បីមើល ចំនួនដែលយើងសន្សំបាន។ អ្នកគ្រប់គ្នា គួរតែយកសៀវភៅសន្សំចេញមក។



ឱ្យសិស្សឈរជាពីរជួរ បែរមុខរកគ្នា

អ្នករាល់គ្នាត្រូវប្រាប់មនុស្សដែលនៅពីមុខអ្នក អំពីអ្វីដែលអ្នកបានសន្សំ និងរបៀបអ្នកធ្វើវា។

ឆ្លើយសំណួរទាំង ៣នេះ ដែលមាននៅលើក្តារខៀន

១. តើអ្វីដែលដំណើរការល្អក្នុងការសន្សំ និងអ្វីដែលអ្នកអាចធ្វើឱ្យល្អប្រសើរឡើង?

២. តើអ្នកនឹងធ្វើអ្វីជាមួយការសន្សំរបស់អ្នក?

៣. តើរបស់អ្វីបន្ទាប់ទៀត ដែលអ្នកនឹងសន្សំ?

បន្ទាប់ពី៣០វិនាទី ជួរមួយនឹងផ្លាស់ប្តូរជា ២កន្លែង។ នេះមានន័យថា ពួកគេនឹងឈរទល់មុខ មនុស្សខុសៗគ្នា។ ពួកគេត្រូវប្រាប់ចម្លើយរបស់ពួកគេម្តងទៀត និងស្តាប់ចម្លើយពីមនុស្សដទៃ។

តើអ្នកគិតថា នរណាធ្វើបានល្អក្នុងការសន្សំ? ហេតុអ្វី?

អនុញ្ញាតឱ្យសិស្សសរសើរសិស្សដទៃ ដោយឱ្យពួកគេឆ្លើយសំណួរនេះបន្ទាប់ពីល្បែងកំសាន្ត។

ឱ្យសិស្សអង្គុយនៅតាមតុរបស់ពួកគេ និងបង្ហាញការវាយតម្លៃសិស្សដល់ពួកគេ។

ក្នុងក្រដាសវាយតម្លៃនេះ អ្នកនឹងឃើញសំណួរជាច្រើនអំពីប្រធានបទដែលអ្នកបានរៀន។ ព្យាយាមឆ្លើយសំណួរក្នុងលក្ខណៈងាយស្រួលយល់តាមតែអាចធ្វើបាន។

**បញ្ចប់មេរៀន** ២០ នាទី

ថ្ងៃនេះគឺជាមេរៀនចុងក្រោយអំពីការសន្សំ និងការចំណាយ ហើយខ្ញុំគិតថា អ្នកបានធ្វើយ៉ាង ល្អ។ យើងបានរៀននូវអ្វីៗជាច្រើន និងធ្វើសកម្មភាពផ្សេងៗ។

ខ្ញុំសូមផ្តល់ដំបូន្មានដល់អ្នក ឱ្យរក្សាការសន្សំសម្ភារៈសំខាន់ៗសម្រាប់ថ្ងៃដែលមានភ្លៀងខ្លាំង។ អនុស្សាវរីយ៍ លុយ ការប្រព្រឹត្តល្អ និងរបស់ផ្សេងៗ។ ហើយប្រសិនជាអ្នកខ្លាចភ្លេចវា សូមប្រើសៀវភៅសន្សំ។ វានឹងជួយអ្នកឱ្យចាំ និងធ្វើឱ្យជីវិតរបស់អ្នករីកចម្រើន។

សិស្សគ្រប់គ្នាក្នុងថ្នាក់នេះនឹងទទួលវិញ្ញាបនប័ត្រសម្រាប់អ្វីដែលពួកគេបានធ្វើ និងបានរៀន។ ខ្ញុំមានមោទនភាពណាស់ចំពោះអ្នកទាំងអស់គ្នា។

ចែកវិញ្ញាបនប័ត្រដល់សិស្សនីមួយៗ ហើយឱ្យសិស្សទាំងអស់ទះដៃអបអរសាទរ។ ប្រសិនជានៅសល់ម៉ោង អ្នកអាចលេងល្បែងកំសាន្តមួយនៅក្នុងសៀវភៅនេះ។ ប្រហែលជា សិស្សអាចជ្រើសរើស និងពន្យល់។

## សេចក្តីណែនាំគ្រូ

វាមានសារៈសំខាន់ដើម្បីផ្តល់ទំនុកចិត្តដល់សិស្សចំពោះស្នាដៃរបស់ពួកគេ។ អនុញ្ញាតឱ្យសិស្សសរសើរគ្នាទៅវិញទៅមក ដែលវាគឺជាឧបករណ៍ដ៏ល្អមួយសម្រាប់បញ្ហានេះ។

ការវាយតម្លៃសិស្ស

សមាជិកម្នាក់ៗក្នុងក្រុមទទួលបានពិន្ទុចំនួនមួយចំពោះការបង្ហាញនេះ។

គ្រូអាចជ្រើសរើសជម្រើស ៣ ។

☹ = ត្រូវការបំប៉នបន្ថែម

😐 = មធ្យម

☺ = ល្អ

| ឈ្មោះរបស់សិស្ស | ☺ | 😐 | ☹ | មតិយោបល់របស់គ្រូ |
|---|---|---|---|---|
| និយាយច្បាស់លាស់ | | | | |
| មានភាសាកាយវិការវិជ្ជមាន<br>*ឈរត្រង់ ភ្នែកមើលទៅកាន់សិស្សគ្រប់គ្នា* | | | | |
| បង្ហាញទំនុកចិត្ត | | | | |
| បង្ហាញចំណេះដឹងអំពីផ្ទៃករបស់ខ្លួន | | | | |

| ឈ្មោះរបស់សិស្ស | ☺ | 😐 | ☹ | មតិយោបល់របស់គ្រូ |
|---|---|---|---|---|
| និយាយច្បាស់លាស់ | | | | |
| មានភាសាកាយវិការវិជ្ជមាន<br>*ឈរត្រង់ ភ្នែកមើលទៅកាន់សិស្សគ្រប់គ្នា* | | | | |
| បង្ហាញទំនុកចិត្ត | | | | |
| បង្ហាញចំណេះដឹងអំពីផ្ទៃករបស់ខ្លួន | | | | |

| ឈ្មោះរបស់សិស្ស | ☺ | 😐 | ☹ | មតិយោបល់របស់គ្រូ |
|---|---|---|---|---|
| និយាយច្បាស់លាស់ | | | | |
| មានភាសាកាយវិការវិជ្ជមាន<br>*ឈរត្រង់ ភ្នែកមើលទៅកាន់សិស្សគ្រប់គ្នា* | | | | |
| បង្ហាញទំនុកចិត្ត | | | | |
| បង្ហាញចំណេះដឹងអំពីផ្ទៃករបស់ខ្លួន | | | | |

| ឈ្មោះរបស់សិស្ស | ☺ | 😐 | ☹ | មតិយោបល់របស់គ្រូ |
|---|---|---|---|---|
| និយាយច្បាស់លាស់ | | | | |
| មានភាសាកាយវិការវិជ្ជមាន<br>*ឈរត្រង់ ភ្នែកមើលទៅកាន់សិស្សគ្រប់គ្នា* | | | | |
| បង្ហាញទំនុកចិត្ត | | | | |
| បង្ហាញចំណេះដឹងអំពីផ្នែករបស់ខ្លួន | | | | |

| ឈ្មោះរបស់សិស្ស | ☺ | 😐 | ☹ | មតិយោបល់របស់គ្រូ |
|---|---|---|---|---|
| និយាយច្បាស់លាស់ | | | | |
| មានភាសាកាយវិការវិជ្ជមាន<br>*ឈរត្រង់ ភ្នែកមើលទៅកាន់សិស្សគ្រប់គ្នា* | | | | |
| បង្ហាញទំនុកចិត្ត | | | | |
| បង្ហាញចំណេះដឹងអំពីផ្នែករបស់ខ្លួន | | | | |



# ការវាយតម្លៃ "ការសន្សំ និង ការចំណាយ"

១. តើអ្នកអាចរក្សាទុកសៀវភៅសន្សំបានដែរឬទេ? ពិនិត្យមើលថាតើសៀវភៅសន្សំផ្ទាល់ខ្លួនរបស់អ្នកពេញឬទេ ហើយប្រគល់វាទៅគ្រូបន្ទាប់ពីលំហាត់នេះ។
២. តើអ្វីជាភាពខុសគ្នារវាងតម្រូវការ និងចំណង់?
៣. ចូរឱ្យឧទាហរណ៍ ៣អំពីតម្រូវការ និង ៣ទៀតអំពីចំណង់។
៤. ហេតុអ្វីបានជាវាមានសារៈសំខាន់ក្នុងការមានអនុស្សាវរីយ៍សប្បាយៗ?
៥. តើ "ការសន្សំសម្រាប់ថ្ងៃភ្លៀងធ្លាក់ខ្លាំង" មានន័យយ៉ាងដូចម្ដេច?
៦. តើអ្នកអាចគូរទំព័រដំបូងនៃសៀវភៅសន្សំរបស់អ្នក? តើតារាងណាខ្លះដែលអ្នកគួរមាន និងតើអ្នកហៅវាថាយ៉ាងដូចម្ដេច?
៧. ប្រសិនបើខ្ញុំទុកលុយ ២០ដុល្លារ នៅធនាគារ ហើយពួកគេឱ្យអត្រាការប្រាក់ខ្ញុំ ៥%។ ក្នុងមួយឆ្នាំខ្ញុំមានដុល្លារដុល្លារប៉ុន្មាន? តើខ្ញុំមានលុយប៉ុន្មាននៅមួយឆ្នាំក្រោយ? ចូរពន្យល់ពីការគណនារបស់អ្នក។
៨. ចូរឱ្យឧទាហរណ៍ ១អំពីគុណវិបត្តិ និង ១អំពីគុណប្រយោជន៍របស់ការសន្សំរបស់មានតម្លៃរបស់អ្នកនៅកន្លែងសម្ងាត់ និងនៅធនាគារ ។
៩. ចូរបង្កើតជាសំណួរដែលចាប់ផ្ដើមដោយពាក្យ *ហេតុអ្វី ពេលណា អ្វី នៅឯណា នរណា* អំពីការពិតដែលមនុស្សប្រើប្រាស់លុយដុល្លារ និងរៀលក្នុងប្រទេសកម្ពុជា។ សំណួរមួយផ្ដើមដោយពាក្យទាំងអស់នេះ។
១០. តើបញ្ហាសំខាន់អ្វីដែលអ្នកបានរៀនក្នុងម៉ូឌុលនេះនិងប្រើប្រាស់វាក្នុងជីវិតប្រចាំថ្ងៃរបស់អ្នក? ពន្យល់ពីមូលហេតុ។

# ចម្លើយរបស់តារាងវាយតម្លៃសិស្ស

១. ពិនិត្យសៀវភៅសន្សំ។ តើសិស្សបានបំពេញក្នុងការសន្សំរបស់ពួកគេក្នុងតារាងត្រឹមត្រូវឬទេ?
ប្រសិនជាពួកគេមានសណ្ដាប់ធ្នាប់ និងធ្វើការកត់ត្រាជាទៀងទាត់ ពួកគេទទួលបាន ២ពិន្ទុ។
ប្រសិនបើពួកគេកត់ត្រាបានទៀងទាត់ ប៉ុន្តែគ្មានសណ្ដាប់ធ្នាប់ ពួកគេទទួលបាន ១ពិន្ទុ។
២. តម្រូវការ គឺជាអ្វីចាំបាច់សម្រាប់យើងដើម្បីរស់នៅក្នុងភាពថ្លៃថ្នូរ។ វាគឺជាសិទ្ធិរបស់យើងដែលត្រូវ មានវា។
ចំណង់ គឺជាអ្វីដែលយើងចូលចិត្ត ឬ ប៉ងប្រាថ្នា ប៉ុន្តែមិនចាំបាច់សម្រាប់ការរស់នៅ ការអភិវឌ្ឍ ការចូលរួម និងការការពារ។
ត្រូវទាំងពីរ = ១ពិន្ទុ
៣. ខាងក្រោមនេះជាតម្រូវការ និងចំណង់ ប៉ុន្តែវាមានច្រើនទៀត។ គ្រូអាចសម្រេចចិត្តថាតើពួកគេចាំ បាច់ (តម្រូវការ) ឬក៏ប៉ងប្រាថ្នា (ចំណង់)។

| តម្រូវការ | អាហារូបត្ថម្ភ | កន្លែងកំសាន្ត | វត្តអារាម | វប្បធម៌ | ការការពារ | សាលារៀន | សិទ្ធិបញ្ចេញមតិ | ការថៃទាំជំងឺ |
|---|---|---|---|---|---|---|---|---|
| ចំណង់ | អាហារគ្រោម | ស្ករគ្រាប់ | គ្រឿងអលង្ការ | ម៉ូតូថ្មី | សម្លៀកបំពាក់ថ្មី | កុំព្យូទ័រ | ទូរទស្សន៍ | បន្ទប់គេងផ្ទាល់ខ្លួន |

សិស្សសរសេរតម្រូវការ ៣ និងចំណង់ ៣ = ១ពិន្ទុ

៤. អនុស្សាវរីយ៍សប្បាយចែករំលែកទៅដល់ចិត្តគំនិតវិជ្ជមាន។ ការចងចាំពេលវេលាល្អ និងពេលសប្បាយរីករាយធ្វើឱ្យអ្នកសប្បាយរីករាយ និងជួយអ្នកឆ្លងកាត់ពេលវេលាពិបាក។

សិស្សសរសេរអំពី "ធ្វើឱ្យអ្នកសប្បាយចិត្ត" ឬ "ជួយអ្នកនៅពេលវេលាពិបាក" = ១ពិន្ទុ

៥. វាមានន័យថា នៅពេលអ្នកសន្សំលុយ ឬសម្ភារៈផ្សេងៗ ការធ្វើបែបនេះអាចត្រូវបានប្រើនៅថ្ងៃដែលអ្វីមួយមិនល្អ ឬព្រឹត្តិការណ៍អ្វីមួយកើតឡើងដោយមិនបានគិតទុកជាមុន។ ឧទាហរណ៍ ៖ អ្នកត្រូវទៅ មន្ទីរពេទ្យភ្លាមៗ ឬរបស់ប្រើប្រាស់នៅក្នុងផ្ទះបែកបាក់។ អ្នកត្រូវការចំណាយសម្រាប់របស់របរទាំងនេះ។ ដូច្នេះ អ្នកត្រូវមានលុយ ឬរបស់សន្សំ។

ល្អ = ១ពិន្ទុ

៦. ចូរមើលតារាងដូចដែលបានពណ៌នាក្នុងមេរៀនទី ៤

| កាលបរិច្ឆេទ | ការសន្សំចូល | ការសន្សំចេញ | សរុប |
|---|---|---|---|
| ឧ. ថ្ងៃអង្គារ ទី១៧ ខែមីនា | ទង្វើល្អ២ | មិនមាន | ទង្វើល្អ២ |
| ថ្ងៃព្រហស្បតិ៍ ទី១៩ ខែមីនា | ទង្វើល្អ១ | មិនមាន | ទង្វើល្អ៣ |

សិស្សសរសេរ តារាងទាំង៤ = ២ពិន្ទុ

សិស្សសរសេរ ៣ក្នុងចំណោមតារាងទាំង៤ = ១ពិន្ទុ

៧. ចម្លើយគឺ ២១ដុល្លារ។

ពន្យល់ = ៥% នៃ២០ដុល្លារ = ១ដុល្លារ ដូច្នេះសរុបត្រូវជា ២១ដុល្លារ។

នៅពេលសិស្សគណនាជាលុយរៀល ពួកគេគួរមានការប្រាក់ ៤ ០០០រៀល ហើយសរុបត្រូវជា ៨៤ ០០០រៀល។

ពន្យល់ ២០ដុល្លារ = ៨០ ០០០រៀល ហើយ ៥%នៃ ៨០ ០០០រៀល =៤ ០០០រៀល។

ចម្លើយត្រឹមត្រូវ ការប្រាក់បូកប្រាក់ដើម = ១ពិន្ទុ

៨. មានគុណវិបត្តិ និងគុណប្រយោជន៍ជាច្រើន។ យើងក៏បានលើកឡើងខ្លះៗខាងក្រោមនេះ ប៉ុន្តែនៅ មានច្រើនទៀត។ វាអាស្រ័យលើគ្រូជាអ្នកសម្រេចថាត្រូវ ឬខុស។

| | គុណវិបត្តិ | គុណប្រយោជន៍ |
|---|---|---|
| កន្លែងសម្ងាត់ | ● អាចត្រូវគេលួច ឬ រកឃើញ<br>● គ្មានការប្រាក់/ផលប្រយោជន៍<br>● អាចភ្លេច | ● មានតែអ្នកម្នាក់គត់ដែលដឹងថាវានៅឯណា<br>● អាចរក្សាទុកមិននៅឆ្ងាយ<br>● មិនអាចប្រើបានភ្លាមៗ ពេលចាំបាច់ |
| ធនាគារ | ● ជួនកាល វានៅឆ្ងាយ<br>● មិនអាចប្រើបានភ្លាមៗ<br>● អានមានការពិបាកនៅពេលដែលអ្នកមិនបាន រៀនពីប្រព័ន្ធធនាគារ | ● បានការប្រាក់ / ផលប្រយោជន៍<br>● វាមានសុវត្ថិភាព មិនអាចលួចបាន<br>● អាចប្រតិបត្តិការបាននៅកន្លែងខុសៗគ្នា |

ឆ្លើយត្រឹមត្រូវចំពោះ គុណវិបត្តិ និងគុណប្រយោជន៍របស់ធនាគារ និងកន្លែងសម្ងាត់ = ២ពិន្ទុ
ឆ្លើយត្រឹមត្រូវតែមួយ គុណវិបត្តិ ឬក៏ គុណប្រយោជន៍របស់ធនាគារ និងកន្លែងសម្ងាត់ = ១ពិន្ទុ

៩. សិស្សដែលបានបង្កើត ៥សំណួរ ដែលសំណួរនីមួយៗចាប់ផ្តើមដោយពាក្យហេតុអ្វី ពេលណា អ្វី នៅកន្លែងណា នរណា = ២ពិន្ទុ
សិស្សដែលបានបង្កើត ចន្លោះ ៣ និង ៥សំណួរ = ១ពិន្ទុ
១០. ប្រសិនបើសិស្សអាចប្រាប់ពីសម្ភារៈសំខាន់ និងពន្យល់ថាហេតុអ្វី = ២ពិន្ទុ
ប្រសិនបើសិស្សអាចប្រាប់ពីសម្ភារៈសំខាន់ ប៉ុន្តែមិនពន្យល់ហេតុអ្វី = ១ពិន្ទុ

## ៦.ឯកសារបន្ថែម

មានអង្គការជាច្រើនដែលអាចផ្តល់ឯកសារបន្ថែម ប៉ុន្តែវាអាស្រ័យលើប្រធានបទ។ ភាគច្រើនឯកសារទាំងអស់នោះ គឺឥតគិតថ្លៃ និងអាចបង្កើតមេរៀនរបស់អ្នក។

ជាពិសេស គឺអង្គការ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាច្រើនស្ម័គ្រចិត្តផ្តល់ប័ណ្ណប្រកាស ឬខិត្តប័ណ្ណដែលអាចប្រើដើម្បីធ្វើឱ្យប្រធានបទកាន់តែច្បាស់ ឬដើម្បីប្រាប់សហគមន៍។

ខាងក្រោមនេះ គឺជាបញ្ជីធនធានដែលអាចប្រើបាន សម្ភារសិស្សគឺអាចមានជាភាសាខ្មែរ។

សម្ភារសិស្ស

- *មីក្រូក្រេឌីត ៖ របស់ដែលត្រូវចងចាំពេលខ្ចីលុយ។*
  មជ្ឈមណ្ឌលវប្បធម៌អាស៊ីប៉ាស៊ីភិកសម្រាប់យូណេស្កូ
  Asia Pacific Cultural Centre for UNESCO ( ACCU )
  http://www.accu.or.jp/litdbase/material/_data/material/Micro_Credit/Micro_Credit_KHM.pdf

- *ក្រុមសន្សំ*
  មជ្ឈមណ្ឌលវប្បធម៌អាស៊ីប៉ាស៊ីភិកសម្រាប់យូណេស្កូ
  Asia Pacific Cultural Centre for UNESCO ( ACCU )
  http://www.accu.or.jp/litdbase/material/_data/material/Savings_Group/Savings_Group_KHM.pdf

- *ការគ្រប់គ្រងប្រាក់របស់ខ្ញុំ*
  អង្គការអប់រំពិភពលោក - ខេប ( World Education - KAPE )
  សៀវភៅសម្រាប់គ្រូ និងសៀវភៅលំហាត់នេះ គឺជាផ្នែកមួយនៃកម្មវិធីបំណិនជីវិត និងផ្តល់នូវព័ត៌មាន លម្អិត និងលំហាត់បន្ថែមទៀតចំពោះការចាត់ចែងថវិកា និងរបៀបកាន់កាប់លុយក្នុងលក្ខណៈទូទៅ។

- *កម្មវិធី អាហ្វ្លេតទូន - www.aflatoun.org*
  សម្ភារៈជាច្រើនក្នុងសៀវភៅនេះត្រូវបានសរសេរដោយ អាហ្វ្លេតទូន (Aflatoun) ដែលជាកម្មវិធីហិរញ្ញវត្ថុអន្តរកម្មមួយ ដំណើរការនៅក្នុងប្រទេសជាច្រើនក្នុងពិភពលោក។ អង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា ហៅកាត់ថា ខេប (KAPE) មានកម្មវិធីក្នុងខេត្តក្រចេះ និងបានបង្កើតនូវសម្ភារៈ សម្រាប់សិស្ស និងគ្រូជាភាសាខ្មែរ។

**សម្ភារគ្រូ**

- *ការអប់រំហិរញ្ញវត្ថុ - សៀវភៅណែនាំគ្រូ*
  អង្គការពលកម្មអន្តរជាតិ ( International Labor Organization )
  http://www.ilo.org/wcmsp5/groups/public/---asia/---ro-bangkok/documents/publication/wcms_108270.pdf

- *ប្រព័ន្ធហិរញ្ញវត្ថុរបស់កម្ពុជា - សង្ខេប*
  ធនាគារអភិវឌ្ឍន៍អាស៊ី ( Asian Development Bank )
  http://www.adb.org/documents/books/finance-lower-mekong/finance-lower-mekong.pdf#page=44

**អង្គការដែលមានប្រយោជន៍**

- អង្គការពលកម្មអន្តរជាតិ ( International Labor Organization )
  http://www.ilo.org/asia/countries/lang--en/WCMS_DOC_ASI_CNT_KHM_EN/index.htm

- ធនាគារពិភពលោកកម្ពុជា ( World Bank Cambodia )
  http://go.worldbank.org/29CHC0WVF0

# វិញ្ញាបនប័ត្រ "ការសន្សំ និង ការចំណាយ"

វិញ្ញាបនប័ត្រនេះត្រូវបានផ្តល់ជូន

-----------------------

ដែលបានបង្ហាញចំណេះដឹង និងជំនាញក្នុងការកំណត់តម្រូវការ និងចំណង់ បង្កើតជាប្រព័ន្ធសន្សំ និងគ្រប់គ្រងចំណូល និងចំណាយក្នុងប្រអប់សន្សំ ។

ក្រៅពីនេះ សិស្សមានចំណេះដឹងអំពីប្រព័ន្ធធនាគារ ប្រព័ន្ធសន្សំផ្សេងៗក្នុងប្រទេសកម្ពុជា និងអាចកំណត់ចរិតលក្ខណៈនៃពួកគេនោះ ។

យើងមានទំនុកចិត្តថាសិស្សនឹងប្រើប្រាស់ចំណេះដឹង និងបំណិនទាំងអស់នេះក្នុងការក្លាយខ្លួនជាសមាជិកសង្គមដែលមានទំនួលខុសត្រូវ និងសម្បជញ្ញៈ ។

| | | | |
|---|---|---|---|
| ហត្ថលេខា | កាលបរិច្ឆេទ | ហត្ថលេខា | កាលបរិច្ឆេទ |

ឧបសម្ព័ន្ធ ១.១ : គំរូប័ណ្ណវាយតម្លៃ (សម្រាប់គ្រូ)

## ប័ណ្ណវាយតម្លៃការសិក្សារបស់សិស្សម្នាក់ៗ

ឈ្មោះសិស្ស ........................ សាលា...................... . ខេត្ត.............. ស្រុក................. ថ្នាក់ទី ........ ប្រធានបទ................

| ចំណុចត្រូវដាក់ពិន្ទុ | | ពិន្ទុ (១-១៥) | និទ្ទេស |
|---|---|---|---|
| **កិច្ចការទី ១: តេស្តចំណេះដឹង (សំណួរសរសេរ)** | | | |
| សំណួរសរសេរមានពិន្ទុសរុប ១៥ ពិន្ទុ បើពិន្ទុ 0 ដល់ ៧=ខ្សោយ/ បើ ៨ ដល់ ១០=មធ្យម / បើ ១១ ដល់ ១៥=ល្អ) | | | |
| **សង្កេតឥរិយាបថសិស្ស** | | ពិន្ទុ (១-៥) | និទ្ទេស |
| ១ | **ការប្រាស្រ័យទាក់ទង និងការសហការ :** សកម្មភាពពិភាក្សាជាមួយសមាជិកទាំងអស់ក្នុងក្រុម និងធ្វើការបានប្រសើរ ជាមួយក្រុម ។ សិស្សស្តាប់គ្នាទៅវិញទៅមក និងផ្តល់យោបល់គ្នាទៅវិញទៅមក ។ | | |
| ២ | **ការវិភាគល្អិតល្អន់ និងការដោះស្រាយបញ្ហា :** ផ្តល់ចម្លើយដោយមានហេតុផល និងអំណះអំណាងច្បាស់លាស់ និងអាចកំណត់ដំណោះស្រាយចំពោះបញ្ហាងាយៗដែលជួបប្រទះ ។ | | |
| ៣ | **ការធ្វើសេចក្តីសម្រេចចិត្តដោយខ្លួនឯង :** មិនមានការបារម្ភច្រើន ក្នុងការធ្វើសេចក្តីសំរេចចិត្ត និងដឹងច្បាស់ថាខ្លួនគេកំពុងនិយាយឬធ្វើអ្វីមួយ ។ | | |
| ៤ | **ទំនុកចិត្តលើខ្លួនឯង :** កំឡុងពេលធ្វើបទបង្ហាញនិងពិភាក្សាក្រុម សិស្សមានទំនុកចិត្តក្នុងការនិយាយ និងចូលរួមក្នុងក្រុម | | |
| ៥ | **ការលើកទឹកចិត្ត និងការយល់ចិត្ត:** សិស្សចង់បន្តរៀនសូត្របន្ថែមពីប្រធានបទនេះ ហើយយល់ច្បាស់ខ្លឹមសារក្នុង ប្រធានបទ និងការអនុវត្តផ្ទាល់ ។ | | |
| ៦ | **ចរិត : សិស្ស**មានចិត្តអំណត់និងអារម្មណ៍ល្អនៅក្នុងការសិក្សា ។ | | |
| ៧ | **ការបង្កើតថ្មី :** សិស្សបង្ហាញនូវភាពច្នៃប្រឌិតក្នុងការរៀបចំការធ្វើបទបង្ហាញផលិតផល នៅកំឡុងពេលសិក្សា ដោយបង្ហាញចេញនូវគំនិតជាច្រើន ។ | | |
| | **សរុបសង្កេតឥរិយាបថសិស្ស** | | |
| សង្កេតឥរិយាបថសិស្សមានពិន្ទុសរុប ៣៥ ពិន្ទុ ( បើពិន្ទុ 0 ដល់ ១៧ =ខ្សោយ/ បើ ១៨ ដល់ ២៣=មធ្យម / បើ ២៤ ដល់ ៣៥=ល្អ) | | | |
| ពិន្ទុសរុបសំណួរសរសេរ និងសង្កេតឥរិយាបថសិស្ស ( បើពិន្ទុ 0 ដល់ ២៤=ខ្សោយ/ បើ ២៥ ដល់ ៣៣=មធ្យម / បើ ៣៤ ដល់ ៥០=ល្អ) | | | |

ថ្ងៃទី .......... ខែ ........... ឆ្នាំ ..........

ហត្ថលេខា និងឈ្មោះគ្រូ

## ឧបសម្ព័ន្ធ ១.២ : តារាងបូកសរុបខ្វាយតម្លៃការសិក្សារបស់សិស្សប្រចាំថ្នាក់

ខេត្ត .......................... ស្រុក .........................សាលា .............................. ថ្នាក់ទី .......... ប្រធានបទ ....................

| ល.រ | ឈ្មោះសិស្ស | សំណួរសរសេរ | | តរិយាបថ | | សរុប | |
|---|---|---|---|---|---|---|---|
| | | ពិន្ទុ | និទ្ទេស | ពិន្ទុ | និទ្ទេស | ពិន្ទុ | និទ្ទេស |
| ១ | | | | | | | |
| ២ | | | | | | | |
| ៣ | | | | | | | |
| ៤ | | | | | | | |
| ៥ | | | | | | | |
| ៦ | | | | | | | |
| ៧ | | | | | | | |
| ៨ | | | | | | | |
| ៩ | | | | | | | |
| ១០ | | | | | | | |
| ១១ | | | | | | | |
| ១២ | | | | | | | |
| ១៣ | | | | | | | |
| ១៤ | | | | | | | |
| ១៥ | | | | | | | |
| ១៦ | | | | | | | |
| ១៧ | | | | | | | |
| ១៨ | | | | | | | |
| ១៩ | | | | | | | |
| ២០ | | | | | | | |
| ២១ | | | | | | | |
| ២២ | | | | | | | |
| ២៣ | | | | | | | |
| ២៤ | | | | | | | |
| ២៥ | | | | | | | |
| ២៦ | | | | | | | |

បានឃើញ និងឯកភាព　　　　　　　　　　ថ្ងៃទី .......... ខែ ............ ឆ្នាំ ..........

នាយកសាលា　　　　　　　　　　ហត្ថលេខា និងឈ្មោះគ្រូបង្រៀន

| **ការអង្កេតថ្នាក់រៀន** | | | | | **ការវាយតម្លៃគ្រូបំណិនជីវិត** |
|---|---|---|---|---|---|
| សាលារៀន | | | | គ្រូ | អ្នកសង្កេត |
| | | | | | |
| កាលបរិច្ឆេទ | ការចាប់ផ្ដើមមេរៀន | ការបញ្ចប់មេរៀន | ថ្នាក់ | ចំនួនសិស្សដែលបានចុះឈ្មោះ/មានវត្តមាន | ប្រធានបទបំណិនជីវិត: |
| | | | | | |
| តើមេរៀនបង្ហាញពីអ្វី? | | | | | |
| | | | | | |

| លក្ខណៈវិនិច្ឆ័យ – ការរៀបចំ – តើបន្ទប់រៀន.. | ពិន្ទុ | កំណត់សម្គាល់យោងតាមភស្តុតាង |
|---|---|---|
| មានសណ្ដាប់ធ្នាប់ ហើយ ត្រៀមសម្ភារៈរួចជាស្រេចសម្រាប់ប្រើប្រាស់ក្នុងមេរៀននេះ? | 1-2-3-4-5 | |
| បង្ហាញសិស្សនូវសម្ភារៈដែលបានធ្វើកាលពីមេរៀនមុន | 1-2-3-4-5 | |
| **លក្ខណៈវិនិច្ឆ័យ - ការសិក្សា - តើសិស្ស...** | **ពិន្ទុ** | **កំណត់សម្គាល់យោងតាមភស្តុតាង** |
| មានចំណាប់អារម្មណ៍ និងចូលរួមក្នុងការងាររបស់ពួកគេដែរឬទេ? | 1-2-3-4-5 | |
| ធ្វើការក្នុងក្រុមខុសៗគ្នាក្នុងកំឡុងពេលបង្រៀនដោយមានតួនាទីក្រុមច្បាស់លាស់ | 1-2-3-4-5 | |
| រីករាយជាមួយមេរៀនដែលគ្រូបង្រៀន | 1-2-3-4-5 | |
| បង្ហាញចំណេះដឹង ឬបំណិនពីមេរៀនមុន | 1-2-3-4-5 | |
| **លក្ខណៈវិនិច្ឆ័យ – ការបង្រៀន – តើគ្រូ..** | **ពិន្ទុ** | **កំណត់សម្គាល់យោងតាមភស្តុតាង** |
| អនុវត្តតាមកិច្ចតែងការបង្រៀនដែលមានឬទេ? | 1-2-3-4-5 | *សូមបញ្ជាក់ធាតុណាមួយដែលត្រូវបានប្រើ* |
| ប្រើប្រាស់ធនធានសហគមន៍ក្នុងការបង្រៀនមេរៀននេះ ឬប្រើប្រាស់សហគមន៍ទាំងស្រុង? | 1-2-3-4-5 | |

| | | |
|---|---|---|
| ប្រើប្រាស់វិធីសាស្ត្របង្រៀនបែបអន្តរកម្ម/សកម្ម ឧ.ផែនទីគំនិត, ករណីសិក្សា, ការសម្តែងតួ, ល្បែងកំសាន្ត... | 1-2-3-4-5 | |
| ប្រើប្រាស់ប្រភេទសំណួរផ្សេងៗ | 1-2-3-4-5 | |
| ប្រើប្រាស់ធនធានបង្កើតឡើងដោយខ្លួនឯង ឬឯកសារបន្ថែមដើម្បីពន្យល់មេរៀន | 1-2-3-4-5 | |
| ចាប់ផ្តើមតាមពេលកំណត់ និងប្រើប្រាស់ពេលវេលាយ៉ាងមានប្រសិទ្ធភាព | 1-2-3-4-5 | |
| ផ្តល់មតិយោបល់វិជ្ជមានដើម្បីជំរុញការសិក្សា និងបង្កើនទំនុកចិត្តដល់សិស្ស | 1-2-3-4-5 | |
| ជួយសិស្សជាលក្ខណៈបុគ្គលចំពោះសិស្សណាដែលមានការលំបាក | 1-2-3-4-5 | |
| កត់ត្រាការវិវត្តនៃអត្តចរិតសិស្សក្នុងតារាងវាយតម្លៃការសិក្សារបស់សិស្ស? | 1-2-3-4-5 | |

បន្ទាប់ពីផ្នែកនេះ ចូរប្រើប្រាស់កំណត់ត្រារបស់អ្នកដើម្បីពិភាក្សាជាមួយគ្រូ។ **សុំឱ្យគ្រូកំណត់ចំណុចល្អរបស់មេរៀន** ហើយស្នើសុំការផ្លាស់ប្តូរ ឬការកែលម្អ។ ធ្វើការជាមួយគ្រូដើម្បីកំណត់ភាពខ្លាំង។ ធ្វើការផ្តល់គំនិតចំពោះការកែលម្អ។ ការសង្កេតត្រូវបានបញ្ចប់ ដោយធ្វើការសម្ភាសន៍។

| ចំណុចខ្លាំង | គំនិតសម្រាប់កែលម្អ |
|---|---|
| | |

ហត្ថលេខា និងឈ្មោះរបស់អ្នកវាយតម្លៃ ......................

ហត្ថលេខា និងឈ្មោះរបស់គ្រូ ....................................


ចំណង់ ឬ តម្រូវការ
X
✓
ការងារ
វត្តអារាម ឬ វិហារអ៊ិស្លាម
មិត្តភក្តិ
លុយជាច្រើន
ទូរទស្សន៍
សាលារៀន
កុំព្យូទ័រផ្ទាល់ខ្លួន
ម៉ូតូថ្មី
ស្ករគ្រាប់ និង នំស្រួយ
សម្រាកពេញមួយថ្ងៃ
គ្រឿងអលង្ការ
ការថែរក្សាជម្ងឺពីគ្រូពេទ្យ
ការការពារពី ការរំលោភបំពាន ឬ ការប្រមាថ
ឡានឡិចស៊ីស
ឈប់
STOP
បន្ទប់គេងផ្ទាល់ខ្លួន
អាហារភ្លាមៗ
សិទ្ធិសម្រាប់ការពារពីការរើសអើង
អាហារូបត្ថម្ភ
ទឹកស្អាត
សំលៀកបំពាក់ និង ម៉ូដនិយមថ្មី
កន្លែងកំសាន្ត និងការកំសាន្តសប្បាយ
ទូរស័ព្ទថ្មី
សេរីភាពដើម្បីប្រតិបត្តិវប្បធម៌របស់ខ្លួនផ្ទាល់
ការបញ្ចេញមតិយោបល់
USAID

# រូបិយវត្ថុកម្ពុជា



ប្រភេទក្រដាសប្រាក់: ៥០រៀល
ទំហំ: ១៣០មម x ៦០មម
ឆ្នាំបោះពុម្ព: ២០០២
ពណ៌ផ្ទៃ: លឿងទុំ
ពណ៌នា: ផ្នែកកណ្ដាលនៃក្រដាសប្រាក់នេះមានរឿងនូវរូបខ្លោងទ្វារប្រាសាទបន្ទាយស្រី។ ផ្នែកខាងស្ដាំមានរូបព្រះ និងផ្នែកខាងឆ្វេងមានរូបចម្លាក់ក្បាលនាគ។



ប្រភេទក្រដាសប្រាក់: ១០០រៀល
ទំហំ: ១៣០មម x ៦០មម
ឆ្នាំបោះពុម្ព: ២០០១
ពណ៌ផ្ទៃ: ស្វាយ និងបៃតង
ពណ៌នា: រំលេចរឿងរូបវិមានមាត់នៃសាលារៀនមួយកន្លែង និងសិស្សប្រុសស្រីកំពុងដើរសំដៅទៅកាន់ថ្នាក់រៀនរបស់ខ្លួន។



ប្រភេទក្រដាសប្រាក់: ៥០០រៀល
ទំហំ: ១៣៥មម x ៦៥មម
ឆ្នាំបោះពុម្ព: ២០០៣
ពណ៌ផ្ទៃ: ក្រហម
ពណ៌នា: រូបភាពស្ពានគីហ្សូណា "កម្ពុជា-ជប៉ុន"ដែលឆ្លងកាត់ទន្លេមេគង្គ ស្ថិតក្នុងខេត្តកំពង់ចាម។



ប្រភេទក្រដាសប្រាក់: ១០០០រៀល
ទំហំ: ១៣៥មម x ៦៥មម
ឆ្នាំបោះពុម្ព: ២០០៦
ពណ៌ផ្ទៃ: ពណ៌បៃតង និងខៀវ
ពណ៌នា: រូបភាពកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ ដែលកំពុងមានសកម្មភាពយ៉ាងសកម្មក្នុងការផ្ទុកដាក់ទំនិញ។



ប្រភេទក្រដាសប្រាក់: ២០០០រៀល
ទំហំ: ១៤៦មម x ៦៥មម
ឆ្នាំបោះពុម្ព: ២០០៨
ពណ៌ផ្ទៃ: បៃតងក្រម៉ៅ និងលឿង
ពណ៌នា: រូបទ្វារប្រាសាទព្រះវិហារ និងអក្សរ "ពីរពាន់រៀល" នៅពីខាងក្រោម។



ប្រភេទក្រដាសប្រាក់: ៥០០០រៀល
ទំហំ: ១៤៦មម x ៦៥មម
ឆ្នាំបោះពុម្ព: ២០០១
ពណ៌ផ្ទៃ: ប្រផេះ និងបៃតង
ពណ៌នា: រូបស្ពានប្រាសាទនៅកំពង់ក្ដី ខេត្តសៀមរាប។



ប្រភេទក្រដាសប្រាក់: ១០០០០រៀល
ទំហំ: ១៤៦មម x ៦៥មម
ឆ្នាំបោះពុម្ព: ២០០១
ពណ៌ផ្ទៃ: ពណ៌ស្វាយ ពណ៌ខ្មៅ និងខៀវ
ពណ៌នា: រូបភាពពិធីបុណ្យអុំទូកនៅមុខព្រះបរមរាជវាំង។



ប្រភេទក្រដាសប្រាក់: ២០០០០រៀល
ទំហំ: ១៥០មម x ៧០មម
ឆ្នាំបោះពុម្ព: ២០០៨
ពណ៌ផ្ទៃ: ស៊ីជម្ពូ និងពណ៌ខៀវ
ពណ៌នា: រូបភាពប្រាសាទបាយ័នទាំងមូលមើលពីលើ និងរូបចម្លាក់ព្រះព្រហ្មមុខបួននៃប្រាសាទបាយ័ន។



ប្រភេទក្រដាសប្រាក់: ៥០០០០រៀល
ទំហំ: ១៥០មម x ៧០មម
ឆ្នាំបោះពុម្ព: ២០០១
ពណ៌ផ្ទៃ: លឿង ពណ៌ត្នោត និងខ្មៅ
ពណ៌នា: រូបភាពប្រាសាទអង្គរវត្ត មើលពីទិសខាងលិច។

# ការសន្សំ និង ការចំណាយ

## ក្បួនសំខាន់ៗនៃការសន្សំ

1. គិតអំពីតម្រូវការ និង សេចក្តីចង់បានរបស់អ្នក
2. រៀនធ្វើជាអាទិភាព
3. ជ្រើសរើសរបស់ណា ដែលមិនគិតថ្លៃ និងមានតម្លៃថោក
4. ចាប់ផ្តើមធ្វើការសន្សំពីចំនួនដ៏តិចតួច
5. កុំប៉ះពាល់ការសន្សំរបស់អ្នក ប្រសិនបើអ្នកពិតជាមិនត្រូវការវា
6. កុំបាក់ទឹកចិត្ត
7. ការសន្សំលុយនឹងធ្វើឲ្យអ្នកអាចចំណាយបានទៅលើ *ការចង់បាន*របស់អ្នកនៅថ្ងៃអនាគត
8. គ្រប់ៗគ្នាគឺអាចសន្សំបាន

ដូច្នេះ តើអ្វី ដែលជាដំបូន្មានរបស់អ្នកអំពីការសន្សំ? តើអ្នកមានដឹងអ្វីផ្សេងទៀតទេ ដែលយើងអាចសន្សំបាន? ឬ ក៏អ្នកមានវិធីសាស្ត្រអ្វីផ្សេងទៀត?

## ការសន្សំរបស់ដែលជាលុយ







## វិធីសាស្ត្រក្នុងការសន្សំ



















## ការសន្សំរបស់ក្រៅពីលុយ






















## វិធីសាស្ត្រក្នុងការសន្សំ



DEUTSCHE ZUSAMMENARBEIT

Implemented by giz

aecid